ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយជំនឿខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣៦ លេខ ១ ខែ មករា

ព.ស. ២៥០៦ គ.ស. ១៩៦៤

- ភ្នំពេញ -

ភ.២៥៩
ទំហំ 16cx24c0
១១០ ទំព័រ
៣-៥-២៧៥

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ
ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — ទំព័រ

ព្រះពុទ្ធសាសនា និងអពុទ្ធសាសនិក (វិចារណកថា) លោក ផង-ដ្រីវ និពន្ធ . . . ១
ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៉ូ-ប៉ូ តែងរៀបរៀង (ត) . . . ៨
ក្ខាទសកម្មាឋា ព្រះមុនីកោសល ស្វ-ហាយ អធិបតីរងនៃក្រុមជំនុំព្រះត្រៃបិដក រៀបរៀង ១៦

*ផ្នែកអក្សរសាស្ត្រ*

បញ្ហាជីវិត (វិចារណកថា) សហជីវិន ផល-ទិត្យ នៅពុទ្ធសាសនបណ្ឌិត្យនិពន្ធ . . ៣០
វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង-ខាត់ រៀបរៀង (ត) . . . . ៤១
រឿងអាប៊ូលហ៊ាអ៊ូរ៉ស់ លោក រាយ-ល្អុត ជំណាងរាស្ត្រ ប្រែរៀបរៀង . . . ៤៣
រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង (ត) . . . ៥៤
ល្បើកឡាហ្វុងតែន លោកផង-ដ្រីវ ប្រែពីភាសាបារាំង (ត) . . . . . ៧៩
រឿងព្រេង ចិន (យើងត្រូវចែកការគ្នាធ្វើ) លោក វ៉ាយ-ប៊ុក ប្រែពីភាសាបារាំង (ត) . . ៨៤
ទំនៀមទម្លាប់ខ្មែរ: ប្រាសាទវត្តអង្គរ នៅខេត្តកំពង់ចាម . . . . . ៨៦

*ផ្នែកកំណត់ទិនប្រវត្តិការណ៍*

– អនុសំវច្ឆរៈ មហាសន្និបាទ នៃមន្ត្រីសង្ឃលើកទី ២០ ឆ្នាំ១៩៥៤ . . . . . ៩៦
– សុន្ទរកថា សហជីវិនអនុរដ្ឋលេខាធិការ ក្រសួងធម្មការ . . . . . ១០២
– រឿងតាំងចៅអធិការ សំរាប់វត្តនានា . . . . . . . ១០៨

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០:០០

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អពៅ
ឲ្យជុំសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា

ប.ព.

# ព្រះពុទ្ធសាសនា និងអពុទ្ធសាសនិក

(វិចារណកថា)

លោក ដេង-ជ្រីវ ទិពន្ធ

ព្រះពុទ្ធសាសនា ជាសាសនារបស់មនុស្សអស្ចារ្យម្នាក់ មានព្រះបរមនាមព្រះសិទ្ធត្ថ ជាសាក្យគោត្រ ក្នុងនគរកបិលពស្តុនៃដែនសក្កៈ ឥឡូវហៅថា «នេប៉ាល់» ក្នុងប្រទេសឥណ្ឌា ។ ក្រោយដែលព្រះសិទ្ធត្ថបានធ្វើទុក្ករកិរិយាអស់ ៦ ព្រះវស្សាក្នុងព្រៃ ទ្រង់ក៏បានត្រាស់ដឹងនូវសច្ចធម៌ ហើយបាននាមថ្មីហៅថាព្រះពុទ្ធ ។ តមក ព្រះពុទ្ធទេសនាប្រដៅមនុស្សទូទៅ ដោយប្រកាន់យកកម្មៈជាមូលដ្ឋាននៃសេចក្ដីសុខទុក្ខរបស់សត្វក្នុងលោក ។ ទើបសាសនានេះ មាននាមថាព្រះពុទ្ធសាសនាតរៀងតមក ។

នៅក្នុងលោក មិនមែនមានតែព្រះពុទ្ធសាសនាមួយទេ គឺមានសាសនាដទៃទៀត ។ ក្រៅពីព្រះពុទ្ធសាសនា គេសង្កេតឃើញមានសាសនាព្រាហ្មណ៍ សាសនាមហាម៉ត់ និងសាសនាគ្រិស្ត ។ សាសនា

ព្រាហ្មណ៍ជាសាសនាដែលបរិស័ទគោរពព្រះ ៣ ព្រះអង្គ គឺ ព្រះព្រហ្ម ព្រះឥសូរ និងព្រះនារាយណ៍ ។ ព្រះទាំងបីព្រះអង្គនេះ មានតែនាម មិនមានរូបជាមនុស្សឬជាទេព្តា ឲ្យឃើញជាភស្តុតាង ពិតប្រាកដនឹងភ្នែកដ៏ជាក់ស្តែងទេ ។ សាសនាមហាម៉ាត់ មានព្រះមហាម៉ាត់ជាមេតំណាងសាស-នា ។ ឥស្លាមសាសនានេះ ប្រដៅឲ្យប្រកាន់យកព្រហ្មលិខិត ទុកជាគោលជតាកសីនៃមនុស្ស ។ ឯសាសនាគ្រិស្ត មានព្រះហៀហ្សូយគ្រិស្ត (Jésus-Christ ជាមេដឹកនាំ ។ សាសនានេះ ប្រកាន់ថាព្រះគ្រិស្តជាកូនព្រះអាទិទេព ដែលទ្រង់ឲ្យមកកើតជាមនុស្ស ដើម្បីទទួលរ៉ាប់រងទោសរបស់សត្វលោក ។

សាសនាទាំងបួនខាងលើ សំដែងទ្រឹស្តីថាមនុស្ស ត្រូវតែធ្វើអំពើល្អ ហើយឲ្យវៀរចាកអំពើអាក្រក់ ។ មិនតែប៉ុណ្ណោះ សាសនាបានសំដែងថា មានឋានសួគ៌ជាកន្លែងជាទីសំណាក់អាស្រ័យនៅនៃអ្នកធ្វើអំពើល្អ ខាងក្រោយដែលខ្លួនស្លាប់ទៅ និងមានឋាននរកជាកន្លែងជាទីសំណាក់នៅនៃអ្នកដែលធ្វើអំពើអាក្រក់ ។ តាមការដឹង ឃើញថា សាសនាទាំងនេះ ពោលថាមានឋានសួគ៌និងឋាននរកដូចគ្នា ។

ដូច្នេះឋានសួគ៌ និងឋាននរក ជាទ្រឹស្តីដ៏ពិតប្រាកដនៃសាសនាទាំងឡាយក្នុងលោក ។ ចំពោះសាសនាបី គឺព្រាហ្មណសាសនា ឥស្លាមសាសនា និងគ្រិស្តសាសនា បរិស័ទនៃសាសនានីមួយ ៗ ឬមនុស្សក្នុង

សង្គមសាសនានោះនោះ មិនសូវដែលឮពោលរិះគន់ ទីងពោលជំទាស់ ថាជាសាសនា ដែលធ្វើឲ្យមានការរអាក់រអួលដល់វឌ្ឍនភាព នៃសង្គមមនុស្ស មិនសូវដែលឮពោលថា សំដីរបស់ព្រះគេ ត្រង់នេះសម ត្រង់នោះមិនសម បានន័យថា គេចង់ធ្វើអ្វី គេធ្វើទៅ គេចង់ជឿ គេជឿទៅ បើគេមិនកាន់មិនជឿក៏វ្ហើទៅ តែត្រង់សំដីបន្ទោសចំពោះសាសនា គឺមិនមានៗ គេនិយមទុកសាសនា ជាវត្ថុពិសេសដាច់ដោយឡែក ឧបមាដូចជាព្រះមហាក្សត្រជាបុគ្គលជាទីសក្ការបូជានៃប្រជារាស្ត្រ ហើយស្ថិតនៅខ្ពស់ហួសការប្រៃណនិន្ទា ៗ

ចំពោះព្រះពុទ្ធសាសនាវិញ ជាសាសនាដែលប្រជាពលរដ្ឋខ្មែរស្ទើរ ១០០ ភាគ ១០០ កាន់ទឹងប្រតិបត្តិតាម ៗ មានខ្មែរខ្លះ តែភាគតិច និយមពោលរិះគន់ ខ្លះរហូតដល់ទៅប្រមាថថាសាសនាព្រះពុទ្ធ ធ្វើឲ្យមនុស្សខ្ជិល ប្រទេសខ្មែរបានជាមានការចំរើនមិនបរិបូណ៌ មកពីមានព្រះពុទ្ធសាសនា ជាឈើខ្ទាស់កាំកង់មិនឲ្យរទេះលឿនទៅបានដោយស្រួល ៗ អ្នកដែលថានេះខ្លះក៏បានរៀនលទ្ធិព្រះពុទ្ធសាសនា ខ្លះបានឃើញតែទម្រង់ក្រៅ ត្រង់ជម្រៅអត្ថន័យនៃសាសនា ខ្លួនគ្មានដឹងសោះ តែអាចហើបមាត់ថាឯបេះឯចុះទាំងព្រាវ ទាំងងងិត ទៅបានដែរ ៗ ពិតមែនតែក្នុងច្បាប់រដ្ឋធម្មនុញ្ញ មានមាត្រាខ្លះ ចែងថាមនុស្សមានសេរីភាពក្នុងជំនឿ ក្នុងការគិត ពិចារណាសព្វយ៉ាងបាន តែមុននិងរិះគន់ មុននិងនិន្ទា គួរជញ្ជឹងគិតមួយស្របក់

សិនថាអាត្មាអញមានសញ្ជាតិជាអ្វី? អាត្មាអញដែលបានកើតមានរូបមានរាងជាមនុស្សនេះដោយសារនរណា? នរនោះមានសញ្ជាតិជាអ្វី? គោរពសាសនាអ្វី? បើអញថាយ៉ាងនេះ នឹងអាចផ្តល់ផលជាតិខ្លួន ទូលទូផលជាកុសល ឬជាអកុសលធំប៉ុណ្ណា? សំដីជាអកុសលនៃខ្លួននឹងអាចបង្កើតជាបដិវត្តន៍ខាងសាសនាបានឬទេ? ខ្លួននឹងអាចឡើងកាន់ឋានៈជាមេដឹកនាំជាតិបានដែរឬទេ? ខ្លួនមានបរិស័ទចុះចូលចំនួនប៉ុន្មានហើយ? ។

តាមការសង្កេតឃើញ សម័យឥឡូវ គំនិតរួបរួមរាងមនុស្សសាកលមានពកជាពន្លកហើយ ទោះអ្នកណាកាន់សាសនាណាក៏ដោយ កាន់របៀបគ្រប់គ្រងប្រទេសផ្សេងពីគ្នាក៏ដោយ គំនិតដ៏ប្រពៃនេះ បានមានឡើង ព្រោះគេយល់ថា មនុស្សរមែងត្រូវការរស់ ត្រូវការសន្តិភាពដូចគ្នា គួរគប្បីកាន់ដៃគ្នាកសាងសន្តិភាព ។ តើមានប្រយោជន៍អ្វីនឹងចោទគ្នា នឹងរិះគន់និន្ទាគ្នា ថាព្រោះតែកាន់សាសនានេះ សាសនានោះ? តើមានប្រយោជន៍អ្វីនឹងធ្វើទុក្ខគ្នា ព្រោះតែគេប្រកាន់របៀបគ្រប់គ្រងដទៃពីខ្លួន? ឧបមាដូចជាភូមិមួយ មានគ្រួសារច្រើន គ្រួសារខ្លះចិញ្ចឹមជីវិតដោយធ្វើរបរពោត ខ្លះទៀតដោយរបរស្រូវ ដោយរបរធ្វើការរាជការ . . . តាមការពិសោធន៍ គឺមិនដែលឃើញមិនដែលឮ ថាគ្រួសារនេះទៅរិះគន់និន្ទាដល់គ្រួសារដទៃ ព្រោះតែគេមិនប្រកាន់មុខរបរដូចខ្លួន ។

ឥឡូវខ្ញុំវិលមកបញ្ហាស្តីពីការរិះគន់និន្ទាចំពោះព្រះពុទ្ធសាសនាវិញ ។

ដែលរិះគន់ទិន្នានេះ គាត់ច្រើនជាអ្នកស្រវឹងដោយវិជ្ជាវិទ្យាសាស្រ្ត ហើយលង់ចិត្តគិតស្មានថា មានតែវិទ្យាសាស្រ្តទេ ដែលអាចដឹកនាំលោកទៅរកសេចក្តីចំរើនបាន ។ ការយល់នេះ ត្រូវបានតែមួយផ្នែកទេ ។ ការចំរើននឹងប្រព្រឹត្តទៅពេញលក្ខណៈបាន លុះណាតែមានសន្តិភាពបរិបូណ៌ ។ ឃើញហើយស្រាប់ សព្វថ្ងៃ វិទ្យាសាស្រ្តកើតបរិបូណ៌មែន តើមនុស្សលោកគ្រប់សញ្ជាតិ បានសុខសន្តិភាពបរិបូណ៌ឬទេ? បើឲ្យសាសនាចំរើនវិញ ហើយកុំឲ្យលាយឡំដោយនយោបាយ យល់ថាសុខសន្តិភាពនឹងមានប្រាកដ ព្រោះការសុខទុក្ខនៃមនុស្ស មិនមែនសម្រេចដោយសម្ភារៈជាប្រមាណទេ គឺសម្រេចដោយចិត្តស្ងប់ ចិត្តមេត្តា ចិត្តមានខន្តី ។ ចំពោះរឿងនេះ សាសនាណាក៏មានប្រៀនប្រដៅ តែតាមការសំគាល់នៃការដឹង ព្រមទាំងការត្រិះរិះ ឃើញថាព្រះពុទ្ធសាសនា ប្រដៅច្រើនជាងសាសនាដទៃ ។ ពុទ្ធវាទមិនឲ្យពុទ្ធបរិស័ទ គោរពត្រឹមតែជីវិតមនុស្សផងគ្នាទេ ឲ្យគោរពសត្វតិរច្ឆានផងថែមទៀត ព្រោះសាសនានេះ យោលទៅរកការរស់នៅជាប្រមាណ ។ អ្វីដែលត្រូវការរស់ រមែងស្រឡាញ់ជីវិត រមែងក្តៅក្រហាយនឹងគេ ដែលធ្វើឲ្យបាត់បង់ជីវិតខ្លួន ។ ការក្តៅក្រហាយនេះហើយដែលក្លាយទៅជាភ្លើង ។ ដើម្បីរំលត់ភ្លើង មានតែរកទឹកគឺសាសនា ចុះបើគិះដៀលសាសនាទៅហើយ ត្រូវតែរកភ្លើងមករំលត់ភ្លើង ដែលជាការផ្ទុយនឹងនីតិធម្មជាតិ ។

ដូច្នេះត្រូវសន្និដ្ឋានថា អ្នកតិះដៀល អ្នករិះគន់ អ្នកប្រមាថសាសនា ជាពិសេសព្រះពុទ្ធសាសនា ទុកជាមនុស្សមានការភាន់ច្រឡំយ៉ាងធំ ។

អ្នកប្រាជ្ញភាគច្រើនក្នុងលោក និយមព្រះពុទ្ធសាសនា ទុកជាសាសនាស្ដីពីការស្វែងរកសន្តិភាព ស្ដីពីការស្វែងរកសុចរិតយុត្តិធម៌ច្រើន ដើម្បីមនុស្ស ប្រសើរជាងសាសនាដទៃ ព្រោះជម្រៅអត្ថន័យនៃសាសនានេះ ស្ថិតនៅត្រង់មេត្តា ករុណា សច្ចនឹងយុត្តិធម៌ ។

អាស្រ័យហេតុនេះ ទើបមានការស្ដាយពន់ពេក ចំពោះខ្មែរវិទ្យាសាស្ត្រខ្លះ ដែលនិយមតាំងចិត្តពោលរិះគន់ទឹងទិន្នាចំពោះព្រះពុទ្ធសាសនា ដែលជាបង្គោលចិត្តរបស់ខ្មែរទាំងប្រទេស ។

ចំពោះរឿងសាសនា កុំថាឡើយមនុស្សសាមញ្ញ សូម្បីមហារដ្ឋបុរសដ៏ឆ្នើមមានជាអាទិ៍ គឺសម្ដេចព្រះនរោត្ដម-សីហនុ ព្រះបិតាឯករាជ្យជាតិ ព្រះប្រមុខរដ្ឋប្រទេសកម្ពុជា ទ្រង់ក៏ប្រកាន់ទុកសាសនា ពិសេសព្រះពុទ្ធសាសនា ជាវត្ថុដ៏ប្រសើរបំផុត ប្រៀបបាននឹងជាតិដែរ បានជាក្នុងត្រីបាវចនា មានសាសនានៅក្នុងនោះផង «ជាតិ សាសនា ព្រះរាជបល្លង្ក» ។

ព្រះចៅអធិរាជណាប៉ូឡេអុងទី ១ នៃប្រទេសបារាំង បានទុកមនុស្សដូចជាទូក ដែលនឹងត្រូវតែរៀបរេរទៅតាមកម្លាំងខ្យល់ ប្រសិនបើគ្មានសាសនាជាបង្គោលចិត្ត ។ ដូច្នេះហើយ បានជាព្រះចៅអធិរាជអង្គនេះ

ពោលថា «សាសនាទុកដូចជាចង្កូត» របស់ទូកគឺមនុស្ស ។ មនុស្ស ណាដែលគ្មានសាសនា ទុកដូចជាទូកគ្មានចង្កូត ។

សូមអ្នកវិទ្យាសាស្ត្រគ្រើម ៗ មុននឹងរិះគន់ឬប្រមាថព្រះពុទ្ធសាសនា មេត្តាត្រិះរិះឲ្យសព្វ ជញ្ជឹងឲ្យគ្រប់ កុំចេះតែថាឲ្យរួចពីមាត់ ៗ ពាក្យចាស់ពោលទុកមកថា «នោចបាក់គ្រាន់ដួស ពាក្យជ្រុលហួសដួសមិនបាន» ។

បើមិនមានព្រះនរបតី ជាអ្នកគ្រប់គ្រងដឹកនាំ ដោយប្រពៃទេ ប្រជាជនទុកដូចជានាវាមិនមាន ចង្កូត នឹងវង្វេងលិចលង់ក្នុងជលធី ៗ

ព្រះនរបតីគ្រប់គ្រងរក្សានូវប្រជាជន ប្រជាជន ធ្វើឲ្យចំរើនព្រះនរបតី ការគ្រប់គ្រងប្រសើរ ជាងសេចក្តីចំរើន បើមិនមានការគ្រប់គ្រងរក្សា សេចក្តីចំរើននោះទេ សេចក្តីចំរើននឹងត្រឡប់ វិនាសអន្តរាយបាត់បង់ទៅវិញ ។

ហិតោបទេស

# ព្រះអភិធម្មបិដក

(គម្ពីរព្រះមហាបដ្ឋាន)

លោក ប៊ូ-ប៉ូ រៀបរៀង

តមក

## ៩– ឧបត្ថម្ភកកម្ម

ឧបត្ថម្ភកំ ណាម កុសលោបិ លព្ភតិ អកុសលោបិ ឯកច្ចោ ហិ កុសលំ កត្វា សុគតិភវេ និព្វត្តិ តត្ថ ឋិតោ បុនប្បុនំ កុសលំ កត្វា តំកម្មំ ឧបត្ថម្ភអនេកានិ វស្សសតសហស្សានិ សុគតិភវេ យេវ វិចរតិ ។

លំដាប់នេះ សូមវិសជ្ជនាក្នុងកម្មបច្ច័យ អធិប្បាយនូវឧបត្ថម្ភកកម្មតទៅ ដំណើរសេចក្ដីថា យំ ឧបត្ថម្ភេតីតិ ឧបត្ថម្ភំ ឧបត្ថម្ភំឯវ ឧបត្ថម្ភកំ កម្មឯណា ជាកម្មទំនុកបំរុងនូវកម្មដែលកំពុងតែឲ្យផល កម្មនោះឈ្មោះថា ឧបត្ថម្ភកកម្ម ។

ឧបត្ថម្ភកកម្មនោះ លោកអាចារ្យកំណត់យកទាំងខាងកុសលទាំងខាងអកុសល គឺកម្មជាកុសលក៏ទំនុកបម្រុងកម្មដ៏ជាកុសល កម្មជាអកុសលក៏ទំនុកបម្រុងកម្មដ៏ជាអកុសល ។ ឯកច្ចោ ហិ កុសលំ កត្វា មែនពិត បុគ្គលពួកខ្លះក្នុងលោកនេះ ធ្វើកងការកុសលក្នុង

លោកនេះហើយ លុះអស់ជីវិត បានទៅកើតក្នុងសុគតិភព កាលទៅក្នុងសុគតិភពនោះ ក៏ធ្វើនូវការកុសលតទៅខាងមុខ ៗ ទៀត ទំនុកបម្រុងនូវកម្មនោះ នៅក្នុងសុគតិភព អស់រយឆ្នាំ ពាន់ឆ្នាំ សែនឆ្នាំជាច្រើន ៗ បុគ្គលពួកខ្លះធ្វើអកុសលកម្ម ជាបាបក្នុងលោកនេះ លុះអស់ជីវិត ទៅកើតក្នុងទុគ្គតិភព កាលនៅក្នុងទុគ្គតិភពនោះ ធ្វើអកុសលនោះរឿយ ៗ ទំនុកបម្រុងនូវអកុសលកម្មនោះ នៅក្នុងទុគ្គតិភព អស់កាលដ៏យូរអង្វែងប្រមាណដោយសែនឆ្នាំជាច្រើន ៗ

អបរោ ឆយោ ន័យដទៃទៀតថា ជនកកម្មរមែងញុំាងវិបាកខន្ធនិងកម្មជរូបឲ្យកើតក្នុងបដិសន្ធិកាលនិងបវត្តិកាល ៗ ឯឧបត្ថម្ភកកម្មនេះ មិនអាចញុំាងវិបាកខន្ធនិងកម្មជរូបឲ្យកើតក្នុងបដិសន្ធិកាល និង បវត្តិកាលបានទេ អញ្ញោច និស្សាយ កម្មដទៃឲ្យបដិសន្ធិ ហើយឧបត្ថម្ភកកម្មខាងកុសល ក៏ទំនុកបម្រុងឲ្យបុគ្គលដែលមានសុខស្រាប់ហើយ ដែលមានទ្រព្យស្រាប់ហើយ ឲ្យបានសេចក្តីសុខច្រើនឡើងទៅទៀត ឲ្យគេតែមានទ្រព្យបរិបូណ៌ច្រើនឡើងទៅទៀត ៗ ចំណែកឧបត្ថម្ភកកម្មខាងអកុសលវិញ គឺបុគ្គលដែលជាអ្នកកំសត់ទុគ៌តមានទុក្ខលំបាកស្រាប់ហើយ ក៏ទំនុកបម្រុងឲ្យបានសេចក្តីកំសត់ទុគ៌ត មានទុក្ខលំបាករឹតតែច្រើនឡើងពល់ពេលវេលា ៗ

កុសលកម្ម ទំនុកបម្រុងមនុស្សឲ្យបានទ្រព្យ ឲ្យបានសេចក្តីសុខច្រើន

ឡើងទៅនោះ ដូចជាព្រះបាទអឌ្ឍមាសករាជ កាលដើមឡើយ ជាអ្នកកំសត់ទុគ៌តអនាថា ឥតញាតិសន្តាន មានទ្រព្យតែកន្លះមាសកប៉ុណ្ណោះ កុសលកម្មក៏ឧបត្ថម្ភឲ្យបានជាព្រះមហាក្សត្រ ក្នុងនគរពារាណសី ។

## រឿងព្រះបាទអឌ្ឍមាសករាជ

អតីតេ ពារាណសិយំ ក្នុងអតីតកាល មានបុរសម្នាក់ជាមនុស្សកំសត់ទុគ៌ត នៅក្នុងនគរពារាណសី សង់ផ្ទះនៅក្បែរទ្វារនគរខាងទិសឧត្តរ ធ្វើការស៊ីឈ្នួលដងទឹកចិញ្ចឹមជីវិតជានិច្ចកាល លុះយូរមក បានទ្រព្យកន្លះមាសក ទើបយកទៅកប់លាក់ទុកក្នុងចន្លោះឥដ្ឋ ដែលគេលើកថ្នល់ ហើយស៊ីឈ្នួលដងទឹកតទៅទៀត រហូតដល់ទ្វារនគរទិសខាងត្បូង ៗ ខាងក្រោយមក បានស្រីកំសត់ទុគ៌តម្នាក់ធ្វើជាភរិយា នាងនេះមានទ្រព្យកន្លះមាសកដូចគ្នា ។

គ្រានោះ ព្រះបាទពារាណសីឲ្យបាវ៉ីគងប្រកាសប្រាប់អ្នកនគរឲ្យនាំគ្នាលេងមហោស្រព បើអ្នកណាមិនព្រមលេងទេ អ្នកនោះនឹងមានទោស ។ ស្វាមីភរិយាប្រឹក្សាគ្នាថា ទ្រព្យរបស់យើងមានកន្លះមាសកម្នាក់ រួមគ្នាបានជាមួយមាសក មួយភាគនឹងទិញកម្រងផ្កាគ្រឿងក្រអូប មួយភាគទៀតនឹងទិញសុរាមេរ័យ មច្ឆមំសាហារ ដើម្បីឲ្យបានលេងមហោស្រពតាមបង្គាប់ អ្នកចូរទៅកាយយកទ្រព្យរបស់អ្នកមក ។ ស្វាមីបានឮភរិយាប្រាប់ដូច្នោះ ត្រេកអរណាស់ ក៏ម្នីម្នាទៅយកទ្រព្យដែលខ្លួនកប់

លាក់ខ្លួនក្នុងបន្ទោះផ្ទៃ នៅក្បែរទ្វារខាងទិសខាងកើត បម្លាយប្រមាណ ១២ យោជន៍ ទៅដល់ពាក់កណ្ដាលផ្លូវ ជួនពេលថ្ងៃត្រង់ រស្មីព្រះអាទិត្យក្ដៅដូចរងើកភ្លើង ផ្ទៃប្រថពី ដូចជាគេកាយដំរូវខ្សាច់ ហើយដូចអណ្ដាតភ្លើង បុរសកំសត់ទុគ៌តដើរជាន់ខ្សាច់ក្ដៅទៅ មិនក្រៀមមុខសោះ ស្រែកច្រៀងបណ្ដើរដើរបណ្ដើរ រហូតដល់មុខព្រះលាន ។

តទា ឧទយោ គ្រានោះ ព្រះបាទឧទ័យរាជ ស្ដេចឈរជិតសីហបញ្ជរ ទតទៅឃើញបុរសកំសត់ទុគ៌ត ស្រែកច្រៀងដើរទៅតាមមុខព្រះលានដូច្នោះ ទ្រង់ទតឆ្ងល់ ក៏ឲ្យរាជបុរសទៅហៅបុរសនោះចូលមកគាល់ ហើយត្រាស់សួរថា ត្វំ កុតោ អាគតោ អ្នកមកពីណា នឹងទៅឯណា ក្នុងពេលរស្មីព្រះអាទិត្យកំពុងតែក្ដៅខ្លាំងដូចជាអណ្ដាតភ្លើង អ្នកដើរស្រែកច្រៀងហាក់ដូចជាឥតក្ដៅសោះ យើងមានសេចក្ដីសង្ស័យណាស់ អ្នកចូរប្រាប់យើងឲ្យច្បាស់ កុំលាក់លៀមឡើយ ។

បុរសកំសត់ក្រាបទូលថា មហារាជ បពិត្រក្សត្រប្រសើរ រស្មីព្រះអាទិត្យដ៏ក្ដៅនេះ មិនមែនក្ដៅក្រៃលែងខ្លាំងជាងរស្មីនៃកំដៅ ព្រោះរាគៈទេ ខ្ញុំព្រះអង្គនឹងទៅយកទ្រព្យមកផ្សំជាមួយភរិយា ។

ព្រះបាទពារាណសី បានទ្រង់ព្រះសណ្ដាប់ដូច្នោះ ក៏ត្រេកអរ ទើបបែងចែកសម្បត្តិចេញពាក់កណ្ដាល ព្រះរាជទានទូវទីជាសម្លាញ់របស់ព្រះអង្គ តម្រង់រាជាណាចក្រជាមួយគ្នា ហើយទ្រង់ឲ្យនាំយកស្រីកំសត់ជា

ភរិយានោះមកតាំងជាអគ្គមហេសី ទ្រង់ឲ្យប្រកាសប្រាប់អ្នកនគរថា ឥឡូវនេះ ក្សត្រសោយរាជសម្បត្តិពីព្រះអង្គរមគ្គា អង្គថ្មីទ្រង់ព្រះនាមថា ព្រះបាទអឌ្ឍមាសករាជ ។

បុរសកំសត់ បានសិរីរាជសម្បត្តិដូច្នេះ ដោយអំណាចឧបត្ថម្ភកកម្មមកទំនុកបម្រុងឲ្យបានទ្រព្យសម្បត្តិទឹងឲ្យបានជាព្រះមហាក្សត្រគ្រប់គ្រងរាជ្យពាក់កណ្ដាល ។ សេចក្ដីនេះ មានក្នុងអដ្ឋកនិបាត កុទ្ទសាលជាតក លើកមកសំដែងឲ្យឃើញជាឧទាហរណ៍ នៃឧបត្ថម្ភកកម្មខាងកុសល ។

ន័យមួយទៀត ឧបត្ថម្ភកកម្មនោះរមែងទំនុកបម្រុងនូវសុខនឹងទុក្ខដែលកម្មដទៃឲ្យផល គឺខាងកុសលឲ្យផលជាសុខរួចហើយ ក៏ឲ្យបានសុខរឹតតែច្រើនឡើងទៅទៀត ខាងអកុសលឲ្យផលជាទុក្ខរួចហើយ ក៏ឲ្យបានទុក្ខរឹតតែច្រើនឡើងទៅទៀត ។

ឧបត្ថម្ភកកម្មខាងកុសលតាមឧបត្ថម្ភ គឺធ្វើឲ្យអន្តរាយវិនាសបាត់បង់ទៅ ញុំាងសម្បត្តិឲ្យកើតបរិបូណ៌ឡើង សម្បត្តិមិនទាន់បានក៏ជួយឲ្យបានហើយជួយឲ្យរឹតតែចំរើនច្រើន ៗ ឡើងទៅទៀត ចាប់ដើមអំពីជាទារកនៅក្នុងគភ៌មាតា តាមទំនុកបម្រុងមិនឲ្យទុក្ខកើតឡើងបាន អន្តរាយទាំង-ឡាយធ្លាប់មានដល់មាតាបិតាជាប្រក្រតី អន្តរាយទាំងនោះក៏ប្រាសចាកទៅរហូតដល់ទាសកម្មករ អ្នកបម្រើក្នុងផ្ទះនោះ ក៏ប្រាសចាកអន្តរាយដែរយ៉ាងនេះឈ្មោះថាឧបត្ថម្ភកកម្មញុំាងអន្តរាយទាំងឡាយឲ្យវិនាសអស់ទៅ

ឧបត្ថម្ភកកម្មញុំាងសម្បត្តិឲ្យមានបរិបូណ៌នោះ គឺចាប់ដើមអំពីទារក មកកើតក្នុងគភ៌មាតា សម្បត្តិក្នុងផ្ទះនោះកើតបរិបូណ៌ទឹងកប់ប្រមាណមិន បាន ដិជិតាកុម្ភិយោ កំណប់ទ្រព្យកើតខាងក្រោយផ្ទះ ខាងមុខផ្ទះ ដូចទឹកហូរ បើនឹកចង់បរិភោគភោជនាហារឬចង់ស្លៀកពាក់តាក់តែងខ្លួនដោយវត្ថុអ្វី ៗ ក៏មានគេនាំយកមកឲ្យ សម្មុខីភាវំ គច្ឆតិ មាតាបិតានៃទារកនោះ ទ្រព្យអ្នកដទៃកប់ទុកក្នុងទីណា ៗ ក៏មកកាន់ទីចំពោះមុខ បានឃើញទ្រព្យនោះ ធេនុយោ មេគោដែលចិញ្ចឹមក៏មានទឹកដោះច្រើន ឲ្យទឹកដោះគ្រប់ពេល មិនដាច់ គោទាំងឡាយ ក៏ប្រាសចាករោគឧបទ្ទពកាយ ៗ សស្សានិ សម្បជ្ជន្តិ សន្ទូងទាំងឡាយដែលបុគ្គលសាបព្រោះក្នុងស្រែ ក៏ដុះលូតលាស់បរិបូណ៌ ទ្រព្យដែលបុគ្គលទាំងឡាយមកខ្ចីយកទៅ ក៏គេយកមកសងវិញតាមធម្មតា មិនបាច់ទៅសួរនាំទាមទារខ្លួនឯងឡើយ ទឹងទាសកម្មករអ្នកបម្រើក៏ងាយស្ដីប្រដៅតែងធ្វើតាមវាចា កម្មន្តា ន អបរិហាយន្តិ ការងារមិនបានសាបសូន្យ គឺជាអ្នកធ្វើការមិនខ្ជិលច្រអូស មិនបាច់រំឭកដាស់តឿនស្ដីថា បរិហារំ លភតិ ចាប់ដើមអំពីទារកចុះកាន់ផ្ទៃមាតា ក៏បានថ្នាំជាគ្រឿងរក្សាគភ៌រហូតដល់ប្រសូតចេញពីគភ៌ ៗ កុមារពេទ្យ ពួកគ្រូកុមារទាំងឡាយ មកប្រជុំគ្នាជួយថែរក្សាព្យាបាល លុះដល់ចំរើនវ័យធំឡើង បើកើតក្នុងត្រកូលគហបតីក៏បានធ្វើជាសេដ្ឋី បើកើតក្នុងត្រកូលអមាត្យ ក៏បានធ្វើជាសេនាបតី ៗ ឧបត្ថ

កកម្មយ៉ាងនេះ ឈ្មោះថាទំនុកបម្រុងឲ្យនូវភោគសម្បត្តិ ញុំាងភោគសម្បត្តិឲ្យកើតឡើង អបរិស្សយោ បុគ្គលនោះពុំមានអន្តរាយឡើយ ដោយសម្បត្តិបរិបូណ៌ដរាបដល់អស់ជីវិត យ៉ាងនេះឈ្មោះថាឧបត្ថម្ភកកម្មខាងកុសល បានដល់បុគ្គលដែលកុសលទំនុកបម្រុង ដូចព្រះបាទអន្លមាសកកាជ ដែលកុសលទំនុកបម្រុងឲ្យបានទ្រព្យជាច្រើន រហូតដល់បានសោយរាជសម្បត្តិក្នុងនគរពារាណសីពាក់កណ្ដាល ដូចវិសជ្ជនាមកខាងដើម ។

ឯឧបត្ថម្ភកកម្មខាងអកុសលវិញ គឺអកុសលកម្មទំនុកបម្រុងតាំងពីចុះចាប់ផ្ទៃមាតាប៉ុ ។ រមែងញុំាងអន្តរាយឲ្យកើតមានឡើងតាំងពីទារកនោះចុះចាប់ផ្ទៃរក្សាម ។ មាតាបិតានៃទារកនោះ រេះតែមានទុក្ខព្រួយលំបាកពុំមានសេចក្ដីសុខឡើយ ៈយ បរិស្សយា អន្តរាយទាំងឡាយណាដែលកើតមានហើយរឹតតែចំរើនច្រើនឡើងថែមទៀត អន្តរាយណាមិនធ្លាប់កើតមាន ក៏ទៅជាកើតមាន ។ ឧបត្ថម្ភកកម្មយ៉ាងនេះ ឈ្មោះថាឧបត្ថម្ភកកម្មខាងអកុសល ញុំាងអន្តរាយឲ្យកើតមាន ញុំាងភោគសម្បត្តិឲ្យវិនាសទៅ គឺថាចាប់ដើមអំពីទារកមកកើតក្នុងផ្ទៃមាតា មាតាបិតានោះធ្លាប់មានទ្រព្យច្រើន ទ្រព្យនោះក៏អស់ទៅសូន្យទៅ ជួនកាលមានភ្លើងឆេះផ្ទះ ជួនកាលត្រូវរាជភ័យ បេះចេញទៅជួញទូកលិចរេឆនុយោ មេគោដែលចិញ្ចឹម គ្មានទឹកដោះ គោដែលចិញ្ចឹមធ្លាប់បាន

សុខ ត្រឡប់ទៅជាបានទុក្ខវិញ គឺមានភេទផ្សេង ៗ កើតឡើងដល់គោ ទាំងនោះ ។ វិប្បដ្ឋានេ ឥ សស្សាធិ សត្វទាំងឡាយក្នុងទីសោប ព្រោះតែវិនាសខូចខាត ជនទាំងឡាយមានទាសាទាសីជាដើម ធ្លាប់ស្តី ប្រដៅងាយ ក៏ត្រឡប់ទៅជាលំបាកស្តីប្រដៅវិញ មិនស្ថិតនៅក្នុងឱវាទ ការងារគេ សាបសូន្យខកខានធ្វើ បរិហារំ ឍ លភតិ តាំងពីពេល ទារកមកកើតក្នុងផ្ទៃមាតា ពេះតែមានស្អប់ខ្ពើមមាតាបិតា ចាំសម្រាប់ រក្សាគភ៌គឺគេមិនបាន ។ កោមារការវេជ្ជោ កុមារពេទ្យទាំងឡាយ គ្មានចិត្តត្រេកអរជួយថែរក្សា ។ បើទារកនោះកើតក្នុងត្រកូលសេដ្ឋី ទ្រព្យ ដែលមានទាំងប៉ុន្មាន ក៏អន្តរធានអស់ ធ្លាក់ខ្លួនទៅជាអ្នកកំសត់ទុគ៌ត អនាថា ។ បើទារកនោះកើតក្នុងត្រកូលអមាត្យ ក៏ត្រូវទោសនិរទេស បណ្តេញចេញពីនគរ ព្រោះហេតុព្រះមហាក្សត្រទ្រង់មានព្រះរាជបញ្ជា ឲ្យបណ្តេញចេញ ។ យ៉ាងនេះឈ្មោះថាឧបត្ថម្ភកកម្មខាងអកុសល ។

បុគ្គលដែលមានឧបត្ថម្ភកកម្មខាងអកុសលផ្តល់ផ្តន្ទាទោសឲ្យរឹតតែ វិនាសអន្តរធានច្រើន ៗ ទៅទៀតនោះ មកពីទោសនៃខ្លួនគ្មានចិត្តមេត្តា មិនធ្វើទាន នឹងប្រទូសរាយដល់អ្នកមិនប្រទូសរាយ សមតាមរឿងអតីតនិទានមានក្នុងព្រះសុត្តន្តបិដកដូចតទៅនេះ៖

(នៅមានត)

# ទ្វាទសកម្មកថា

ព្រះមុនីកោសល ស្វរ-ហាយ

អធិបតីរង នៃក្រុមជំនុំព្រះត្រៃបិដក តែងរៀបរៀង

---

## ទ្វាទសកម្មកថា

សម្ដែងអំពីកម្ម ១២ យ៉ាង

### កម្មពួកទី ១ ឲ្យផលតាមគ្រា

១– ទិដ្ឋធម្មវេទនីយកម្ម កម្មឲ្យផលក្នុងបច្ចុប្បន្ន ។

២– ឧបបជ្ជវេទនីយកម្ម កម្មឲ្យផលក្នុងជាតិជាបន្ទាប់ ។

៣– អបរាបរវេទនីយកម្ម កម្មឲ្យផលក្នុងជាតិតៗទៅ ។

៤– អហោសិកម្ម កម្មដែលគ្រិនផលអស់ហើយ ។

### កម្មពួកទី ២ ឲ្យផលតាមកិច្ច

៥– ជនកកម្ម កម្មញុំាងសត្វឲ្យកើត ។

៦– ឧបត្ថម្ភកកម្ម កម្មដែលជួយជ្រោមជ្រែង ។

៧– ឧបបីឡកកម្ម កម្មដែលបៀតបៀន ។

៨– ឧបឃាតកកម្ម កម្មដែលផ្ដាច់ផ្ដិល ។

### ពួកកម្មទី ៣ ឲ្យផលតាមលំដាប់

៩– គរុកកម្ម កម្មធ្ងន់ ។

១០– ពហុលកម្ម     កម្មដែលសន្សំច្រើន ។

១១– អាសន្នកម្ម     កម្មដែលធ្វើក្នុងវេលាជិតស្លាប់ ។

១២– កដត្តាកម្ម     កម្មដែលគ្រាន់តែធ្វើឥតចេតនា ។

កម្ម ១២ យ៉ាងនេះ មាន ៣ ពួក គឺកម្មពួកទី ១ ឲ្យផលតាមគ្រា កម្មពួកទី ២ ឲ្យផលតាមកិច្ច កម្មពួកទី ៣ ឲ្យផលតាមលំដាប់ ។

ពាក្យថា « ឲ្យផលតាមគ្រា » សំដៅយកផលរបស់កម្ម ទោះបីជាកុសល ឬជាអកុសល ដែលបុគ្គលធ្វើហើយ កម្មនោះរមែងឲ្យផលឃើញជាក់ច្បាស់ តាមសមគួរក្នុងវេលា ឬក្នុងខណៈមិនយូរប៉ុន្មាន បន្ទាប់អំពីកាលនៃជាតិដែលខ្លួនធ្វើមក ។

ពាក្យថា « ឲ្យផលតាមកិច្ច » សំដៅយកផលរបស់កិច្ចការ គឺថា កិច្ចធំ ឬតូច ធ្ងន់ ឬស្រាល ក៏រមែងកើតផលតាមកម្លាំង នៃកិច្ចដែលបុគ្គលធ្វើ ។

ពាក្យថា « ឲ្យផលតាមលំដាប់ » សំដៅយកផលរបស់កម្មដែលបុគ្គលធ្វើ ជាផលដែលត្រូវឲ្យក្នុងកាលជាលំដាប់នៃជាតិ របស់បុគ្គលអ្នកធ្វើ ដូចជាអ្នកធ្វើអំពើជាកុសល ឬអកុសលក្នុងជាតិនេះ នឹងត្រូវទទួលផលក្នុងជាតិជាលំដាប់ ៗ តទៅអនាគត ។

# អធិប្បាយពង្រីកសេចក្តី

១- ទិដ្ឋធម្មវេទនីយកម្ម កម្មនេះ លោកកំណត់យកទាំងកុសលទាំងអកុសល ជាកម្មដែលកើតក្នុងបឋមជវន៍ មានកម្លាំងក្លៀវក្លាជាងជវន៍ទី ២ អាចឲ្យផលក្នុងបច្ចុប្បន្ន គឺកុសលកម្មដែលបុគ្គលធ្វើក្នុងជាតិនេះ ឲ្យផលសម្រេចក្នុងជាតិនេះ អកុសលកម្មដែលបុគ្គលធ្វើក្នុងជាតិនេះ ក៏ឲ្យផលសម្រេចក្នុងជាតិនេះ ។ ការធ្វើបុណ្យឬធ្វើបាបដែលអាចឲ្យផលក្នុងបច្ចុប្បន្ននោះ អាស្រ័យកម្លាំងរបស់ជវនចិត្ត បើជវនចិត្តជាកុសល ក៏ឲ្យសម្រេចការជាបុណ្យ បើជវនចិត្តជាអកុសល ក៏ឲ្យសម្រេចការបាប ។ ផលរបស់កម្មនោះ ក៏បញ្ចេញឲ្យឃើញជាក់ច្បាស់ដោយអំណាចកម្លាំងនៃជវនចិត្ត ក្នុងកាលដែលធ្វើ ព្រោះថា កុសលនិងអកុសលទាំងអស់ កាលដែលបុគ្គលធ្វើ សុទ្ធតែប្រកបដោយជវនចិត្តដែលមានកម្លាំងក្លៀវក្លា ឬទន់ខ្សោយជាដរាប បើកម្មប្រកបដោយជវនចិត្តខ្លាំងក្លា ឲ្យផលក្នុងបច្ចុប្បន្នជាតិនេះ កាលបើកម្មដទៃ មិនអាចឲ្យផលបានទេ ក៏ក្លាយទៅជាអហោសិកម្ម ជាកម្មគ្មានផលអស់ហើយ ជាកម្មលែងមានផល ដែលត្រូវឲ្យក្នុងបច្ចុប្បន្ន និងអនាគតទៀតហើយ ។ ទិដ្ឋធម្មវេទនីយកម្ម នេះ មានទំនាងប្រៀបដូចជាព្រានម្រឹគ ដែលលបលាក់ខ្លួនចាំបាញ់ម្រឹគ កាលបើឃើញម្រឹគមកដល់ ខ្លួនក៏យកធ្នូបាញ់ទៅម្រឹគនោះ ព្រួញដែលព្រានបាញ់ទៅនោះ បើត្រូវម្រឹគបានដូចបំណង ព្រានម្រឹគ

ក៏ផ្លាស់កន្ទ្រង់អគ្គិយនោះចេញ ហើយយកម្រឹគនោះមកពន្លាត់ស្បែកអារសាច់ យកទៅចំអិនបរិភោគ ។ បើនាយព្រានបាញ់ម្រឹគមិនត្រូវ ព្រោះហេតុម្រឹគនោះដឹងខ្លួន គេចរត់បាត់ទៅ សេចក្ដីនេះយ៉ាងណាមិញ នាយព្រានម្រឹគនោះ បុគ្គលគប្បីយល់ថា ដូចជា ទិដ្ឋធម្មវេទនីយកម្ម សត្វម្រឹគដូចជាផលនៃទិដ្ឋធម្មវេទនីយកម្ម កាលព្រានបាញ់ត្រូវម្រឹគបានដូចបំណង ប្រៀបដូចជាកម្មឲ្យផលក្នុងជាតិនេះ កាលបើព្រានបាញ់ម្រឹគមិនត្រូវ ម្រឹគផ្អើលរត់គេចបាត់ទៅ ប្រៀបដូចជាកម្មដទៃពុំអាចជ្រៀតជ្រែកឲ្យផលក្នុងបច្ចុប្បន្នបាន កម្មនោះក៏ទៅជា អហោសិកម្ម ។

២-- ឧបបជ្ជវេទនីយកម្ម កម្មឲ្យផលក្នុងជាតិជាបន្ទាប់ ៗ កុសលកម្ម ឬអកុសលកម្ម ដែលកើតឡើងដោយសត្តមជវន (ជវនទី ៧)ជាកម្មឲ្យផលក្នុងជាតិជាបន្ទាប់អំពីជាតិរបស់បុគ្គល ដែលប្រព្រឹត្តធ្វើ ។ ឧបបជ្ជវេទនីយកម្ម នេះ បើជាផ្នែកខាងកុសល បានដល់សមាបត្តិ ៨ ប្រការ គឺរូបសមាបត្តិ ៤ អរូបសមាបត្តិ ៤ ។ បើជាផ្នែកខាងអកុសល បានដល់អនន្តរិយកម្ម ៥ ប្រការ ។ យោគាវចរកុលបុត្រ អ្នកចំរើនឈានស្ទាត់ជំនាញ ក្នុងរូបជ្ឈាន លុះច្យុតចាកអត្តភាពនេះ ក៏ទៅកើតក្នុងព្រហ្មលោក ដោយកម្លាំងសមាបត្តិណាមួយដែលឲ្យផលបានមុន ឯសមាបត្តិទាំង ៧ នោះ ក៏ទៅជាអហោសិកម្ម ផ្អាកការឲ្យផលទៀត ចំណែកខាង

អនន្តរិយកម្មទាំង ៤ ក៏ដូចគ្នា បើបុគ្គលណា ធ្វើអនន្តរិយកម្មទាំង ៤ បុគ្គលនោះត្រូវទទួលផលអនន្តរិយកម្មណាមួយ ដែលគាត់តែងឲ្យបដិសន្ធិបានមុន ឯអនន្តរិយកម្មទាំង ៤ នោះ ក៏ទៅជាអហោសិកម្ម ។

២ ឧបបជ្ជវេទនីយកម្ម នេះ ជាកម្មដែលត្រូវឲ្យផលក្នុងជាតិទី ២ ដូចយ៉ាងស្ដេចអជាតសត្រូវ ជឿស្ដាប់ពាក្យភិក្ខុទេវទត្ត ធ្វើអំពើបិតុឃាត ចំពោះព្រះរាជបិតារបស់ខ្លួន លុះស្ដេចអជាតសត្រូវ ដល់នូវមរណភាព ក៏ទៅកើតក្នុងនរក រងទុក្ខវេទនាអស់កាលយូរ ក្នុងជាតិជាបន្ទាប់ គឺជាតិជាគំរប់ពីរ អំពីជាតិជាបច្ចុប្បន្នរបស់ខ្លួន ។

៣– អបរាបរវេទនីយកម្ម កម្មឲ្យផលក្នុងជាតិត ៗ ទៅ កម្មនេះកើតឡើងក្នុងវេលាដែលសមគួរ ក្នុងចន្លោះនៃជវនទាំងពីរ គឺបឋមជវន និងសត្តមជវន កម្មនេះមិនទៅជាអហោសិកម្មទេ តែងជាប់តាមបុគ្គលអ្នកធ្វើតរៀងទៅ បើបុគ្គលនោះមិនទាន់បានសម្រេចអរហត្ត ដរាបណា កម្មនេះក៏តាមឲ្យផលដរាបនោះ រាប់តាំងអំពី ១០ ជាតិ រយជាតិជាដើមឡើងទៅ កាលបើបានឱកាស ក្នុងកាលណា ក៏ឲ្យផលក្នុងកាលនោះ ។ អបរាបរវេទនីយកម្ម នេះ បុគ្គលតប្រៀបដោយពាក្យឧបមា ដូចព្រានសុនខ ។

ធម្មតាសុនខដែលព្រានពន្យុះ ឲ្យដេញម្រឹគនោះ សុនខក៏ស្ទុះបោលទៅស្កាត់ខាងស្ដាំខ្លះ ខាងឆ្វេងខ្លះ ដេញតាមទៅ ទាល់តែកាល

ណាដេញតាមទាន់ក៏ខាំម្រឹគ ក្នុងកាលនោះ មិនអាចលែងវិញទេ ៗ សុនខដែលប្រឹងៈបាលដេញតាមខាំម្រឹគទាល់តែខាំបាន យ៉ាងណាមិញ អបរាបរវេទនីយកម្ម ក៏ជាប់តាមសត្វដែលត្រាច់រង្គាត់ចាប់កំណើត គឺក្នុងកំណើតទាំង ៤ ក្នុងគតិទាំង ៥ ក្នុងវិញ្ញាណដ្ឋិតិទាំង ៧ ក៏យ៉ាងនោះដែរ ៗ ពួកសត្វទាំងអស់ មិនអាចនឹងគេចចេញអំពីអបរាបរវេទនីយកម្ម នោះបានឡើយ បើទុកជាទៅពួនក្នុងមហាសមុទ្រក្តី ក្នុងចន្លោះភ្នំក្តី បិតនៅឰដ៏អាកាសក្តី ក៏មិនរួចអំពីអបរាបរវេទនិយកម្ម ក្នុងកាលណាមួយទេ ៗ កម្មដែលសត្វបានធ្វើនោះ ទោះជាកុសលកម្ម ឬអកុសលកម្ម ឈ្មោះថាជាកម្មរបស់ខ្លួនដោយពិត មិនមែនអន្តកយទៅអំពីសត្វដែលជាអ្នកធ្វើនោះទេ លោកប្រៀបដូចជាស្រមោល ដែលជារូបធាតុតែងអន្ទោលទៅតាមប្រាណ ៗ ការធ្វើប្រកបដោយសុចរិត ក៏រមែងឲ្យផលជាសុខសួស្តីជាប់តាមខ្លួន ការធ្វើប្រកបដោយទុច្ចរិត ក៏រមែងឲ្យផលជាទុក្ខភ័យជាប់តាមខ្លួនទៅ ៗ ព្រោះហេតុនោះ បុគ្គលអ្នកមានប្រាជ្ញា ប្រាថ្នាសេចក្តីសុខដើម្បីខ្លួន គប្បីបំពេញនូវកុសលកម្ម គប្បីប្រព្រឹត្តធម៌ជាសុចរិតគ្រប់ត្រៃទ្វារ គប្បីលះបង់អកុសលកម្ម វៀរចាកការប្រព្រឹត្តទុច្ចរិត ៗ

៤– អហោសិកម្ម កម្មដែលគ្មានផលអស់ហើយ បានដល់កម្មនោះជាកុសល ឬអកុសល ដែលកន្លងកាលផុតទៅ មិនអាចឲ្យផលជាកម្មឲ្យផលមិនកើត ដោយហេតុកម្មទាំង ៣ ខាងដើម ជៀតជ្រែកឲ្យ

ផានមុន ព្រោះហេតុនោះ អហោសិកម្ម នេះ ឈ្មោះថាជាកម្មមិនឲ្យផល ទៅវិញ លោកប្រៀបដូចជាផ្លែរុក្ខជាតិ មានផ្លែដូចជាដើម ដែលខូចពីជៈ សម្រាប់ដុះអស់ហើយ មិនអាចនឹងដុះលូតលាស់ឡើងបាន ។

៥– ជនកកម្ម កម្មញុំាងសត្វឲ្យកើត ។ កម្មនេះនៅក្នុងពួក កម្មឲ្យផលតាមកិច្ច បានដល់កុសលកម្ម នឹងអកុសលកម្ម ដែលញុំាងសត្វ ឲ្យកើតក្នុងបដិសន្ធិកាល កម្មនេះ ឲ្យផលចំពោះតែក្នុងបដិសន្ធិកាល ប៉ុណ្ណោះ ។ កម្មដែលឲ្យផលតាមនាទីដូច្នេះ លោកហៅថា ជនកកម្ម បណ្ឌិតគប្បីសន្និដ្ឋានថា កុសលកម្ម ឬអកុសលកម្ម ដែលឲ្យផលក្នុងបវត្តិ កាល បន្ទាប់អំពីបដិសន្ធិកាលនោះ គឺជាកម្មដទៃដោយឡែក មិនមែន ជាជនកកម្មឡើយ ប្រៀបដូចជា មាតាគ្រាន់តែជាអ្នកបង្កើតបុត្រប៉ុណ្ណោះ ឯគ្រឿងការចិញ្ចឹមថែរក្សានោះ ជាភ្នាក់ងាររបស់មេនំ សេចក្ដីនេះយ៉ាងណា ជនកកម្ម គ្រាន់តែជាភ្នាក់ងារក្នុងការណែនាំបដិសន្ធិឲ្យកើត បន្ទាប់មក ទើបមានឧបត្ថម្ភកកម្ម ទទួលការបន្តមកទៀត ក៏យ៉ាងនោះដែរ ។

៦– ឧបត្ថម្ភកកម្ម កម្មដែលជួយជ្រោមជ្រែង បានដល់កុសលនឹងអកុសល ដែលជាប់តាមទំនុកបំរុងគាំពារក្នុងបវត្តិកាល ។ ឧបត្ថម្ភកកម្ម នេះ បណ្ឌិតគប្បីយល់ថា ជាកុសលក៏មាន អកុសលក៏ មាន ប៉ុន្តែមតិនៃអ្នកប្រាជ្ញខ្លះថា ឧបត្ថម្ភកកម្ម នេះជាកុសលសុទ្ធ មិន

កាប់យកអកុសលឡើយ ។ ក្នុងបករណៈវិសុទ្ធិមគ្គ និងគម្ពីរ មនោរថបូរណី ថា ឧបត្ថម្ភកកម្ម បានដល់កម្មទាំងកុសល ទាំងអកុសល មិនសំដៅយកចំពោះកុសលតែម៉្យាងទេ ដូចបុគ្គលពួកខ្លះ ធ្វើការកុសលណាមួយ លុះដល់ធ្វើមរណកាល ក៏ទៅកើតក្នុងសុគតិភព លុះបានទៅក្នុងសុគតិភពនោះ ក៏ខំប្រឹងប្រែងធ្វើកុសលរឿយ ៗ កុសលកម្មរបស់បុគ្គលនោះឈ្មោះថាជាឧបត្ថម្ភកកម្ម ជាបច្ច័យជួយជ្រោមជ្រែងឲ្យបុគ្គលនោះ បានទទួលផលជាសុខ អស់កាលដ៏វែង បន្តទៅទៀតនេះឈ្មោះថា ឧបត្ថម្ភកកម្ម ជាកុសល ។ បុគ្គលខ្លះធ្វើអកុសលកម្មផ្សេង ៗ លុះធ្វើមរណកាល ក៏ទៅកើតក្នុងទុគ្គតិភពនោះ ក៏ធ្វើបាបកម្មណាមួយថែមទៀត បុគ្គលនោះក៏បានទទួលទុក្ខវេទនាក្នុងភពនោះ អស់កាលយូរតទៅទៀត នេះឈ្មោះថា ឧបត្ថម្ភកកម្ម ជាអកុសល ។

ឧបត្ថម្ភកកម្ម នេះ មានសេចក្ដីផ្សេងគ្នា សូមឲ្យលោកអ្នកឈ្លាសវៃ ត្រិះរិះពិចារណា យកសេចក្ដីតាមគាប់ចិត្តចុះ ។

៧- ឧបបីឡកកម្ម កម្មដែលបៀតបៀន បានដល់កម្មទាំងកុសល ទាំងអកុសល ដែលសម្រេចកិច្ចបៀតបៀន នូវផលរបស់កម្មដទៃ ដូចយ៉ាងកុសលកម្មកំពុងឲ្យផលក្នុងកាលណាមួយ ក៏ស្រាប់តែមានអកុសលកម្មមកជ្រៀតជ្រែក បៀតបៀន នូវផលរបស់កុសលកម្មនោះ។ ឧបបីឡ

កកម្ម រមែងជាប់តាមបៀតបៀនញាំញីនូវសុខទុក្ខ មិនឲ្យសុខទុក្ខកើតឡើង ជិតនៅអស់កាលយូរបាន ។

ឧបបីឡកកម្ម នេះ បើខាងកុសលកំពុងឲ្យផល រមែងតែមានអកុសល ជាឧបបីឡកកម្ម បើខាងអកុសលកំពុងឲ្យផល រមែងតែមានកុសលជាឧបបីឡកកម្ម គឺជាកុសលកម្ម បៀតបៀនឃាត់ហាមនូវអកុសល មិនឲ្យមានឱកាសឲ្យផលបាន អកុសលកម្មក៏បៀតបៀនឃាត់ហាមនូវកុសល មិនឲ្យមានឱកាសឲ្យផលបានវិញដែរ មួយទៀត កុសលកម្ម ជាឧបបីឡកកម្មរបស់អកុសល ទើបឯអកុសលកម្ម ជាឧបបីឡកកម្មរបស់កុសលវិញដែរ ។

៨- ឧបឃាតកម្ម កម្មដែលផ្តាច់ផ្តិល បានដល់កម្មទាំងពីរ គឺទាំងកុសល ទាំងអកុសល បើកុសលកម្មតាមទាន់ រមែងផ្តាច់បង់នូវអកុសលកម្ម បើអកុសលកម្មតាមទាន់ រមែងផ្តាច់បង់នូវផលរបស់កុសលកម្ម ។ កុសលកម្ម ជាឧបឃាតកម្មរបស់អកុសល ចំណែកខាងអកុ-សលកម្មក៏ជា ឧបឃាតកម្ម របស់កុសលវិញដែរ ។ កម្មនេះលោកហៅថា ឧបច្ឆេទកកម្ម ដូច្នេះវិញក៏បាន ។ ឧបឃាកម្ម នេះ មានសេចក្តីប្រហែលគ្នានឹងឧបបីឡកកម្មដែរ ផ្សេងគ្នាតែត្រង់ការឲ្យផលយូរនិងឆាប់ប៉ុណ្ណោះ គឺឧបឃាតកម្ម កាលបើជាប់តាមហើយ ក៏ផ្តាច់បង់សន្តតិ

សន្និទដោយឆាប់រហ័ស មិនបៀតបៀនបណ្តោយឲ្យយូរ អស់កាលវេលាវែងដូចឧបបីឡកកម្មទេ ។

៩-- គរុកម្ម កម្មក៏ធ្ងន់ បានដល់កម្មទាំង ២ ចំណែក គឺ ទាំងកុ-សល ទាំងអកុសល ។ កុសលកម្ម លោកសំដៅយកមហគ្គតកម្ម ៩ គឺ រូបាវចរកុសល ៥ អរូបាវចរកុសល ៤ នេះចាត់ជាគរុកម្មខាងកុសល ព្រោះជាហេតុនាំឲ្យកើតផលដ៏ខ្ពង់ខ្ពស់កន្លងជាតិជាលំដាប់ ។ អកុសលកម្មសំដៅយកអនន្តរិយកម្មទាំង ៥ មានមាតុឃាតជាដើម នេះចាត់ជាគរុកម្មខាងអ-កុសល ដោយហេតុថា បុគ្គលដែលធ្វើអនន្តរិយកម្មទាំង ៥ ណាមួយ បើទុកជាដឹងថាខ្លួនធ្វើកម្មអាក្រក់ណាស់ ហើយប្រាថ្នានឹងជម្រះទោសខ្លួនដោយវិធីណាមួយ មានបព្វជ្ជា និងឧបសម្បទាជាដើម ក៏ព្រះអង្គមិនអនុ-ញ្ញាតចំពោះវិធីនោះឡើយ សូម្បីនៅជាគ្រហស្ថ ចំរើនសមថកម្មដ្ឋានក៏មិនអាចសម្រេចមគ្គផលបាន ទោះបីធ្វើបុណ្យណាមួយ ដើម្បីលុបលាងទោសអនន្តរិយកម្មនោះក៏ពុំបានឡើយ ។ បុគ្គលអ្នកធ្វើអនន្តរិយ-កម្មនោះ លុះធ្វើកាលកិរិយា ទៀងតែទៅកើតក្នុងនរកដោយពិត ព្រោះអំពើនោះ ជាអំពើបាបមានទម្ងន់ណាស់ ទើបលោកចាត់ជា គរុកម្ម (កម្មដ៏ធ្ងន់) ។

១០- ពហុលកម្ម កម្មដែលសន្សំច្រើន បានដល់កម្មទាំង ២ ចំ

ណែក គឺទាំងកុសលទាំងអកុសល ។ កុសលណាមួយដែលបុគ្គលធ្វើជាញឹកញយ ជាកុសលមានកម្លាំង ប្រកបដោយសោមនស្សចេតនាក្នុងកាលទាំង ៣ គឺកាលខាងដើម នៃការធ្វើបុណ្យប្រកបដោយសោមនស្ស កាលកំពុងធ្វើក៏មានសោមនស្ស កាលបើធ្វើរួចហើយ ក៏មានសោមនស្សទៀត កម្មនេះនឹងហៅថា **អាចិណ្ណកម្ម**ក៏បាន ។ ផ្នែកខាងអកុសលនោះ គឺអកុសលណាមួយដែលបុគ្គលសន្សំធ្វើញឹកញយ ជាអកុសលមានកម្លាំងប្រកបដោយទោមនស្ស ក្នុងកាលទាំង៣ ដូចខាងកុសលដែរ ។ អកុសលកម្ម ប្រកបដោយទោមនស្សដ៏ក្លៀវក្លា ដែលធ្លាក់ទៅក្នុងសេចក្តីក្រោធ មានការកាចឃោរឃៅ អាចហ៊ាន ដេរពយ កាប់ សម្លាប់មនុស្សសត្វដទៃ ។ កម្មនេះច្រើនតែឲ្យផល ឃើញជាក់ច្បាស់ ក្នុងកាលដែលមានជម្ងឺចូលប៉ះពាល់ម្តង ៗ ដោយនិមិត្តឃើញជាក់ច្បាស់ ព្រោះកម្មនោះមានអាសេវនបច្ច័យ (បច្ច័យដោយការសេពគប់ញឹករឿយ ៗ ក្នុងមនោទ្វារ) ។

១១- **អាសន្នកម្ម** កម្មដែលធ្វើក្នុងវេលាជិតស្លាប់ បានដល់កម្មទាំង ២ គឺទាំងកុសលទាំងអកុសល ។ កុសលនិងអកុសលដែលបុគ្គលធ្វើនោះ ហើយនឹករលឹកឃើញប្រាកដក្នុងមនោទ្វារ ក្នុងវេលាជិតធ្វើកាលកិរិយា កម្មនោះឈ្មោះថាអាសន្នកម្ម ឬហៅថា យថាសន្នកម្មក៏

បាន ។ អាសន្នកម្ម នេះ មិនអាចនឹងមានកម្មដទៃចូលជ្រៀតជ្រែក ដណ្តើមឲ្យផលបានមុនឡើយ វៀរលែងតែមហគ្គតកុសលនឹងអនន្តរិយកម្ម ។ ឯកម្មដទៃ ៗ ឲ្យផលមុនបានដោយក្រណាស់ សូម្បីអាសន្នកម្ម មានប្រមាណតិចក៏ដោយ ច្រើនតែឲ្យផលបានមុន ជាងកម្មដទៃជាដរាប ប្រៀបដូចជាគោចាស់ដែលឈរនៅជិតមាត់ទ្វារក្រោល កាលបើនាយគោបាលបើកទ្វារក្រោលភ្លាម គោចាស់នោះក៏អាចចេញតាមទ្វារបានមុនជាងគោក្មេង សេចក្តីនេះយ៉ាងណា អាសន្នកម្ម កម្មដែលបុគ្គលនឹកឃើញក្នុងកាលរៀបមរណៈ ក៏អាចឲ្យផលបានមុន ជាងកម្មឯទៀត ក៏យ៉ាងនោះដែរ ។

១២- កដត្តាកម្ម កម្មដែលគ្រាន់តែធ្វើ ឥតចេតនា សំដៅយកកុសលកម្មនឹងអកុសលកម្ម ដែលជាកម្មស្តួចស្តើង ឬកម្មស្រាល ៗ ជាកម្មផុតចាកកម្មទាំង ៣ គឺ គរុកម្ម ១ ពហុលកម្ម១ អាសន្នកម្ម ១ កដត្តាកម្ម មិនរាប់បញ្ចូលក្នុងកម្មទាំង ៣ នេះឡើយ ។ កម្មនេះហៅថា កដត្តាវិបាកកម្ម ក៏បាន ។ មួយទៀត អំពើរបស់បុគ្គលដែលប្រកបដោយកាយ វាចា ចិត្ត ដោយពុំបានដឹងថាជាបុណ្យ ឬជាបាប គឺការធ្វើដោយមិនដឹងថា ត្រូវឬខុសទេ គ្រាន់តែធ្វើទៅតាមទម្លាប់ប៉ុណ្ណោះ កម្មនេះលុះដល់កាលដែលឲ្យផល ក៏ពុំមានកំណត់ ប្រៀបដូចជាកូនសរដែល

គេបាញ់ឆ្ពោះទៅទីណាមួយ ធម្មតាគូនសរ ដែលគេបាញ់ទៅនោះ មិនអាចនឹងកំណត់ថា ធ្លាក់ក្នុងទីនេះទីនោះបានទេ សេចក្ដីនេះយ៉ាងណា កដត្តាកម្ម អាចឲ្យផលដល់បុគ្គលអ្នកធ្វើ តាមអំណាចកម្មរបស់ខ្លួនដោយពិត ប៉ុន្តែពុំអាចកំណត់កាលវេលាបាន ក៏យ៉ាងនោះដែរ ។

ការបញ្ញត្តិអំពីកម្ម ដូចបានអធិប្បាយមកនេះ ជាផ្លូវដ៏ល្អដែលព្រះសម្មាសម្ពុទ្ធសំដែងទុកមកហើយ ដើម្បីពន្យល់ឲ្យឃើញថា បណ្ដាកម្មទាំងអស់ កម្មណាមួយសុទ្ធតែជាហេតុ កាលបើហេតុមាន ផលក៏រមែងមាន គឺផលទាំងអស់ទោះបីជាសុខឬជាទុក្ខ រមែងចេញផ្ដើមកអំពីហេតុដោយមានហេតុជាប្រភព (ហេតុជាដែនសម្រាប់កើត) ។ កម្មប្រៀបដូចជាដើមឈើ ផ្កាឬផ្លែ ដូចជាតួផល ។ ផលល្អក្ដី ផលអាក្រក់ក្ដី សុទ្ធតែកើតមកអំពីហេតុខាងក្នុង ពោលគឺកម្មរបស់អ្នកធ្វើ គឺជាកម្មរបស់បុគ្គលណា ផលក៏ឲ្យដល់បុគ្គលនោះវិញ តាមសមគួរដល់កម្លាំងកម្មរបស់ខ្លួន ដោយពិត ។ កម្មជាបុណ្យឬកម្មជាបាប ទៀងតែឲ្យផលជាដរាប ពុំមានវត្ថុស័ក្តិសិទ្ធិណាមួយ មកជ្រៀតជ្រែកឲ្យផល ឲ្យសិរីសួស្ដីក្រៅអំពីកម្មនេះដំបូង ឡើយ ដោយសេចក្ដីថា បើបុគ្គលធ្វើអំពើអាក្រក់ ហើយខំបន់ស្រន់សំបូងសង្រ្វែងចំពោះវត្ថុស័ក្តិសិទ្ធិ ឬចំពោះព្រះជាម្ចាស់ថា «សូមឲ្យបានផលជាសុខ សួស្ដីដល់អាត្មាអញ» ។ អំពើអាក្រក់ដែលបុគ្គលណាធ្វើហើយ បុគ្គលនោះត្រូវបានទទួលផលអាក្រក់វិញជាប្រាកដ មិនអាចបំបែរ ដោយ

ការបេទស្រទ់ដូចោះឡើយ ។

ការសំដែងអំពីកម្មនេះ ដើម្បីញុំាងមហាជនឲ្យស្គាល់ហេតុផល និង បានចៀសពង វៀរចាកបាបកម្ម ឬអកុសលកម្មឲ្យស្រឡះចេញចាកខន្ធ-សន្តាន ហើយនឹងបានសេពគប់ អប់រំ ចំរើន ធ្វើឲ្យរឿយ ៗ នូវបុញ្ញកម្ម ឬកុសល ឲ្យមានបរិបូណ៌ក្នុងខន្ធសន្តាន ។

ចប់បុណ្ណោះ ។

លោកថាភ្នំ ព្រះសុមេរុធំ ខ្ពង់ខ្ពស់គណនា ប្រាំប័ម៉ឺនស្បាន់ បួនពាន់យោជន៍ប្រា- កដគុណមាតា ខ្ពស់លើសលែងនោះ ។ រីចក្រវាល ទូលាយពិស្តារ ធំធេងទៀងនោះ ទូលាយលើសក្រៃ ឥតអ្វីស្មើស្មោះ លើកយកគុណនោះ មកផ្ទឹមពុំបាន ។ រីមហាសមុទ្រ ជ្រាលជ្រៅបំផុត ពេកពន់ប្រមាណ មោះគុណមាតា រក្សាព្រួយប្រាណ ជ្រៅក្រៃផលផ្លូន ផលសាគរវិញ ។ រីមហាប្រថពី ការគតផែនដី ក្រាស់ក្រៃពាសពេញ ទូទាំងចក្រវាឡ ថាស្រាលស្តើងវិញ គុណម្តាយនោះមិញ ក្រាស់ក្រៃគណនា ។

ឆកញ្ញាព្រះឃ្លាំងខង

# ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគត់មត់
ព្រោះអក្សរជាតិ ពោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប. ព.

## បញ្ហាជីវិត (វិចារណកថា)

សហជីវិន ជល-ធិត្យ នៅពុទ្ធសាសនបណ្ឌិត្យ និពន្ធ
ព្រះមុនីកោសល ស្វរ-ហាយ អធិបតីនៃក្រុមជំនុំព្រះត្រៃបិដក ពិនិត្យ ។

យោបល់អ្នកខ្លះ ប្រកាសពិត តែថាជីវិត ជាទោសទុក្ខ
ព្រោះត្រូវរក្សា ការគ្រប់មុខ តាំងពីស៊ីបុក ទំនុកកាយ ។
ខ្លះថា ជីវិត ឥតទោសពៃរ៍ ជាធម្មជាតិថ្លៃ-ថ្លា កើតឆាយ
ជាទីនាំសុខ មកផ្ទុកកាយ មនុស្សសត្វទាំងឡាយ តែងចង់បាន ។
ឯអ្នកខ្លះទៀត ជ្រៀតពន្យល់ ប្រមូលយោបល់ ទាំងពីរស្ថាន
ប្រកាសប្រកាន់ ថា ល៍អាន ជីវិតគឺបាន ទាំងពីរបែប ។
ដើម្បីលើកហេតុ សង្កេតគាង បញ្ចេញពស្តុតាង បញ្ជាក់អែប
យើងសូមវែកញែក ដោយសង្ខេប ទុកជាបទបែប ពិចារណា ។
ទីមួយ យោបល់ យល់ជាប់ចិត្ត ដែលថាជីវិត ទុក្ខខ្លោចផ្សា
ទ្រឹស្តីនេះឯង ចែងប្រាប់ថា មនុស្សយើងគ្រប់គ្នា ដែលប្រឹងរស់ ។

ចន្លោះការកើត និងការស្លាប់ លំបាកយ៉ាកយ៉ាប់ សព្វទាំងអស់
ដូចជាប្រឹងរក ទ្រព្យរបស់ រកកិត្តិយស ខ្ពស់ឧត្តម ។
បើមិនប្រឹងរក វាអត់បាយ បើគ្មានប្រាក់ចាយ វាគ្រោះធំ
ម្ល៉ោះហើយគ្រប់គ្នា ត្រូវតែខំ សន្សែសន្សំ កសាងកម្ម ។
បញ្ចេញទឹកញើស បញ្ចូលទ្រព្យ ប្រឹងដកកាយកប់ បណ្តុះដាំ
ទិញដូរបណ្តាក់ លក់បញ្ចាំ រងកម្តៅកាយ ក្រហាយចិត្ត ។
ពេលថ្ងៃក្តៅថែស សឹងឆេះក្បាល ធ្វើការក្នុងវាល ក៏គ្មានគិត
ត្រូវភ្លៀងរខ្វះ រះគួរកើត ក៏ចិត្តឥតបេះ វេះនឿយណាយ ។
តែក្រោកពីដេក បើកភ្នែកឡើង ទាំងគេទាំងយើង ដើរប្រញាយ
ចេញទៅធ្វើការ ផ្សារទាំងឡាយ ព្រោះតែរូបកាយ បង់រស់ពិត ។
អ្នកដែលក្រពេក ដេកសម្ងំ ដកដង្ហើមធំ ក្រៀមក្រំចិត្ត
ខ្លះជ្រុលរុលសាង ខាងទុច្ចរិត បង្ខិតបង្ខំ បន្ទំគេ ។
ខ្លះទៀតលួចប្លន់ ជាន់លើច្បាប់ ហ៊ានបាញ់តាក់កាប់ ក្បត់ឪម៉ែ
ខ្លះជា-ម្ចករ យកប្រាក់ខែ ខ្លះទៀតពូកែ ខាងលីសែង ។
មើលចុះ បាវស្រូវ ធំអ៊ែម៉ែះ ទំលើរចង្កេះ គួរឲ្យស្ញែង
កោតគេព្រនាក់ ដាក់ដូចលេង ម្នាក់ឯងឈានដើរ ធ្វើពហើ ។
តើអ្វីទៅអេះ ? ដែលរុញច្រាន ឲ្យគ្នាប្រឹងប្រាណ គ្មានប្រណី
មិនគឺជីវិត ហ្នឹងឬអ្វី នេះឯងទ្រឹស្តី ដែលថាទុក្ខ ។

ពិសេសទៅទៀត រូបរាងកាយ ដែលអាស្រ័យបាយ ម្ហូបគ្រប់មុខ
បើមានស៊ីហើយ នៅឈឺចុក មានរោគកលទុក្ខ រកថែមទៀត ។
ប្រឹងតែថែខ្លួន ផ្ទួនសំគាត ភ័យក្រែងខត្សាត រកជ្រែកជ្រៀត
ឈឺនេះឈឺនោះ ព្រួយចង្អៀត នេះទៀត ក៏គ្រោះ គ្រោះជីវិត ។

រួមមកថា រស់ ព្រោះប្រឹងណាស់ ហេតុនេះ ឃើញច្បាស់ ថាទុក្ខពិត
គ្មានផ្លូវណាមួយ ឲ្យជឿចិត្ត តែថា ជីវិត សុខស្រួលទេ ។

ទីពីរ យោបល់ យល់លើអ្វី ដែលចេញទ្រឹស្តី យ៉ាំងហូវហែ
ប្រាប់ថា ជីវិត ឥតទុក្ខទេ តើគេចង់ថា អាចដូចម្តេច ។
រឿងនេះ គេចង់ថា ជីវិត ដែលស្និតសព្វថ្ងៃ ថ្លៃជាងពេជ្រ
វាជាប្រភព សុខជានិច្ច ទោះមនុស្សដូចម្តេច ក៏ប្រាថ្នា ។
បើជាសំបុក ទុក្ខរំខាន ម្តេចក៏ចង់បាន តែគ្រប់គ្នា
បើពិតជាហេតុ ទុក្ខវេទនា ម៉េះគ្មានអ្នកណា ត្រូវការឡើយ ។
គេស្អប់អាក្រក់ ទើបគេល្អ ស្អប់ខ្មៅគេស អ៊ីចឹងហើយ
ចុះជីវិតវិញ នោះមិត្រតើយ មិត្រឆ្លើយថាស្អប់ ឬស្រឡាញ់ ។
បើថាស្រឡាញ់ ពេញជាសុខ បើស្អប់ទើបទុក្ខ ពិតឥតកាញ់
តែដើរសួរចុះ ខុសសុំទាញ បើគ្មានស្រឡាញ់ គឺគ្មានមនុស្ស ។
ដូច្នេះ បេះប្រាប់សព្វបរិយាយ ជីវិតសប្បាយ នេះឥតខុស
បើនៅសង្ស័យ ថាកំហុស យើងសូមបំផុស ន័យតទៅ ។

ជីវិត បានដល់ការសោកទ បិតថេររូបប្រាណវិញ្ញាណនៅ
ជីវិតមិនមែនរឿងផ្កាក្តៅ តាមពិតគេហៅថាថ្លៃថ្លា ។
បើជារបស់ ថ្លៃពិសុទ្ធ ពិសេសបំផុត ដូច្នេះណា
នោះគេអាចហៅ ខ្ញុំថា ជាសុខធម្មតា គ្មានទុក្ខទេ ។
ដូចជាដុំពេជ្រ រលោងស្រស់ ជាវត្ថុខ្ពស់សឹងអស់គេ
បើយើងមានច្រើន យើងតែងតែ រីកថ្លើមចិត្តប្រែ គេគិតរីករាយ ។
គឺបើមានពេជ្រ ពាក់ប្រាណយើង ចិត្តតែងជោរឡើង ថ្លាសប្បាយ
ព្រោះពេជ្រជារបស់ ខ្ពស់ចើតឆ្ងាយ នាំក្តីសប្បាយ មកឲ្យប្រាណ ។
បើប្រាណវិនាស ដុំពេជ្រវិញ យើងបែរទោម្នេញ ទុក្ខរំខាន
ដូចយើងប្រាសសុខ ពីសន្តាន តែងមានចិត្តស្តាយ ក្លាយជាទុក្ខ ។
រីឯជីវិត គិតដូច្នោះ ប្រាជ្ញប្រាយសង្គ្រោះ ហៅថាសុខ
បើប្រាសជីវិត ពិតជាទុក្ខ ប្រៀបនឹងប្រាសសុខត្រូវពេកពន់ ។
អ្នកដែលមានពេជ្រ តែងគិតខ្លាំង ភ័យក្រែងចោរខ្លាំង មកលួចប្លន់
រឿងនេះគឺព្រោះតែនរជន គិតគន់ក្រែងពេជ្រ ជាប់ទៅគេ ។
ព្រោះពេជ្រជាផ្លូវ ដើមនៃសុខ ឯទុក្ខមិនមែន ពេជ្រលង់ទេ
ដូចអ្នកបានសុខ តែងគិតរេ ក្រែងគេលួចសុខ ដូច្នោះឯង ។
រីឯជីវិត ក្រឹតតម្រូវ មានផ្លូវត្រូវថា ចរចាថ្លែង ។
ជាសុខថ្លៃថ្លា ឃើញជាក់ស្តែង មនុស្សស្មែងតែងបានមានមូលមក ។

ត្រង់ប្រាណវិនាស បាត់ទៅវិញ    ក៏គេទុក្ខម្នេញ ពេញកវេក
ដូចអ្នកបាត់សុខ តែងទុក្ខកក    ទឹកខកស្ដាយវ៉ា ជាធម្មតា ។
ឯមនុស្សប្រឹងប្រាណ គ្មានឈប់ឈរ    ប្រកបរបរផងនានា
ទ្រាំក្ដៅត្រជាក់ ញាក់ខ្លោចផ្សា    គឺគ្រាន់តែជាបរជីវិត ។
ដូចយើងចង់បាន ឡានជិះលេង    ទាល់តែខ្នះខ្នែង វែងរិះគិត
រកលុយកាក់ព្រម ល្មមកម្រិត    ទើបបានដូចចិត្ត ដែលត្រូវការ ។
បើឥតលុយកាក់ ប្រាក់ទៅទិញ    បំណងនោះមិញ ឥតអសារ
មិនមែនអ្នកលក់ ចាំដេកចារ    ពន្យារទុកដល់ ជាតិក្រោយឡើយ ។
រីឯជីវិត ក៏ដូច្នោះ    ត្រូវតែស្រាយដោះ អ៊ីចឹងហើយ
បើមនុស្សចិត្តក្នុក ដេកព្រងើយ    អាចឆ្ងើយថាពិត ជីវិតគ្មាន ។
ប្រសិនត្រូវការ ប្រាថ្នាពេជ្រ    ដែលជាងរំលេចស្មើសួរគាន្ធ
ត្រូវតែខំប្រឹង ឲ្យតឹងប្រាណ    រកប្រាក់ឲ្យបាន យកទៅដូរ ។
ជីវិតវិញសោត ក៏ដូច្នោះ    ត្រូវយកការនោះ ទុកជាបរ
ត្រូវស្វែងសម្បត្តិ ឲ្យសម្បូណ៌    ទើបអាចទិញដូរ ជីវិតបាន ។
ប្រសិនរកទ្រព្យ មិនគ្រប់គ្រាន់    ជីវិតក៏អន់ អាប់ឥតក្សាន្ត
ព្រោះបរខ្ទតិច ធ្វើម្ដេចបាន    ជីវិតថ្កើងថ្កាន មានសុខពេញ ។
តែបើរកទ្រព្យបានគ្រប់គ្រឿង    ជីវិតរុងរឿង ឥតទុក្ខម្នេញ
ព្រោះបរគេព្រម ល្មមថ្លៃទិញ    ជីវិតនោះមិញ ពេញសុខសាន្ត ។

អ្នកដែលចង់រស់ព្រោះខ្លាចស្លាប់    អ្នកដែលចង់ស្លាប់ព្រោះព្រួយប្រាណ

មានទោសទុក្ខធំតែពុំបាន    យ៉ាងហ្នឹងទើបហ៊ានបែកឋានទៅ ។

ទោសទុក្ខគ្មានទេ គង់ជីវិត    តែមនុស្សព្រួយចិត្ត គិតក្តួលក្តៅ

នឹកឃើញតែទុក្ខ មុខហ្មងសៅ    លែងចង់រស់នៅ គង់លោកផង ។

ប្រៀបដូចមនុស្សម្នាក់ជំពាក់គេ    មានខ្សែមាសពេជ្រ ច្រើនកន្លង

ដល់គេទារពេក ដេកមួហ្មង    លក់មាសពេជ្រសង លែងអាល័យ ។

មាសពេជ្រជារបស់ថ្លៃមែនពិត    តែទាល់គំនិតក៏អស់ន័យ

លក់សងគេភ្លាម តាមតម្លៃ    ឈប់ដេកស្រមៃ គេស្តីទារ ។

រីអ្នកចង់ស្លាប់ ព្រោះជាប់ទុក្ខ    ជាប់ទោសផ្ចាល់មុខ ផុតពុះពារ

អស់ផ្លូវត្រូវតែ ប្រែបង់ការ    ប្រថុយសង្ខារយកទៅសង ។

ទោសទុក្ខនោះឯង ករៃងធ្ងន់    មានតែជីពជន្ម ទើបល្មមរង

យកទៅផាត់សើយថយថែមសង    រួចគ្នាតែម្តង គង់លោកហ្នឹង ។

យ៉ាងនេះឯងហើយ ដែលឆ្លើយថា    ជីវិតថ្លៃថ្លា ឥតបីថ្លឹង

ជាសុខក្សេមក្សាន្ត មានទីពឹង    មនុស្សត្រូវតែប្រឹង រក្សាទុក ។

នេះឯងយោបល់យល់គង់ចិត្ត    ប្រាប់ថាជីវិត ពិតជាសុខ

គ្មានផ្លូវណាឡើយ ឆ្លើយថាទុក្ខ    ដូចកយទំនុក មកប៉ុណ្ណឹង ។

ទីបីយោបល់យល់អារកាត់    អ្នកខ្លះបញ្ញត្តបញ្ញាថ្លឹង

លប់ចោលទ្រឹស្តី ទាំងពីរហ្នឹង    ហើយតាំងប្រកែកជជែកថា ។

ជីវិតស្ថិតនៅផ្លូវកណ្ដាល    មិនជ្រាលកលទៅ ផ្លូវខាងណា
គ្មានសុខគ្មានទុក្ខ ជាធម្មតា    គេអាចហៅថា អព្យាក្រិត ។
បើវាឯកា ជាប្រក្រតី    ឥតអ្វីមកជ្រែក ក្នុងជីវិត
នឹងហៅថាសុខ ក៏ពុំពិត    ថាទុក្ខវិបរិត ក៏ពុំបាន ។
ប្រៀបដូចក្អែកជា មើលជិតឆ្ងាយ    ឃើញរូបទាំងឡាយ សព្វទិហាន
ទោះបីរូបល្អ ស្រស់កុំផាន    ឬរូបសាមាន្យ អាក្រក់ក្តី ។
មិនមែនក្អែកទេ ជាជាងឆ្លាក់    ឲ្យរូបវិលក្សណ៍ល្អពិសី
ឬឲ្យអាក្រក់ មិនគប្បី    តាមពិតអ្វី ៗ មានរូបរាង ។
វាស្រេចតែតាម សភាពវា    មិនមែនក្អែកណា ចេះកសាង
ក្អែកគ្រាន់តែឃើញ រូបគ្រប់យ៉ាង    នេះ ជាភ័ស្តុតាង យ៉ាងច្បាស់ ។
ដំណើរជីវិត ពិចិត្រទៅ    ពិសោធកក់ជ្រៅ ឲ្យត្រូវអស់
គឺវាមានត្រឹម តែការរស់    នាទីវាអស់ប៉ុណ្ណឹងឯង ។
ត្រង់រឿងសុខទុក្ខ ស្រួលរីករាយ    លំបាកសប្បាយ ដែលគេថ្លែង
នោះវាត្រូវជា ធម្មជាតិផ្សេង    ចែកបែងជាស្រេច ដាច់ដោយឡែក ។
ចំណែកជីវិត គិតតែរស់    ត្រង់រឿងទាបខ្ពស់ សុខទុក្ខប្លែក
មិនមែនជីវិតជាអ្នកចែក    ប្រៀបបាននឹងក្អែក ដូច្នោះឯង ។
បើហ៊ានថាពិតជីវិតទុក្ខ    ឯសុខក៏ត្រូវតែថ្លាថ្លែង
ព្រោះសុខនឹងទុក្ខ ពីរនេះឯង    វាតែងនៅចាំ ផ្លាស់ប្ដូរគ្នា ។

ប្រៀបដូចអាក្រក់ ហើយនឹងល្អ　　ឬមានទទឹងក្រ ខូចនឹងជា
ទាំងនេះជាគូ គូផងវា　　តែងផ្លាស់ប្តូរគ្នា ជាលំអាន ៗ
គឺបើមានល្អ សឥតល្អក់　　ឯក្តីអាក្រក់ ត្រូវតែមាន
ឥតគូតាំងនៅ តែឯកឋាន　　ជានេះឥតស្មាន គ្មានខ្ចាប់ក្រង ៗ
មួយទៀតការរស់ បើគ្រោះទុក្ខ　　ឬផ្លាក់ត្រូវសុខ ដូចគេថ្លែង
សុខ-ទុក្ខទាំងនេះកំរផ្សេង　　ការរស់គ្មានបែង បង្កើតឡើយ ៗ
ប៉ុន្តែ ការរស់ គឺជីវិត　　ជាអញ្ញាក្រឹត្យ ពិតមែនហើយ
តែងមានសុខទុក្ខ នៅកិតកើយ　　មិនមែននៅខ្ជើយ ម្នាក់ឯងទេ ៗ
ព្រោះកាយកើតបាន មានឈាមសាច់　　ត្រូវការចាំបាច់ ច្រើនហូរហែ
ដំបូង បង់រស់ ដើម្បីរេ　　ចាប់ប្រែប្រឹងប្រែងស្វែងរកសុខ ៗ
ការស្វែងរកស្រួល ក្តួលក្តៅណាស់　　តែងតែរេប៉ះ លើក្តីទុក្ខ
ដែលជាឧបសគ្គ ស្លាក់ពីមុខ　　ទម្រាំបានសុខ មានទុក្ខធំ ៗ
គិតទៅជីវិត មិនឥតគ្នា　　ត្រូវរងវេទនា ទាំងពីក្រុម
គឺសុខនឹងទុក្ខ មកជ្រែកជ្រុំ　　ប្រឡូកប្រឡំ ផ្សំចូលគ្នា ៗ
ពេលខ្លះជីវិត ជាសុខស្រួល　　ពេលខ្លះទទួល ទុក្ខវេទនា
សព្វាយលំបាក ផ្លាស់វេនគ្នា　　តាមព្រេងវាសនារបស់មនុស្ស ៗ
ដូច្នេះ បើរួម សុខទុក្ខផង　　ដោយចង់គ្មានបែកញែកគ្នានោះ
ជីវិតគឺប្រាជ្ញ អាចសង្គ្រោះ　　ឲ្យឈ្មោះពីរយ៉ាងខាងធម្មសាស្ត្រ ៗ

ហៅសុខក៏បាន ទុក្ខក៏បាន
ថាជាសុខខ្លះ ជាទុក្ខខ្លះ
ហៃមិត្តទាំងឡាយប្រាជ្ញប្រាយធ្ងុះ
យោបល់ទាំងបីលៃខាងណា
សូមមិត្រជួយតប សបឲ្យជាក់
ខ្ញុំចង់ដឹងថាណាត្រូវជាង
បញ្ហានេះហោច ពិសោធចិត្ត
នៃមិត្រនារី នឹងបុរស
បើមិត្រគិតយល់ ផ្ដល់ចម្លើយ
ឲ្យឃើញថាត្រូវ ព្រោះផ្លូវណា
ជៀតអីស្រី ប្រុស មនុស្សសាកល
ប្លែកៗ ពីគ្នាអីចឹងហើយ
ប៉ុន្តែ ខ្ញុំចង់ស្រង់គំនិត
តើផលទ្រឹស្ដី ទាំងបីនុះ
ដូចជាយោបល់ យល់តាមចិត្ត
បើគេប្រកាន់ដូច្នេះណា
ជាមនុស្សបេះបង់ខ្ពង់ខ្ពស់ប្រាណ
ចង់ជួយសាងជាតិញាតិសាច់ផៅ

ឬរួមពីរហានឲ្យជាក់ច្បាស់
ឆ្លើយនេះត្រូវណាស់ អស់គាំៗ
ស្ដាប់មើលទៅចុះបូរដោះសា
ត្រូវល្អថ្លៃថ្លាសមសារជាង ៗ
ប្រត្យក្សដោយនូវផ្លូវវៃរាង
ឬទាំងបីយ៉ាង មិនទាំងអស់ ៗ
ចង់ឃើញគំនិតដ៏ខ្ពង់ខ្ពស់
តើចេញមកស្រស់របៀបណា ៗ
សូមឆ្លើយមកភ្លាមតាមប្រាជ្ញា
កុំខ្លាចគេថា អ្វីឲ្យឡើយ ៗ
តែងមានយោបល់យល់ឆ្លងឆ្លើយ
កុំគិតអ្វីឡើយ ឆ្លើយមកចុះ ៗ
ដែលពិតមិត្រស្រាវជ្រាវរាវធ្ងុះ
រកដុះមែកធាងទៅខាងណា ៗ
ជាជុំជីវិត ទុក្ខខ្លោចផ្សា
តើគេនឹងជាមនុស្សអ្វីទៅ ៗ
ចង់មានចង់បានចង់រស់នៅ
ឬចង់រត់ទៅ ទៅណាវិញ ៗ

តើគេនឹងជាមនុស្សហ៊ឹហា    លេងស្រីផឹកស្រា បារដង់ស៊ិញ
ត្រូវការសប្បាយសុខសាយពេញ    ឬមនោកាមញេញពេញក្រៃលែង ។
ជាមនុស្សទ្រុះមិត្រ គិតតែបាន    ដើម្បីរស់កាន ខ្លួនប្រាណឯង
ឬមនុស្សមានមែក បេះបែកបែង    បែកសុខគេឯងស្វែងតែល្ហុម ។
មិនលោភមិនលន់ធ្ងន់ទុច្ចរិត    ចចើងចងចិត្តឥតបេះព្រម
ឬជាមនុស្សក្មើដើរតែប្លម    ដូចកមរមាស់រស់ដោយគេ ។
ឬក៏គេនោះរស់ម្តេចវិញ    សូមមិត្រចាំពេញឲ្យហូរហែ
ឲ្យឃើញហេតុផលយល់ប្រាជ្ញប្រែ    តាមកិច្ចល្បែចកែ ខ្ញុំអ្នកជា ។
រឯទីពីរ និងទីបី    ក៏មានសេចក្តីន័យដូចគ្នា
ខ្ញុំចង់តែដឹងដំណឹងថា    តើគេក្លាយជា មនុស្សដូចម្តេច ។
គឺថាបើគេប្រកាន់ចិត្ត    ថាដួងជីវិត ពិតជាងពេជ្រ
ជាទីញុំាងសុខឲ្យសម្រេច    គ្មានមនុស្សណាគេចមិនប្រាថ្នា ។
បើយល់យ៉ាងហ្នឹងគេប្រឹងគិត    ព្រមប្រាណប្រព្រឹត្តទៅយ៉ាងណា
ដើម្បីតម្រូវ ផ្លូវតម្រា    ដែលថាជីវិតពិតជាសុខ
រវាងយោបល់យល់ជីវិត    ថាអព្យាក្រិត្យឥតបេញមុខ
រួមបានទាំងសុខបានទាំងទុក្ខ    តើរៀបចំទុកដូចម្តេចវិញ ។
អ្នកដែលប្រកាន់គំណាន់នេះ    នឹងទៅម៉េចអេះសូមបំពេញ
តើគេរស់នៅដូចអ្វីវិញ    ភាគឬចំណេញយ៉ាងណាខ្លះ ។

ប្រស្នានេះគួរសួរយោបល់ ប្រយោជន៍ដំកល់កាព្យសាស្ត្រ
គំនិតសិល្បៈដ៏ជាក់ច្បាស់ ទឹងចិត្តសាស្ត្រផ្លាស់សម័យ ។
ទឹងជាប្រយោជន៍យ៉ាងឧត្តម ខាងការអប់រំផ្ទំនិស្ស័យ
ឲ្យជាអ្នកសាងខាងប្រពៃ សូមមិត្រគិតថៃ ឆ្លើយទៅអើយ ។

— ចប់ —

---

នារីណា ប្តីដេរប្រទេច ឬប្តីសំឡុឹងសំឡក់
ដោយក្តីក្រោធ នៅតែធ្វើទឹកមុខស្រស់ស្រាយញញឹម
នារីនោះ ទើបឈ្មោះថាស្រីមានលក្ខណ៍ ។
ស្រីណាស្រឡាញ់ប្តី ទោះជាប្តីនៅក្រុង ឬនៅ
ស្រុកព្រៃ ឬពុំនោះទេ ជាប្តីគ្មានបុណ្យ ឬ មាន
បុណ្យក្តី ស្រីនោះទើបលោកតាំងមូលឲ្យសេចក្តីសុខ ។
សេចក្តីពិត ភស្តាជាគ្រឿងអលង្ការនៃនារីទាំងឡាយ
នារីឥតភស្តា ឈ្មោះថាមិនមានគ្រឿងអលង្ការ
បើទុកជាមានរូបល្អ ក៏មិនឈ្មោះថាមានរូបដែរ ។

ហិតោបទេស

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

*ព្រះមហា ចាំង-ទាត់ រៀបរៀង*

(តមក)

---

អធិវេដ្ឋិត គុ. ដែលព័ទ្ធក្រៃលែង ដែលព័ទ្ធជុំវិញ ។

អធិគស្ដ គុ. ដែលគេសរសើរ ។

អធិគិរោធរមិ ក្រិ. វិ. នៅលើក ។

អធិឝី ក្រិ. សម្រាក ដេក នៅ ដាក់ ។

អធិគ្រយណី ស្ត្រី. ខ្ទះ ។

អធិឝ្រិ ក្រិ. ដាក់ក្រៃលែង ផ្អែក ។ – ឝ្រិត គុ. ដែលដាក់ ដែលនៅលើ ដែលចូលទៅ ដែលសង្កត់លើ ។

អធិឝ្រី- គុ. ដែលមានសិរី ដែលមានតម្លៃ ដែលមានអធិបតេយ្យ ។

អធិឞ្ឋា (ស្ថា) ក្រិ. នៅក្រៃលែង ទុំលើ នៅគ្រប់គ្រង ត្រួតត្រា ។ – ឞ្ឋិត គុ. ដែលឋិតនៅ ដែលត្រួតត្រា ដែលនាំ ។

អធិឞ្ឋាតឫ ក. ន. នាយ មេ ។

អធិឞ្ឋាន នបុំ. ឋានក្រៃលែង ទីស្នាក់ការ កន្លែង ។ អំណាច ទីតាំង មូលដ្ឋាន ។ – វន្ត គុ. ដែលមានទីឋានក្រៃលែង ។

អធិឞ្ឋេយ្យ គុ. ដែលនៅក្រៃលែង ដែលះភ័ ។

អធិសេនាបតិ បុំ. អធិសេនាបតី ឧត្តមសេនីយនាយក ។

អធិស្ឋកម៌ ក្រិ. វិ. ដិតដោះ ។

អធិស្យ៩ គុ. ដែលលឿនក្រៃលែង ។

អធិហស្ដិ ក្រិ. វិ. លើដំរី ។

អធិហ្វ ក្រិ នាំទៅក្រៃលែង ធ្វើឲ្យមាន ធ្វើឡើង ។

អធី (អធិ+ឥ) ក្រិ. ទៅក្រៃលែង ស្គាល់ យល់ រៀន ។ អធីត គុ. ដែលរៀនហើយ ។

អធីការ បុំ. អធិការ ការត្រួតត្រា ។

អធីក្ស (អធិ+ឦក្ស) ក្រិ. មើលក្រៃលែង សង្ស័យ ។

អធីតិន គុ ដែលរាប់រកគ្នា ការបេះដឹង(ខាងវេទ) ។

អធីន គុ. ដែលអាស្រ័យ ដែលនៅក្រោម ។

អធីរ គុ. ដែលមិនក្លាហាន ដែលខ្លាច ដែលខ្សត់ខ្សោយ ។

អធីរតា ស្រី. ភាវនៃបុគ្គលមិនក្លាហាន កម្លាច កំសោយ ។

អធីរាក្ស គុ. ដែលមានភ្នែកមិននឹង ដែលមានភ្នែកព្រឡេបព្រឡប់ ។

អធីវាស បុំ. លំនៅ ទីស្នាក់ការ ។

អធីឝ បុំ. ជនធំក្រៃលែង ម្ចាស់ ។ – តា ស្រី. ភាវនៃជនធំក្រៃលែង ។

អធិភូ ក. ន. ព្រះរាជា ចៅហ្វាយ ។

# រឿងអាប៊ូលហ្វ៉ាអ៊ួរិស៍

លោក ក៉យ - ល្មុត តំណាងរាស្ត្រ ប្រែរៀបរៀង

---

នៅបុរាណកាល កន្លងរំលងទៅហើយជាយូរអង្វែង មានយុវជនមួយរូបនាមថា អាប៊ូលហ្វ៉ាអ៊ួរិស៍ ជាកូនអ្នកឈ្មួញមួយធំខាងជើងសំពៅ បិតនៅក្នុងក្រុង បាសរ៉ា ។ កាលវ័យជាកុមារ បិតាតែងនាំក្មេងនេះធ្វើដំណើរ ជួញប្រែ តាមសមុទ្រឥណ្ឌា ។ លុះដល់អាយុ ១២ ឆ្នាំ អាប៊ូលហ្វ៉ាអ៊ួរិស៍ បានស្គាល់កោះទាំងឡាយចំនួនប្រហែលជាងពាក់កណ្ដាលក្នុងសមុទ្រនេះ ។ កិច្ចការជំនួញបានផ្ដល់នូវលទ្ធផលដ៏ប្រពៃ ក៏ក្នុងប្រមាណជា ១០ ឆ្នាំ ប៉ុណ្ណោះ ពាណិជនេះ ទៅជាអ្នកមានទ្រព្យសម្បត្តិលើសជាងគេទាំងអស់ នៅទីក្រុងបាសរ៉ា ។

មានមួយថ្ងៃ ឪពុកនិយាយទៅកាន់កូនថា : កូនសំឡាញ់អើយ ! ឪពុកមានកិច្ចការទាក់ទិនជាច្រើន ត្រូវតែជម្រះបញ្ជីប្រាក់កាស តម្លៃទំនិញ អីក៉ន់យើង . . . ។ល។ ឲ្យជ្រះស្រឡះ ជាមួយនឹងមហាសេដ្ឋីនាម «ហាប៊ីប» ដែលឪពុកទាក់ទងរកស៊ីជាមួយនឹងលោក នៅទីក្រុងសេរេនឌីប ។ ឪពុកគិតប្រគល់រឿងនេះ តាមតែកូនគិតគួរផ្ទៀងផ្ទាត់សម្រេចយ៉ាងម្ដេចឲ្យខាងតែបានបញ្ជីនេះជ្រះស្រឡះគ្នាទៅចុះ ។

អាប៊ូលហ្វ៉ាអ៊ួរិស៍ ក៏ទទួលចាត់ការ តាមបំណាងឪពុក ថ្វីបើមានសេចក្ដីទុក្ខព្រួយ ដោយត្រូវធ្វើដំណើរឃ្លាតពីស្រុកទេស ជាយូរថ្ងៃ

តែយុវជននេះ ចង់ឃើញទីក្រុង សេរេនឌីប នោះណាស់ដែរ ព្រោះពីកាលមុន បានធ្លាប់ស្គាល់ទីក្រុងនេះដែរ តែខានទៅក្រុងពេក ឥឡូវស្រពិចស្រពិល ចង់ភ្លេចទៅវិញអស់ទៅហើយ ។

ក្រោយដែលបានទទួលលិខិតប្រគល់អំណាច និងសេចក្តីផ្តាំផ្ញើសព្វគ្រប់ព្រមទាំងបញ្ជីផ្សេង ៗ . . . ។ល។ អ៊ីពឌុក អាប៊ូលហ៊ាំ-ម្ស៊ីស៍ ចេញដំណើរទាំងទឹកភ្នែក ដល់កំពង់ បាសរ៉ា ចុះក្នុងសំពៅមួយ មានផ្ទុកទំនិញនាំទៅទីក្រុង សុរ៉ាត ហើយត្រូវបន្តដំណើរពីទីនោះទៅកោះ សេរេនឌីប ។

សំពៅត្រូវធ្វើដំណើរឆ្លងកាត់ឈូងសមុទ្រទាមបាសរ៉ា ដែលមានបណ្តោយប្រហែល ៣០០លើ (ប្រមាណ ១.២០០ គីឡូម៉ែត្រ) ទទឹង ៥ លើ (២០០ គីឡូម៉ែត្រ) ។ ឈូងសមុទ្រនេះ ទៅផុតខាងកើតគឺប្រទេស អារ៉ាប ឯណោះ ដែលជាមហាប្រទេសមួយធំសប្បាយរុងរឿងណាស់ ហើយបិតនៅ សន្ទឹងចំពាក់កណ្តាលប្រទេសប៉ែរ្ស ប្រមូលបញ្ចូលរួមគ្នាវែងអន្លាយសំដៅត្រង់ទៅពាមហៅថា ទរមុស ។ សំពៅបានឈប់សម្រាកបន្តិចនៅទីក្រុង ទរមុសនេះ រួចធ្វើដំណើរកាត់ត្រង់ចូលទៅក្នុងសមុទ្រ ប៉ែរ្ស ហើយបត់ទៅខាងកើត ឆ្ពោះទៅទីក្រុង សុរ៉ាត ។ យើងបានដល់ទីក្រុង សុរ៉ាត ដោយសុវត្ថិភាព បានផ្ទេរទំនិញ រួចធ្វើដំណើរទៅទៀត តាមផ្លូវត្រង់ទៅកោះសេរេនឌីប

តែម្តង ដល់ហើយ ក៏រើទំនិញដែលមានទាំងប៉ុន្មានចេញពីសំពៅ ។

អា – កិច្ចការជាដំបូងបំផុតរបស់ខ្ញុំគឺ ខ្ញុំត្រូវតែទៅសួររក តើលោកមហាសេដ្ឋី ហាប៊ីប លោកឋិតនៅត្រង់ណា ? ។ មានគេប្រាប់ខ្ញុំភ្លាម នូវអាសយដ្ឋានរបស់លោកនេះ ព្រោះនរណាក៏គេស្គាល់លោកដែរ គឺជាអ្នកមានទ្រព្យសម្បត្តិជាងគេទាំងអស់ក្នុងកោះនេះ ហើយលោកជាមនុស្សសុភាពស្លូតបូតទៀងទាត់ណាស់ ។ នាកាលខ្ញុំបានទៅជួបលោកភ្លាម លោកទទួលខ្ញុំ ដោយសេចក្តីអនុគ្រោះរាក់ទាក់ជាទីបំផុត ក្រោយពីលោកបានឧបត្ថម្ភខ្ញុំជាច្រើនផង ។

ហា – កុំអ្នកមានចិត្តទើសទាល់ញញើតអ្វីឲ្យសោះ អ្នកចង់យ៉ាងម្តេច ស្រេចហើយតែអ្នក ។

អា – តមក ដោយលោក ហាប៊ិប ជ្រាបកិច្ចការនោះច្បាស់លាស់ ហើយដោយការគិតគូរបញ្ហាទាំងនោះ គិតនាំគ្នារកតែសេចក្តីសុចរិត មិនយូរថ្ងៃប៉ុន្មាន បញ្ហាទាំងនោះ បានត្រូវស៊ីសងទូទាត់គ្នាស្រេច ។ ក្នុងពេលទំនេរ ខ្ញុំបានចេញទៅដើរកំសាន្ត មើលទីក្រុងបានឃើញរបស់ប្លែក ៗ ជាច្រើនអស្ចារ្យ ។ ខ្ញុំបានសង្កេតមើលរបៀបរបបច្បាប់សម្រាប់ប្រជារាស្ត្រ ទំនៀមទម្លាប់ កិច្ចការរបស់ពលរដ្ឋ កិច្ចរបស់រដ្ឋាភិបាល . . . . ដល់ប្រមាណជា ៥ ឬ ៦ សប្តាហ៍ ខ្ញុំគិតវិលទៅស្រុកខ្ញុំវិញ ទទួលនៅនោះ កព្វល្អ មានសំពៅមួយនៃទីក្រុងសុរ៉ាត ឋិត

នៅទីក្រុង សេវេឆិប នោះដែរ បម្រុងនឹងលើកយុថ្កាចេញដំណើរត្រឡប់ទៅវិញ ។

ថ្ងៃមួយ មុនចេញដំណើរទៅស្រុកខ្ញុំវិញ នៅពេលថ្ងៃត្រង់ ខ្ញុំបានចេញពីទីលំនៅ ទៅកាន់គេហដ្ឋានលោកមហាសេដ្ឋី ហាប៊ិច ។ ក្នុងពេលធ្វើដំណើរ ខ្ញុំប្រទះឃើញលោកស្រីមួយ ប្រកបដោយសំលៀកបំពាក់គ្រឿងអលង្ការស្រោបស្រប់ខ្លួនល្អជាពន់ពេក ហើយមានទាសីម្នាក់កាន់អីវ៉ាន់ផ្សេង ៗ ដើរតាមពីក្រោយដោយសេចក្ដីគោរពផង ។ ថ្វីបើលោកស្រីឃុំរុំពុំខ្លួបិទបាំងមុខ ដោយសំពត់ក្រាស់បន្តិចក៏ពិតមែន ខ្ញុំស្រាប់តែភាន់ភាំងស្មារតីភ្លេចខ្លួនឈរស្រឡាំងកាំង ភ្នែកទាំងពីរសម្លឹងឥតដាក់ផ្ដោះទៅលោកស្រី លោកស្រីមានរូបឆោមលោមព័ណ៌ធេតឆាយស្រស់បំព្រង ដំណើរល្វតល្វន់ ទុកចេញស្មើតដូចគេស្ទួយ ល្អហើយសមផងវិប្ញកចំឡែកពីគេឯង បើស្ដីដោយធៀបប្រៀបទៅនឹងបណ្ដាស្រីក្នុងទីនោះ លោកស្រីនេះ ដូចជាពជហង្សក្នុងហ្វូងក្អែក ។ ខ្ញុំលាន់មាត់ទាំងពុំដឹងខ្លួនថា ៖ យី ! ចុះល្អអីល្អម្ល៉េះ ! . . . . ប្រហែលជាស្រីស្នំសំណប់ទី១ របស់ព្រះករុណាមហាកជាហើយ មើលទៅ ! . . . លោកស្រីក្រឡេកសម្លឹងហើយ សម្លឹងទៀតមកខ្ញុំ ក៏ដើរហួសទៅដោយឥតមានបញ្ចេញឫកពា កិរិយាអ្វី ឲ្យខ្ញុំសំគាល់បានថា តើលោកស្រីសប្បាយចិត្តឬខឹងចំពោះពាក្យដែលខ្ញុំពោលភ្ញាក់មាត់នោះឡើយ ។ ខ្ញុំក៏នៅឈរធ្មឹងអស់

មួយសន្ទុះ ស្រាប់តែមានបុរសម្នាក់មកទីណា ខ្ញុំពុំដឹង មកចាប់ស្មាខ្ញុំអង្រួន ខ្ញុំភ្ញាក់ប៉ុនគេបោល តែខំធ្វើជាព្រងើយ សួរទៅថា៖ អ្នកមានការណ៍អ្វី? មនុស្សប្រុសនោះ ឆ្លើយដោយគោរពថា៖ ខ្ញុំបាទបានទទួលបង្គាប់អំពីលោកស្រីជាម្ចាស់ខ្ញុំ លោកឲ្យខ្ញុំប្របាទមកអញ្ជើញ សូមលោកម្ចាស់ប្រុសអញ្ជើញតាមខ្ញុំប្របាទមក ។

បើពិតជាបង្គាប់នេះ ចេញមកអំពីលោកស្រីជាម្ចាស់អ្នកមែន ខ្ញុំទទួលភ្លាមដោយរីករាយ តាមតែកាទៅជាយ៉ាងណាក៏ទៅ ៗ ចុះ! (មាត់ឆ្លើយដូច្នេះ ក្នុងទ្រូងខ្ញុំបុកហប់ ។ ។ ។ ។ ទាសាឆ្លើយមកខ្ញុំវិញទាំងដៃប្រណម្យសំពះញ័រៗ ថា: ពិតមែនហើយ! គឺជាបង្គាប់របស់លោកស្រីជាម្ចាស់ខ្ញុំ តែលោកឥតបានប្រាប់ខ្ញុំថា លោកចង់យ៉ាងណាទេ សូមលោកម្ចាស់ប្រុសករុណាអញ្ជើញ ទាន! បើលោកម្ចាស់អញ្ជើញតាមខ្ញុំប្រាកដជាលោកម្ចាស់ឥតស្តាយក្រោយទេ មើលទៅ! ។

ចំពោះរឿងនេះ គួរតែខ្ញុំគិតឃើញដល់ការចេញដំណើរ នៅថ្ងៃស្អែកនេះ មិនដូច្នោះ ខ្ញុំទៅជាភ្លុចភ្លាំងដើរតាមទាសានោះទៅវិញ ដើរទៅបត់បែន តាមផ្លូវតូចប្រកល្ហក ក៏ទៅដល់ប្រាសាទមួយយ៉ាងធំសំបើមជាទីមនោរម្យសុខុមគម្ពីរភាពយ៉ាងអស្ចារ្យ នាំឲ្យកាន់ស្មារតីមមីងមមាំង តែខ្ញុំខំប្រឹងទប់ខ្លួនមិនឲ្យទាសានោះដឹង . . . . យើងទាំងពីរនាក់ នាំគ្នាដើរចូលទៅក្នុងប្រាសាទនោះ ទៅដល់សាលមួយយ៉ាងធំ មហាធំ ខ្ញុំត្រូវ

វង់ចាំនៅទីនោះ ។ ខ្ញុំមានសេចក្ដីស្ងើចសរសើរ ដោយពិនិត្យទៅឃើញសាលនេះគុបតែងលំអល្អពន់ពេក សុទ្ធសឹងតែរបស់មានតម្លៃច្រើន មិនដឹងបើនឹងកប់ តែខ្ញុំចេះតែនឹកមមៃទៅដល់លោកស្រីជាម្ចាស់ប្រាសាទនេះ ។

ជាដំបូង ខ្ញុំឃើញស្រីៗ ជាច្រើន មានចាស់ មានក្មេង រូបកាយតែងកាយល្អ ៗ ឥតខ្មោះចូលមកក្នុងសាលនោះ តែខ្ញុំដើរណោះណោះ ធ្វើព្រងើយដូចជាឥតយកចិត្តទុកដាក់អ្វីនឹងស្រីទាំងនោះ បន្ទាប់បន្តិចតមក ពួកស្រីឲ្យសញ្ញាគ្នា ហើយនាំគ្នាលុតជង្គង់ក្រាបក្បាលចុះ នាកាលនោះ ខ្ញុំឃើញលោកស្រីជាម្ចាស់ប្រាសាទចេញមក គ្រាន់តែក្រឡេកកន្ទុយភ្នែកទៅ ខ្ញុំស្គាល់ភ្លាម យ៉ាងច្បាស់ ដោយកំពស់និងទឹកមុខសណ្ឋានទ្រង់ទ្រាយម្ដងនេះ លោកស្រីគ្មានបាំងមុខទេ ខ្ញុំឃើញកាន់តែល្អលើសមុនទៅទៀត ប្រកបដោយសំអាងសុទ្ធសឹងជាពេជ្រទាំងគ្រាប់ ៗ ចិញ្ចៀន កងក្រវិលរំលេចត្បូងគជវិទូរ្យមរកត . . . ក្លិនទាំស្មើព្រោងព្រាត សំលៀកបំពាក់សោតក៏ភ្លឺច្រាល ត្រូវនឹងលោកស្រីស្អាតល្អសោភាប្រឡង សមរម្យឥតទាស់ថែមទៀត ខ្ញុំមើលឥតដាក់ភ្នែក កាន់តាំងស្មារតី លោកស្រីដ៏មានសម្ផស្សអំណោយទាន នាងឃើញខ្ញុំសំឡឹងឥតព្រិចភ្នែកដូច្នេះ ក៏នាងញឹម ៗ អញ្ជើញទៅអង្គុយលើសុវណ្ណកោច្ចៈមួយ មានសណ្ឋានដូចមកុដកញ្ចតូច ឯពួកស្រីស្នំគម្រៀបគ្នាជាពីរជួរ ខាងស្ដាំ ខាងឆ្វេង

វែបអង្គលោកស្រី  មើលទៅដូចព្រះចន្ទពេញវង់កណ្ដាលគគនា . . ស្រេចហើយ លោកស្រីល្អសោភិនី  មានប្រសាសន៍យ៉ាងទន់ភ្លន់ថា: អ្នកប្រុសដួងចិត្តបង  សូមអ្នកមកឱបកាយជិតខ្ញុំ. . . ខ្ញុំ (អា) ក៏ដើរសន្សឹមៗ សសៀរទៅជិត  បន្ទន់កាយគោរព · · ។ ក្រៅពីរូបខ្ញុំ (ក) ប្រាកដជាមានសេចក្ដីចាំងជាក់អាក់អន់ចិត្តហើយ  អ្នកប្រុស ចំពោះអំពើឆ្គាំឆ្គងរបស់អ្នកដែលបានប្រព្រឹត្ត ក្នុងទីប្រជុំជនសាធារណៈដូច្នោះ តែខ្ញុំស្មានមើលទៅប្រហែលរូបអ្នកជាបរជន បានជាអ្នកត្រូវបានទទួលសេចក្ដីអត់ឱនលស់លាគ្រាប្រណីអំពីសំណាក់ខ្ញុំដូច្នេះ! ខ្ញុំនិយាយដោយត្រង់ទៅចុះថា  ទោះបីផ្កាយលើមេឃផង  ក៏គប្បីតែមានគំនិតដូចខ្ញុំដែរ  គឺគិតចង់ផ្ដល់សេចក្ដីសុខចំរើនឲ្យអ្នកគ្រប់ពេលវេលា . . . ។  បើអ្នកប្រុសតាំងខ្លួនអ្នកឲ្យសមរម្យនឹងខ្ញុំ  ដោយខ្សែចំណងមួយដ៏ស្មោះស្ម័គ្រ  ខ្ញុំនឹងអនុញ្ញាតអ្នកឲ្យអ្នកថើបស្រូបយកក្លិនបាទដៃខ្ញុំបាន  សេចក្ដីអនុគ្រោះនេះ  ខ្ញុំពុំដែលមានដល់បុគ្គលរូបណាមួយសោះឡើយ  រហូតមកទល់ពេលនេះ . . . ។

ដល់ឮពាក្យទន់ភ្លន់បែបនេះ  ខ្ញុំ (អា) មានបីតិព្រឺព្រួចត្រេកអរដូចអណ្ដែតខ្លួនទាំងលុតជង្គង់ទាំងមាត់ថា ឱ! សម្ដេចកញ្ញានីអើយ ! ទូលព្រះបង្គំបានឮព្រះសវនីយមែនឬទេ? ទូលព្រះបង្គំឮមែនឬទេ  នូវព្រះបន្ទូលថាស្ដេចទ្រង់ព្រះមេត្តាលើកបរជនកំសត់ម្នាក់ដល់ឋានៈដូច្នេះ? គ្រាន់តែបរជននោះលាន់មាត់ដោយពុំដឹងខ្លួនថា  គប្បីទុកព្រះអង្គក្នុងទីសក្ការៈបូជាប៉ុណ្ណោះ!

ក — សាធុ ! សេចក្ដីសណ្ដោសប្រណីកាន់តែធំឡើង ៗ ប៉ុណ្ណា សេចក្ដីយល់ឃើញថា ខ្លួនអ្នកប្រុសពុំសមរម្យនឹងខ្ញុំ កាន់តែធំឡើង ៗ ប៉ុណ្ណោះដែរ នេះបើស្ដីដោយរបៀបប្រៀបគឺយ៉ាងហ្នឹង ! ។ ចូរអ្នកប្រុសប្រាប់ខ្ញុំ តើអ្នកមកពីស្រុកណា ? ជាតិកំណើតរបស់អ្នក ? ហេតុម្ដេចបានជាអ្នកមកទីក្រុង សេរេឈឺប ?

ខ្ញុំ(អា) បានសារសព្វរៀបរាប់អស់អាថ៌សេចក្ដី អំពីរឿងខ្ញុំតាំងពីខាងដើមដល់ខាងចុង ។ នាកាលព្រះរាជធិទ្រង់បានជ្រាបថា ស្អែកនេះខ្ញុំត្រូវចុះសំពៅធ្វើដំណើរត្រឡប់ទៅបាសរ៉ាវិញ ព្រះអង្គទ្រង់មានសេចក្ដីរកើបព្រះរាជហឫទ័យខ្លាំង . . . ។

(ក) — ភ្ញា ! ម្ដេចដូច្នោះទៅវិញ ! អ្នកប្រុសចង់ចាកចោលខ្ញុំភ្លាមទៅហើយ ! បណ្ដាកោះក្នុងសមុទ្រឥណ្ឌា កោះមួយដែលល្អជាងគេនេះ តើគ្មានប្រិយភាពឃាត់អ្នក ឲ្យនៅនេះយូរបន្តិចទៅទៀតបានទេឬ ? ។

(អា) — ហា ! ខ្ញុំដកដង្ហើមធំយូរ· ហើយថា ធ្វើមេចទៅលោកម្ចាស់ខ្ញុំអើយ ? ។

(ក) — ដូច្នេះ អ្នកប្រុសនៅតែប្រកាន់ថា ត្រូវតែចេញដំណើរខានមិនបាន យ៉ាងនេះឬអី ? ។

(អា) — ទាន ! បន្ទាប់ពីបានពេបប្រទះ សេចក្ដីសង្ឃឹមប្រកប

ដោយមហាជោគជ័យមង្គលសួស្តី ដែលព្រះអង្គទ្រង់បានបង្ហើបឲ្យទូល ព្រះបង្គំឃើញលឹម ៗ ដូច្នេះ សមេ្តចពជិនីជាម្ចាស់អើយ ! ទូលព្រះបង្គំ ឥតមានចិត្តណាមួយសោះឡើយ ខុសពីព្រះរាជហឫទ័យ ។

(ក) – បើអ្នកប្រុសមានទឹកចិត្តដូច្នេះ ប្រាកដជាអ្នកនឹងនាំឲ្យ ខ្ញុំបានសប្បាយរីករាយ ខ្ញុំក៏នឹងឥតស្តាយក្រោយ ដោយបានជ្រើសរើស យកអ្នកប្រុសក្នុងគ្រាពេលនេះ ។

អា) – សមេ្តចព្រះពជិនីទ្រង់ចាប់ដៃទាញខ្ញុំ ឲ្យអង្គុយក្បែរព្រះ អង្គ លើព្រះសុវណ្ណកោច្ឆៈ . . . ។ ស្រេចហើយទ្រង់មានព្រះសវ- នីយ . . . ។

(ក) –. ខ្ញុំជាបុត្រីតែមួយរបស់ឯកឧត្តមនាយកគណៈរដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រ សេរេឆឹប ។ ឪពុកខ្ញុំ គាត់ទទួលអនិច្ចកម្មទៅ ហើយ ឥឡូវនេះ ខ្ញុំចង់សម្រេចយ៉ាងមេច ស្រេចហើយតែចិត្តខ្ញុំ ។ ម- ហាសេដ្ឋីក្នុងរដ្ឋនេះ តែងតែនាំគ្នារហេបរកខ្ញុំ តែខ្ញុំគេចខ្លួនរហូតមក ដល់ពេលនេះ ។ រូបឆោមទ្រង់ទ្រាយទឹកមុខរបស់អ្នកប្រុសជាទីពេញចិត្ត របស់ខ្ញុំ ខ្ញុំសុខចិត្តស្រឡាញ់តែប្រុសនេះមួយប៉ុណ្ណោះ ដើម្បីគ្របាញ់ វេញជីវិតយើងទាំងពីរបញ្ចូលគ្នាជាគូនឹងមួយ រួមរស់សប្បាយរីករាយ ចាយវាយ នូវសម្បត្តិទ្រព្យច្រើនឥតគណនា ដែលបិតាខ្ញុំ នាកាល លោកធ្វើការក្នុងតំណែងទាំងឡាយ លោកបានសន្សំប្រមូល ក្នុងកំឡុង

២០ឆ្នាំ ។

(អា) — ខ្ញុំសូមសំដែងអំណរគុណយ៉ាងជ្រាលជ្រៅ . . . ពាក្យផ្អែមល្ហែមរបស់លោកស្រីអំពីភោគទ្រព្យ ជារឿងបន្ទាប់បន្សំទេ ឯរឿងធំដែលទាក់ចិត្តខ្ញុំជាទីបំផុតនោះ មិនគឺអ្វីក្រៅពីរូបកល្យាណមានលំអគ្រប់លក្ខណៈផូរផង់រលីងរលង់ស្រឡះស្រស់បំព្រង របស់លោកស្រីប៉ុណ្ណោះ ហើយដែលជាទីចាប់អារម្មណ៍របស់ខ្ញុំរកភ្លេចមិនកើតក្នុងជីវិតនេះ ។

បន្ទាប់តទៅ យើងទាំងពីរបាននិយាយសំណេះសំណាលអំពីកិច្ចការផ្សេងៗ ខ្ញុំបានសង្កេតឃើញថា ធម្មជាតិបានបង្កើតនាងនេះមកសមប្រកបព្រមគ្រប់លក្ខណៈ ល្អទាំងចិត្ត ល្អទាំងរូបកាយ ។ សន្ទនាត្រូវឈប់ដោយមានទាសា ១២ នាក់ ចូលមករៀបចំប្រដាប់ប្រដាគ្រប់សព្វ សម្រាប់ពេលបាយមួយយ៉ាងធំ ។ ស្រេចហើយ នាងកនហ្វាឌ ដឹកដៃខ្ញុំទៅអង្គុយនៅតុ ដោយដាក់ខ្ញុំនៅខាងស្តាំនាង ទាំងពីរនាក់ក៏ទទួលភោជនាហាររីឯនាងកនហ្វាឌ នាងធ្វើជាអ្នកបំរើខ្លួនឯង ចាប់ម្ហូបណាឆ្ងាញ់ៗ ជាងគេជូនខ្ញុំ ដោយសេចក្តីស្និទ្ធស្នាលគួរសមជាទីបំផុត ព្រមទាំងស្រាទំពាំងបាយជូរនានាយ៉ាងប្រណីត គម្រប់ទៅនឹងអាហារនោះ ។ ។ សុរាទំពាំងបាយជូរបញ្ចេញរស្មីពីក្នុងកែវបនាំលេចមាស មានក្លិនទីងទុជារស់នាំឲ្យខ្ញុំព្រឹកេមព្រីស្សុក ក្រវល់ក្រវាយក្នុងចិត្ត ម្តង ១ រឿយ ១ វង់ក្អែកដួងប្រស្រីខ្មៅថ្លា មួលនាងកនហ្វាឌ ទៀបទាបដាក់ថ្នមបញោសអង្អែលខ្ញុំ សមនិងកត្រនាង

ញញិមម្តង ៗ ក្រអឺពក្រអៀម ម្រាមដៃលូតលូន់លើកកែវជូនមកខ្ញុំក្នុង
សេចក្តីគួរសមជាទីបំផុត . . . នៅពេលជូនអ៊ូមកខ្ញុំ នាងមានវាចា
ថា ៖ សូមបងម្ចាស់ចិត្ត ភ្លក្សល្បងមើល ចំ! .. ចំ! ... នាងសុទ្ធ
តែជិបសុរានោះ ៗ មុនល្បងមើលជាដកប ៗ ដូច្នេះសុរានោះកាន់តែមាន
ឱជារសទេវឡើងទៀតដល់ខ្ញុំ ៗ ខ្ញុំទទួលកែវហើយ ក្រេបយ៉ាងយូរនូវឱ
សថស្នេហានោះ ៗ នៅផុតពេលខាទនីយភោជនីយាហារ សេវិកាទាំង
ឡាយរបស់នាងជួបជុំគ្នាក្នុងសាល ហើយបែកមុខការគ្នា ៖ ខ្លះកាន់គ្រឿង
ដូរ្យតន្ត្រីដេញដំផ្លុំកួត ហើយតាប់ច្រៀង ខ្លះរាំផ្សំគ្នាដោយសិល្បៈទំនង
សេចក្តីច្រៀងតាតយ៉ាងប្រសប់ យ៉ាងអស្ចារ្យ ហើយជារឿយ ៗ . . ត្រង់
ចង្វាក់ដូរ្យតន្ត្រីផ្អែមល្ហែម ភ្នែកនាងកនហារ្យឧទឹងភ្នែកខ្ញុំផ្តោតផ្តិតផ្ចង់ជាប់
គ្នា លួងលោមថ្នមថ្នមទៅវិញទៅមក ត្រជាក់ក្នុងបេះដូងឆ្ងាយដង្ហើមធំ
ម្តងៗ រៀងខ្លួន . . . ៗ

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា នូ-កាន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ ។
យូរ-អ៊ុន

មិនត្រូវគិតលះបោលសោះ ឯសង្គ្រាមនោះ គឺបូច្ចឯងដែលនាំសម្លាប់បិតាអ្នក ។ ក៏ត្រូវតាំងចិត្តគិតសងសឹកវិញឲ្យបាន ទើបនឹងមានកេរ្តិ៍ឈ្មោះជាមនុស្សកតញ្ញូនឹងបិតា ឥឡូវខ្លួនអ្នកធ្លាក់មកនៅក្នុងទីនេះអស់តម្រិះនឹងគិតយកខ្លួនឲ្យរួចហើយ បើនឹងរកទៅរកឡៅជៀងចៅ-ហ្វាយស្រុកសែឈួនក៏មិនបាន បើនឹងត្រឡប់ទៅរាប់អានទៀវឡូវិញ អៀវស៊ុនក៏ចេះតែញុះញង់ឲ្យទាស់អធ្យាស្រ័យ សព្វថ្ងៃនេះទៀវឡូក៏ប្រើទាហានមកចាំស្ទាក់ផ្លូវនៅគ្រប់តំបន់អស់ហើយ អ្នកនឹងចូលទៅឆ្លើយដោះសាឲ្យទៀវឡូជឿស្ដាប់ឯណាបាន បើគ្មានផ្លូវទៅដូច្នេះ បើអ្នកនឹងត្រូវវាយទំលាយទ័ពឡៅពីឲ្យបែកក៏មិនងាយ មួយទៀតក៏មិនបានគាប់ប្រសើរនឹងទៀវឡូ ជានាយចៅហ្វាយថ្មីនោះទេ គួរតែនឹងគិតគ្នេរមើល

កុងខ្លួនឲ្យដឹងថា វេលានេះខ្លួនអ្នកមកនៅក្នុងកណ្ដាលកងក្មេងដូច្នេះ ត្រូវរិះគិតដកខ្លួនឲ្យរួចទើបពេញជាជាតិទាហានមានប្រាជ្ញា ខ្ញុំយល់ឃើញថា ដែលអ្នកនឹងដំអឺងរឹងនៅដូច្នេះ ភ័យអន្តរាយក៏គង់នឹងមានដល់ខ្លួនអ្នកជាប្រាកដ កាលគ្រាអ្នកទៅចូកងនៅតំបន់អ៊ីយ៉ហោ ទាញប្រៀបចួច បែកទៅនោះ ក៏បានសេចក្ដីលំបាកពន់ប្រមាណណាស់ គ្រានេះ ពោះបើថាអ្នកនឹងមិនស្ដាប់ ក៏គង់បានកពប្រសព្វលើសេចក្ដីអាប់យស់លើសជាងពីគ្រាមុននោះទៅទៀត នឹងចំឡៀតមើលមុខគេក៏មិនពេញភ្នែក ហេតុនេះ បានជាខ្ញុំគិតសង្វើត មកជួយរំលឹកស្មារតីដោយមេត្រីពប់អាន ។

ម៉ាឈៀវត្រូដូច្នោះក៏រសាយសេចក្ដីខឹង បោះក្រប៉េចេញពីដៃ ហើយក្រោកឡើងគំនាប់លីអ៊ុនថា ដែលអ្នកមករំលឹកខ្ញុំដូច្នេះគួរសមណាស់ តែខ្លួននៅក្នុងទីចង្អៀតចង្អល់គិតមិនយល់ច្បាស់ផ្លូវ ដែលនឹងដើរទៅទីណាបានឡើយ បើអ្នកមានចិត្តអាណិតខ្ញុំ មេត្តាជួយណែនាំបំភ្លឺចុះ ខ្ញុំនឹងទទួលធ្វើតាម ។ លីអ៊ុនតបថា ខ្ញុំនឹងជួយណែនាំរំលឹកឲ្យអ្នកយល់ក៏បានខ្លះដែរ តែថាពួកទាហានរបស់អ្នក កាន់អាវុធឈរប្រចាំនឹងធ្វើអន្តរាយខ្ញុំ ។ នឹងថាការអ្វីបាន ។ ម៉ាឈៀវក៏បណ្ដេញពួកទាហានទាំងនោះ ឲ្យចេញទៅខាងក្រៅអស់ ។ លីអ៊ុនតបថា ឡើងពីនោះ ចំពោះជាពូជព្រះកជវង្សព្រះចៅហៀនគេប្រាកដ ប្រកបទាំងចិត្តអធ្យាស្រ័យធូរទូលាយ គិតតែចំនុកបម្រុងផែនដីឲ្យបានសេចក្ដីសុខតទៅ ដូចជាម៉ាថេងចិតាអ្នកកាល

រស់នៅ ៗ ក្នុងស្រុកហ៊ីតោនោះ ក៏បានពិគ្រោះត្រូវគំនិតគ្នានឹងឡៅពីថា នឹងជួយគ្នាកំចាត់ចូនចេញ ព្រោះឃើញថាជាគូសត្រូវរាជសម្បត្តិពិតណាស់ ការនោះក៏គិតពុំទាន់បានសម្រេច ឥឡូវត្រូវអ្នកមកចំពាក់ខ្លួននៅដូច្នេះ បើប្រសិនជាអ្នកនឹងរិះគិតទៅនៅនឹងឡៅពីវិញ ដើម្បីនឹងជួយបំពេញគំនិតគិតធ្វើការបំបាត់ចូនចេញ អ្នកក៏បានរលាយសេចក្តីទុក្ខទោម្នេញនោះអស់ទៅ ទាំងឈ្មោះសំឡេងអ្នកក៏នៅល្បីរជាប្រាកដទៅមុខទៀត ៗ

ម៉ាឈៀវបានឮដូច្នោះ ក៏មានអំណរណាស់ ឲ្យហៅខ្លួនអៀវប៉េកដែលជាទាហានទៀវឡូចូលមក ហើយក៏ចាប់សម្លាប់មួយរំពេច ហើយកាត់យកក្បាលអៀវប៉េកនោះនាំទៅជាមួយនឹងលីអ៊ុន នឹងទាហានទាំងពួងទៅឯទីតយហៃបាំងគួន ៗ ឯឡៅពីដឹងថា ម៉ាឈៀវលុះក្នុងបាយលីអ៊ុន បានចូលខ្លួនមកជាមួយនឹងលីអ៊ុនដូច្នោះ ក៏មានសេចក្តីត្រេកអរពន់ប្រមាណណាស់ ចេញទៅទាំទទួលម៉ាឈៀវនាំចូលមក ៗ ម៉ាឈៀវគំនាប់ឡៅពីហើយថា ដែលខ្ញុំបាទបានមកនៅនឹងលោកជាអ្នកមានសតិបញ្ញាដូច្នេះ ខ្ញុំបាទមានអំណរណាស់ ទុបមាដូចនៅក្នុងទីងងឹត មានគេនាំឲ្យមកដល់ទីដែលភ្លឺ នោះអ្វីជារបស់លោក ត្រូវការប្រើខ្ញុំបាទចុះ ខ្ញុំបាទនឹងសុំទទួលយកកាសាធ្វើឲ្យគ្រាតែអស់ជម្រិះប្រាជ្ញា នឹងសតិកំឡាំងផងជីវិតមិនគិតស្តាយឡើយ ៗ ខណៈនោះ ស៊ុនខៀនដឹងថា ម៉ាឈៀវចូល

ទៅនៅទឹងឡៅតីហើយ ក៏លាអៀវស៊ុនត្រឡប់ទៅប្តឹងឡៅតីគ្រប់ប្រការ ។

ឡៅតីបង្គាប់បេងគាត់ទឹងហាក់ជុន ឲ្យនៅរក្សាបន្ទាយ ហើយឲ្យរៀបចំទាហានលើកត្រឡប់ទៅទឹងកាយយកស្រុកសែឈួន លុះទៅដល់ស្រុកគឹមកុក ជូឡុង ហានគុងជឹង ក៏ចេញមកទទួលឡៅតីចូលទៅក្នុងស្រុក ហើយជំរាបថា ឥឡូវឡៅជៀងប្រើឡៅយួន ទឹងម៉ាហ៊ានលើកទាហានមកជាច្រើន ខ្ញុំបាទទឹងសុំអាសាចេញទៅកាត់ក្បាលនាយទាហានទាំងពីរមកជូនលោក ៗ ឡៅតីក៏បើកឲ្យទៅ ។ ជូឡុងជិះសេះនាំទាហានចេញពីស្រុកគិមកុក បានច្បាំងទឹងនាយទាហានទាំងពីរ ។ ឯឡៅតីនៅក្នុងស្រុកឲ្យរៀបតុលៀងម៉ាឈៀវនៅមិនទាន់នឹងសម្រេច ទទួលឃើញជូឡុងយួរក្បាលឡៅយួនចូលមកជូនឡៅតី ៗ ម៉ាឈៀវឃើញដូច្នោះ ក៏ភ័យស្លុត គិតថា ជូឡុងនាយទាហាននេះ មានថ្វីដៃរហ័សរហួនណាស់ ម៉ាឈៀវក៏រឹតតែគោរពក្រែងឡៅតីពន់ប្រមាណណាស់ ទើបជំរាបឡៅតីថា ឯស្រុកសែឈួននោះ លោកកុំបាច់លើកកងទ័ពទៅឲ្យបានសេក្តីលំបាកនឿយព្រួយដល់ទាហានឡើយ ខ្ញុំបាទទឹងសុំទទួលអាសាចូលទៅនិយាយទឹងឡៅជៀងឲ្យចេញមកចំណុះចុះចូលលោកដោយស្រួល បើឡៅជៀងរឹងទទឹង ខ្ញុំបាទទឹងម៉ាតាយជាប្អូនទឹងលើកទាហានទៅវាយយកស្រុកសែឈួនឲ្យបាន ៗ ឡៅតីបានឮដូច្នោះក៏មានអំណរណាស់ លុះលៀងអាហារស្រេចបរិបូណ៌ហើយ នាយទាហានទាំងពួងក៏លាទៅកាន់ទីសំ

ណាក់ ។

ខណៈនោះ មានទាហានដែលមកក្នុងកងទ័ពឡៅយួន ម៉ាហ៊ននោះ បែករត់គេចខ្លួនទៅប្រាប់ឡៅជៀងគ្រប់ប្រការ ឡៅជៀងដឹងដូច្នោះ ក៏ភ័យខ្លាំងណាស់ ឲ្យបិទទ្វារស្រុកជិតទាំងអស់ ហើយឲ្យទាហានរក្សាសើនបន្ទាយជុំវិញម៉ាំមួនណាស់ ។ ខណៈនោះ ម៉ាឈៀវក៏លាឡៅពីលើកកងទ័ពតម្រង់ទៅស្រុកសៃឈួន ។

ទាហានដែលនៅលើសើនបន្ទាយ ឃើញម៉ាឈៀវលើកមកជិតកំផែង ក៏ចូលទៅប្រាប់ឡៅជៀងថា ឥឡូវម៉ាឈៀវលើកកងទ័ពមកព័ទ្ធជិតគូកំផែងស្រុកហើយ ។ ឡៅជៀងក៏ឡើងទៅមើលសើនបន្ទាយទតួល ម៉ាឈៀវក្រឡេកទៅឃើញ ក៏ស្រែកអញ្ជើញឡៅជៀងឲ្យងាកមុខចេញមកនឹងសុំនិយាយការផង ។

ឡៅជៀងឮហើយ ក៏អើតមុខចេញទៅ ហើយស្រែកថា អ្នកឯងចង់និយាយការអ្វីក៏ឲ្យស្ដីមកចុះ ។ ម៉ាឈៀវថា ពីដើមយើងលើកទាហានទៀវឡូទៅធ្វើសង្គ្រាមនឹងឡៅពី ប្រាថ្នានឹងជួយការពារស្រុកលោក តែអៀវសុងញុះញង់ទៀវឡូឲ្យមានសេចក្ដីសង្ស័យនឹងយើង ។ ទើបនាំទាហានទៅនៅនឹងឡៅពី ឥឡូវគ្រូវលោករិះគិតជាប្រញាប់ ចេញមកចំណុះចុះចូល លើកស្រុកប្រគល់ជូនឡៅពីដោយល្អចុះ ទើបនឹងផុតសេចក្ដីអន្តរាយ មិនមានដល់ខ្លួនលោក ហើយបណ្ដារាស្ត្រក្នុងស្រុក ក៏នឹងបាន

សេចក្តីសុខតទៅ បើលោកនៅតែរឹងទទឹង យើងនឹងអាសាឡៅពី វាយយកស្រុកសែឈូនឲ្យទាល់តែបាន ។

ឡៅដៀងឮដូច្នោះ ក៏ឲ្យស្លុតស្មារតីភ័យ ទាល់តែដួលចុះសន្លប់នៅទីនោះ ។ ទីប្រឹក្សានឹងទាហានទាំងពួងក៏នាំគ្នាគ្រាហ៍ឲ្យដឹងស្មារតីឡើងវិញ ។ ឡៅដៀងប្រឹក្សានឹងទាហានទាំងពួងថា ការទាំងនេះ យើងមិនបានត្រិះរិះឲ្យហ្មត់ជាមុន ទើបបណ្តាលឲ្យចាញ់ប្រៀបគេ លុះនឹងប្រឹងក្នុងវេលានេះ បេះតែស៊ូច្បាំងទៅ ការក៏កាន់តែប្រទាល់ខ្លួនដល់ប៉ុណ្ណោះទៅហើយ យើងអាណិតអាណាប្រជានុរាស្ត្រ ព្រោះថានឹងមិនឲ្យបានសេចក្តីក្តៅក្រហាយ គិតនឹងចេញទៅសុំចំណុះលើកស្រុកឲ្យឡៅពី តើអ្នកទាំងអស់គ្នានឹងយល់ឃើញប្រការម្តេច ។ តាំងហោឆ្លើយថា ទាហានដែលមានក្នុងស្រុកយើងក៏ច្រើនដែរ គិតឃើញចំនួន ៣ ម៉ឺនប៉ាយ ទាំងស្រូវអង្ករស្បៀងអាហារក៏បរិបូណ៌ល្មម នឹងដប់លៀងទាហានគ្រប់គ្រាន់បានក្នុងពេល ១ ឆ្នាំ ដែលលោកនឹងលើកស្រុកទៅឲ្យឡៅពីដោយងាយនេះមិនគួរសោះ ។

ឡៅដៀងតបថា បិតាយើងនិងខ្លួនយើង បានមកនៅក្នុងស្រុកនេះដល់កំណត់ ២០-៣០ ឆ្នាំហើយ បណ្តារាស្ត្រអ្នកស្រុកក៏មិនដែលបានទុក្ខលំបាក ពីព្រោះអ្វី គ្រានេះឡៅពីលើកកងទ័ពមកធ្វើអន្តរាយអាណាខេត្រហើយ ទន្ទ្រានចូលមកដល់ដែនស្រុកយើងហើយ រាស្ត្រទាំងឡាយក៏

បានសេចក្ដីក្ដៅក្រហាយគ្រប់ ៣ ឆ្នាំមកហើយ ខ្ញុំយើងមានចិត្តអាណិតអាណាប្រជានុរាស្ត្រណាស់ បានជារិះគិតនឹងលន់តួចំណុះទៀត ។ ទៅដីវទីប្រឹក្សាឆ្លើយថា លោកគិតនេះត្រូវណាស់ ព្រោះខ្ញុំបាទបានឃើញផ្កាយសម្រាប់ស្រុកសៃឈូននោះបាត់ទៅ មានផ្កាយមួយដួងធំរះឡើងដ៏ខ្ពស់ មានពន្លឺរស្មីភ្លឺដូចព្រះចន្ទ មានផ្កាយតូចៗ ហោមរោមជាបរិវារហោមរោមច្រើនណាស់ ហើយខ្ញុំបាទបានឮកូនក្មេងក្នុងស្រុកសៃឈូនច្រៀងក្មេងលេងថា បើអ្នកណានឹងចង់ពិសាអាហារថ្មី ចូរចាំម្ចាស់ផែនដីថ្មីមកឈរស្រុកនេះចុះ ទើបបានសមតាមសេចក្ដីប្រាថ្នា ។

អ៊ុយគួន ឡៅប៉ា បានឮដូច្នោះ ក៏ខឹងណាស់ កន្ទ្រាក់យកក្របីមកកាន់គិតនឹងសម្លាប់ទៅដីវចេញ ឡៅជៀងក៏ស្ទុះទៅឃាត់ ទទួលមានបំរើចូលទៅប្ដឹងឡៅជៀងថា ទៅចេងដែលជាបាល័ដ្ឋខែត្រនោះ លបរត់ចេញទៅនៅខាងឡៅតីទៅហើយ ឡៅជៀវបានឮដូច្នោះ ក៏រឹតតែតូចចិត្តអន្ទុយយំ ហើយត្រឡប់ចូលទៅខាងក្នុង លុះវេលាព្រឹកឡើងនាយទ្វារចូលមកប្ដឹងឡៅជៀវថា ឥឡូវឡៅតីលើកកងទ័ពមកពីគយហៃបាំងគួនមកហើយ បោះទ័ពនៅខាងក្រៅស្រុកយើងនេះ ឲ្យកាន់យ៉ុងចូលមករកលោក ឡៅជៀវបង្គាប់ឲ្យបើកទ្វារស្រុកទទួលចូលមក នាយទ្វារក៏ចេញបើកទ្វារទទួល ។

ឯកាន់យ៉ុងនោះក៏ជិះសេះចូលទៅដល់កណ្ដាលស្រុក ដ៏នពី

ឃើញដូច្នោះក៏ខឹងណាស់ កន្ទ្រាក់ក្របីក្រវែងឡើង ហើយស្រែកឲ្យកាន់យ៉ុងថា ខ្ញុងឯងជាជាតិថោកទាប ហេតុម្ដេចទើបហ៊ានជិះសេះចូលមកដល់កណ្ដាលស្រុក ឯងមើលងាយថា ក្នុងស្រុកសៃឈ្មួននេះ គ្មានមនុស្សល្អទេឬ? ទើបព្រះហើនដូច្នេះ ៗ កាន់យ៉ុងឮដូច្នោះក៏ចុះពីលើសេះ តំនាប់សួរឈ្មោះគ្នាទៅវិញទៅមក ហើយកាន់យ៉ុងថា ខ្ញុំបាទជាមនុស្សប្រមាទ ហ៊ានជិះសេះចូលមកដល់កណ្ដាលស្រុក អ្នកកុំប្រកាន់ទោសឡើយ ៗ ជិនពីក៏សោយកំហឹង ទើបនាំកាន់យ៉ុងចូលទៅជួបទីងឡៅជៀង ៗ កាន់យ៉ុងឧទតំនាប់ហើយជំរាបថា ឡៅពីនោះជាមនុស្សមានស្មារតី មានចិត្តអាណិតករុណាបណ្ដារាស្ត្រច្រើនណាស់ ទើបលោកតាំងចិត្តលំអុតលំទុនដល់ឡៅពីដោយសុចរិត ហើយឡៅពីក៏ទីងមិនបានប្រទូសរ៉ាយដល់លោកទេ ៗ

ឡៅជៀងឮដូច្នោះ ក៏បណ្ដាលចិត្តគិតញញើតកោតខ្លាចឡៅពីខ្លាំងណាស់ ទើបនិយាយជាពាក្យដាច់ថា អ្នកពល់គ្នាកុំបីនិយាយរឿងទទឹងទីងយើងឡើយ យើងទីងទំនុកបម្រុងអាណាប្រជារាស្ត្រទាំងពួងឲ្យបានសេចក្ដីសុខតទៅ ក្នុងគ្រានេះ យើងទីងចេញទៅលន់តួសុំចំណុះចុះចូលឡៅពី ទើបឲ្យរៀបតុលៀងកាន់យ៉ុង ឲ្យបរិភោគអាហារ លុះលៀងរួចហើយ ក៏យកត្រាសម្រាប់ងារឱ្យអស់របស់ទ្រព្យដែលល្អត្រកាលនាំពាហានចេញទៅតំនាប់ឡៅពីក្នុងបន្ទាយ ៗ ឡៅពីឃើញដូច្នោះ ក៏ចុះទៅ

ទាញដៃឡៅជៀងឲ្យឡើងទៅអង្គុយជាក់លើ ឡៅពីយំហើយនិយាយនឹងឡៅជៀងថា ខ្លួនយើងនេះ មានចិត្តសុចរិតគិតនឹងទំនុកបំរុងផែនដីឲ្យបណ្តារាស្ត្របានសេចក្តីសុខតទៅ ដែលខំមកធ្វើទាំងម៉្លេះ ដោយសេចក្តីចាំចិត្ត លុះនឹងមិនគិតធ្វើដូច្នេះ ការដែលគិតទុកនោះក៏មិនបានហេតុ អ្នកចូរឃើញដល់ផែនដីដែលបានសេចក្តីក្តៅក្រហាយនោះចុះ កុំបីប្រកាន់ទោសដល់យើងឡើយ ។

ឡៅជៀងតបថា ធម្មតាអ្នកដែលខំទំនុកបំរុងផែនដីនោះ ទោះដូចម្តេចក៏ត្រូវតែធ្វើដូចជាលោកនោះទាំងអស់ ខ្ញុំបាទឥតគិតអ្វីសោះឡើយ ហើយក៏លើកត្រាសម្រាប់ការនោះជូនទៅឲ្យ ឡៅពី ព្រមទាំងបណ្ណាការទាំងពួង ឡៅពី ទទួលហើយ ក៏មានសេចក្តីសោមនស្សសាទរអរពេកណាស់ ។ ឡៅជៀង ក៏អញ្ជើញឡៅពី នឹងបណ្តាសេនាពាហនចូលទៅក្នុងស្រុក ។ ខណៈនោះ មនុស្សម្នាមហាជនទាំងឡាយទាំងពួងបណ្តាដែលមានក្នុងកំឡុងស្រុកសែឈួនទាំងប៉ុន្មាន បានក្រឡេកឃើញឡៅពីចូលទៅ ក៏ស្រុះស្រួលបបួលគ្នាអុជធៀនធូបបូជាពីការឡៅពី តាមលំដាប់មាគាទាំងសងខាងរៀងទៅ ។ ឡៅពីនោះ លុះក្រឡេកឃើញដូច្នោះ ក៏មានចិត្តត្រេកអរណាស់ កាលបើយាត្រាទៅដល់ទីគេហដ្ឋាននិយាយការរាជការហើយ ក៏ឃើញទីប្រឹក្សារបស់ឡៅជៀងទាំងប៉ុន្មានចូលទៅគ្រៀមចាំគំនាប់ឡៅពីទាំងអស់ បាត់តែឈ្មោះអ៊ុយ គួន ១ ឡៅ

ប៉ា ១ មិនបានចូលទៅគំនាប់ឡើយ ។

ពួកទាហានឡៅពីដឹងដូច្នោះ ក៏បបួលគ្នានឹងទៅចាប់អ៊ុយ គួន នឹងឡៅប៉ា សម្លាប់ចេញ ៗ ឡៅពីឮពាក្យទាហាននិយាយគ្នាដូច្នោះ ក៏ក្រែងបង្អាប់ថា ឲ្យសម្លាប់ឲ្យអស់ទាំងពូជពង្សវង្សញាតិកានិងស្ត្រីគ្រប់ក្រុមពួកកុំឲ្យសល់ ហើយឡៅពីក៏ស្រូតតាមទាហានទាំងពួងទៅ លុះទៅដល់មុខអ៊ុយ គួន ឡៅប៉ា ឡៅពីក៏ឃាត់ហាមទាហានទាំងពួង ឲ្យបង្អង់ឈប់ ហើយក៏ក្លែងស្រែកប្រកាសឲ្យឮច្បាស់ទៅដល់អ៊ុយ គួន ឡៅប៉ាថា ឯអ៊ុយ គួន នឹងឡៅប៉ានោះ គេជាមនុស្សមានសេចក្ដីស័ត្យពិតត្រង់នឹងនាយចៅហ្វាយណាស់ គួរយើងនឹងចិញ្ចឹមរក្សាទុកតទៅ កុំបីអស់អ្នកទាំងពួងធ្វើអន្តរាយគេឡើយ សូម្បីតែអំបោះមួយសរសៃឬម្ជុលមួយ ក៏មិនត្រូវធ្វើឲ្យបាត់បង់របស់គេជាដាច់ខាត បើនរណាមិនស្ដាប់ពាក្យយើងហាមឃាត់ទេ យើងនឹងចុះទោសដល់ជីវិត ។ អ៊ុយគួន ឡៅប៉ា ឮឡៅពីស្រែកប្រកាសដូច្នោះក៏ពិគ្រោះគ្នាថា ឡៅពីនេះគេជាមនុស្សល្អ មានអធ្យាស្រ័យសុភាពរៀបរយដូចពាក្យគេនិយាយមែន ៗ គួរតែយើងនឹងចូលទៅធ្វើកងការផងចុះ លុះនិយាយហើយក៏នាំគ្នាចេញទៅគំនាប់គោរពឡៅពី ៗ ក៏ទទួលកេះកាយ ហើយនាំខ្លួនអ៊ុយគួន នឹងឡៅប៉ា ទៅទីលំនៅ រួចក៏តាំងឲ្យនៅកន្លែងដដែលតាមដើម ។

ខុនបេងនិយាយនឹងឡៅពីថា ស្រុកសៃឈួនសព្វថ្ងៃនេះ បានកប

ទាបស្រួលបួលហើយ ដែលនឹងឲ្យមានចៅហ្វាយស្រុក ២ រូបនោះ មិនគួរសោះ គួរតែឲ្យឡៅជៀងទៅស្រុកគេឯងដីវវិញ ។ ឡៅពីថា ខ្លួនយើងទើបតែនឹងបានស្រុកសែឈួននេះ បើនឹងឲ្យឡៅជៀងទៅនៅស្រុកគេឯងដីវ មនុស្សទាំងពួងនឹងគរហានិន្ទាថា យើងក្លែងបញ្ឆោតឡៅជៀងឲ្យខូចស្រុកសែឈួន ។

ខុងបេងថា ឯឡៅជៀងនេះជាមនុស្សមិនចេះដឹងគុណសោះ ហើយថែមទាំងខូចចិត្តគំនិតទៅហើយ បើយើងនឹងទុកឲ្យនៅក្នុងស្រុកនេះជាមួយយូរទៅ ខ្លាចមានគេនាំញុះញង់ គង់នឹងស្តាប់ជឿពាក្យគេ ខ្លួនលោកក៏គង់នឹងបានសេចក្តីខានចិត្តទៅថ្ងៃក្រោយ ។ ឡៅពីយល់ឃើញត្រូវ លុះកន្លងមកមួយថ្ងៃ ឡៅពីក៏ឲ្យអញ្ជើញឡៅជៀង ទៅលៀងអាហារហើយនិយាយថា យើងនឹងឲ្យអ្នកទៅនៅឈរស្រុកកងអាន់ ។ ឡៅជៀងក៏ទទួលប្រសាសន៍ ។ ឡៅពីក៏ឲ្យធ្វើត្រាតាំង ។ ឡៅជៀងជាជីវរុយចុងកុន ឲ្យនាំគ្រប់គ្រួសារចេញទៅឈរស្រុកកងអាន់ ដែលឡើងស្រុកឡាំគុន ក្នុងដែនស្រុកគេឯងដីវ ។ ឡៅពីប្រគល់ត្រាតាំងឲ្យឡៅជៀងហើយថា មាសប្រាក់នឹងទ្រព្យសម្បត្តិរបស់អ្នកទាំងប៉ុន្មាន ចូរនាំយកទៅទាំងអស់ចុះ ។ ឡៅជៀងទទួលយកត្រាសម្រាប់ការ ហើយក៏នាំគ្រប់គ្រួនឹងបក្សពួកទៅនៅស្រុកកងអាន់ ។

ឯឡៅពីកាលបានស្រុកសែឈួនហើយ បណ្តាទីប្រឹក្សានឹងសេនា

ទាហានរបស់ខ្ញុំជឿនទាំងប៉ុន្មាន ខ្ញុំក៏តាំងឲ្យធ្វើជាមុខមុខមន្ត្រីខាង រដ្ឋបាលទាំងអស់ តែហួតបេងនោះ តាំងឲ្យធ្វើបាលរដ្ឋស្រុកសែឈូន ហើយខ្ញុំក៏តាំងខុនបេងជាអាចារ្យធំសម្រាប់ប្រៀនប្រដៅ តាំងគួនអ៊ូ ឲ្យជាចៅហ្វាយស្រុកគេងជ័រ ឯទៀតហ៊ុយ ជូឡុង អ៊ុយអៀន ហងគុង ម៉ាឈៀវ ៤ នាក់នេះ ជានាយទាហានឯក ស៊ុនខៀន កាន់យ៉ុង ប៊ិតុក ប៊ីហង គួនប៉េង ជីវតេង ខ្ញុំហង លៀវហួ ម៉ាចេក ម៉ាលៀង បៀងអួន អ៊ីបៀ ទាំងនេះជានាម៉ឺនធំតូចតាមលំដាប់ ហើយឲ្យបំណាច់ រង្វាន់ជាច្រើនគ្រប់ៗគ្នា តែជីវតេង គួនប៉េង ហត់ឲ្យទៅនៅជួយធ្វើរាជការគួនអ៊ូឯស្រុកគេងជ័រ ហើយខ្ញុំក៏ចាត់មាស៥០០ ជញ្ជីង ប្រាក់ ១០០០ ជញ្ជីង អ៊ុំប៉េះ៤ ពាន់ម៉ឺន ព្រៃយ៉ាងល្អ១ពាន់ផាប់ ឲ្យទាហាននាំទៅឲ្យជាបំណាច់គួនអ៊ូ ឯស្រុកគេងជ័រ ដើម្បីឲ្យចែកបណ្ដាកូនទាហានតាមបំណាច់ ។

លុះវេលាព្រឹក ខ្ញុំក៏ឲ្យបើកជង្រុកស្រូវ នឹងបំណាក់ត្រីសាច់ស្បៀងអាហារចែកអ្នកស្រុក នឹងរេហ៍ពលតាមសមគួរគ្រប់ៗគ្នា ។ អស់បណ្ដាមនុស្សម្នាមហាជនមុខមន្ត្រី កំឡុងក្នុងស្រុកសែឈូន ក៏មានសេចក្ដីសុខនិរទុក្ខបាកកយន្ដកយសប្បាយគ្រប់ៗគ្នា ។ ខ្ញុំក៏បង្គាប់ថា ជីស្ងួនច្បារស្រែចម្ការ ដែលគ្មានម្ចាស់កាន់កាប់ចុះបញ្ជីជាកម្មសិទ្ធិទេ ត្រូវបែងឲ្យបានពន្ធទៅជាសម្រាប់មុខមន្ត្រីតូចធំ ដើម្បីជាកម្លាំងរាជការ ។ ជូឡុង

ឆ្លើយថា ស្រុកសែឈូននេះមានសឹកសង្គ្រាម បណ្តាកស្ត្រីខ្ចាត់ខ្ចាត់ពីភូមិលំនៅ មិនបានធ្វើស្រែចម្ការ ដែលនឹងយកពន្ធពីស្រែចម្ការមកថែងរំលែកចែកឲ្យនាម៉ឺនមុខមន្ត្រីនោះ បណ្តាកស្ត្រីនឹងបានសេចក្តីក្តៅក្រហាយណាស់ គួរលោកឲ្យប៉ាវគងប្រាប់កស្ត្រីថា ភូមិលំនៅនឹងសួនច្បារស្រែចម្ការរបស់អ្នកណា ក៏ឲ្យមកនៅធ្វើរកទទួលទានតាមដើមចុះ ទើបកស្ត្រីនឹងបានសេចក្តីសុខតទៅ ។ ទៀតពីយល់ត្រូវផង ទើបឲ្យប៉ាវគងប្រាប់កស្ត្រីតាមពាក្យជូឡុង ។

ទៀតពីនិយាយ នឹងខុងបេងថា ច្បាប់សម្រាប់ស្រុកសែឈូននោះ យើងត្រូវលើកចោលចេញ ហើយសុំឲ្យលោកតាក់តែងច្បាប់ថ្មីសម្រាប់ស្រុកឡើងវិញ ហើយឲ្យកាត់ទោសមនុស្សដែលប្រព្រឹត្តខុសឲ្យធ្ងន់ជាងច្បាប់ចាស់ ទើបមនុស្សនឹងខ្លាចរអាប្រតិបត្តិតាម ស្រុកទេសទើបនឹងបានរាបទាបតទៅ ។ ហួតបេងថា កាលគ្រាព្រះចៅហាន់កោចោបានសោយរាជសម្បត្តិនោះ ស្តេចឲ្យតែងច្បាប់កាត់ទោសមនុស្សដែលប្រព្រឹត្តខុសទុកជាប្រមាណ លុះដល់ព្រះចៅហៀនតេគ្រានេះ ទ្រង់ឲ្យតែងច្បាប់កាត់ទោសឲ្យធ្ងន់ជាងច្បាប់ចាស់ បានជាមនុស្សកើតក្តៅក្រហាយជាចលាចលដូច្នេះ ហេតុនេះ គួរឲ្យលោកត្រិះរិះបន្ថយទោសឲ្យស្រាលទៅវិញ តាមច្បាប់បុរាណនឹងបានសេចក្តីសុខធូរទូលាយ ។

ខុងបេងថា ពាក្យដែលអ្នកនិយាយនេះគួរប្រពៃណាស់ ព្រោះតាំង

ពីគ្រាព្រះចៅហាន់កោចោ ឲ្យតែងច្បាប់ទុកនោះ មិនមែនទុកមកដល់ព្រះចៅហៀនតេទេ វេលានេះនាម៉ឺនមីងបណ្ដារាស្ត្រគ្រប់អាណាខេត្តក្នុងប្រទេសចិន ក៏មិនបានសេចក្ដីសុខសោះឡើយ ដូចឡើងជៀងសោត ក៏ជាមនុស្សមិនសូវមានជម្រះវិជ្ជា នឹងរកអំណាចអាជ្ញាសក្ដិសិទ្ធិមិនបាន បើនឹងទំនុកបំរុងនរណា ៗ ក៏រើសយកតែមនុស្សអាប់ឥតប្រាជ្ញាដូចគ្នា តាំងធ្វើជានាម៉ឺនធំ ម្ល៉ោះហើយមនុស្សនោះក៏មានចិត្តកំរើបលះបង់ច្បាប់សម្រាប់ផែនដី មានតែសេចក្ដីកំហែងសក្ដិសិទ្ធិអាណាប្រជានុ-រាស្ត្រតាមអំណាចចិត្ត រាស្ត្រក៏បានសេចក្ដីក្ដៅក្រហាយ ដោយហេតុដ្បិតអំពើដូច្នោះឯង បានជាត្រូវអន្តរាយខូចស្រុកទេសទៅ គ្រានេះ យើងត្រូវលើកច្បាប់ចាស់ចោលចេញ តាំងបទបញ្ញត្តច្បាប់ថ្មីបំពេញឲ្យធ្វើទោសមនុស្ស ដែលប្រព្រឹត្តខុសនោះម៉ិញឲ្យធ្ងន់សហ័ស ដើម្បីឲ្យមនុស្សទាំងអស់នោះ ខ្លាចញញើត នឹងប្រតិបត្តិតាមច្បាប់តទៅ បើនាហ្មឺននឹងបណ្ដារាស្ត្រឯណា ឃើញនរណាប្រព្រឹត្តខុសអំពីបញ្ញត្តច្បាប់ក៏ត្រូវចុះទោសតាមទោសានុទោស បើឃើញនរណាប្រព្រឹត្តសេចក្ដីគាប់ប្រសើរក៏ត្រូវឲ្យបានបំណាច់រង្វាន់ឲ្យមានឡើង ទើបនឹងបានថ្កុំថ្កើងស្រុកទេសជាវឌ្ឍនាការតទៅ ៗ ហ្លួងចេងបានស្ដាប់ក៏គាប់ចិត្ត គិតយល់ត្រូវប្រាកដ ទុនគំនាប់ឡៀតី នឹងខុងចេង ទទួលតាមប្រសាសន៍គ្រប់ប្រការ ៗ

ខុងចេង ក៏តែងរចនាច្បាប់តាមទម្លាប់ទំនៀមផែនដី នឹងកាត់ទោស

ឲ្យធ្ងន់ជាងប្រក្រតីបុរាណ ហើយបញ្ចុះទៅឲ្យគ្រប់ខេត្តខ័ណ្ឌ ដែលនៅក្រោមបង្គាប់ទាំង ៤ ដំបន់ ជាខេត្តសម្រាប់ឡើងស្រុកសៃឈួខ ទៅហ្វាយស្រុកទាំងអស់នោះ នឹងទៅហ្វាយស្រុកសម្រាប់ត្រី-ចត្វា ដែលឡើងត ៗ ជាលំដាប់គ្នាទាំងមួយរយប៉ាយដំបន់ ក៏ទទួលធ្វើតាមបញ្ញត្តទាំងអស់ បណ្តាកស្ត្រគ្រប់ខេត្តខ័ណ្ឌ ក៏បានសេចក្តីសុខសប្បាយក្សេមក្សាន្តលើសជាងពីដើម ។

លុះនៅមកថ្ងៃមួយ ឡៅតីចេញនិយាយរាជការ មានបំរើស៊ើបការចូលទៅជូនថា ជ្រៀតមានបំរើគួនអ៊ូ គួនប៉េងនឹងចូលមកគំនាប់លោកឡៅតីក៏ឲ្យហៅគួនប៉េងចូលទៅ គួនប៉េងគំនាប់ហើយជំរាបថា គួនអ៊ូបិតាខ្ញុំបាទ មានសេចក្តីត្រេកអរព្រះតេជព្រះគុណ ដែលលោកបានឲ្យបំណាច់រង្វាន់ទៅនោះច្រើនណាស់ បានជាប្រើខ្ញុំបាទឲ្យចូលមកជំរាប ខ ១ បិតាខ្ញុំបាទផ្តាំមកថា ជ្រៀតបានឮដំណឹងល្បីទៅដល់ថា ម៉ាឈៀវនោះជាមនុស្សមានថ្វីដៃខ្លាំងពូកែណាស់នឹងរកនរណាស្មើគ្មាន បិតាខ្ញុំបាទនឹងសុំមកតស៊ូកម្លាំង នឹងម៉ាឈៀវល្បងមើល ។

ឡៅតីឮដូច្នោះក៏ភ័យភ្ញាក់ស្មារតី ទើបប្រឹក្សានឹងខុនបេងថា គួនអ៊ូនឹងចង់មកល្បងថ្វីដៃនឹងម៉ាឈៀវនោះ បើអ្នកឯណាភ្លាត់ចំណាប់ទទំថយក៏គង់នឹងជាប់ពាក្យបាទគ្នា តទៅ លោកនឹងគិតប្រការម្តេច ៗ ខុនបេងថា លោកកុំព្រួយ ខ្ញុំនឹងធ្វើសំបុត្រផ្ញើទៅឲ្យគួនអ៊ូឲ្យរសាយសេចក្តីឥច្ឆា

ព្យាបាទនោះចេញ ៗ ទៀតថា ការនេះបើបង្អង់ឲ្យយូរ មុខជាគួនអ៊ីទីនមកដល់ នាំឲ្យព្រួយលើសឡើងទៀត បើដូច្នេះ គួរតែលោកធ្វើសំបុត្រផ្ញើទៅឲ្យទាប់ កុំឲ្យគួនអ៊ីមកដល់មុន ៗ ខុនចេនក៏ធ្វើសំបុត្រសរសើរលើកគួនអ៊ីគ្រប់ប្រការ រួចប្រកបិទស្រោមប្រគល់ឲ្យគួនប៉េង ៗ ទទួលហើយក៏លាត្រឡប់ទៅវិញ លុះទៅដល់ស្រុកកេងជីវ ក៏យកសំបុត្រនោះទៅជូនគួនអ៊ី ហើយពណ៌នាសេចក្ដីឲ្យស្ដាប់គ្រប់ប្រការ ៗ

គួនអ៊ីទទួលសំបុត្រទៅមើលឃើញសេចក្ដីថា ខុនចេនឲ្យពរមកគួនអ៊ីទីបុងគុនឲ្យបានជ្រាប ព្រោះយើងដឹងថា អ្នកមានសេចក្ដីវិតក្ក ព្រោះម៉ាឈៀវនោះ មិនគួរទេ ព្រោះថ្វីដៃម៉ាឈៀវនោះប្រៀបស្មើនឹងថ្វីដៃទៀវហ៊ុយ ប្អូនអ្នក ឯការកល់សឹកសង្គ្រាមនោះ ថ្វីដៃអ្នកលើសជាងម៉ាឈៀវច្រើនណាស់ ដែលអ្នកនឹងលះបង់ស្រុកកេងជីវទៅល្បងថ្វីដៃគ្នានឹងម៉ាឈៀវនោះ មិនស្រួលទេ ក្រែងមានសេចក្ដីអន្តរាយដល់ស្រុកកេងជីវខ្លួនអ្នកក៏ត្រូវមានទោសខុស ព្រោះធ្វេសប្រហែស ការនេះសូមឲ្យអ្នកត្រិះរិះតាមគួរសិនទើបបាន លុះមើលចប់សេចក្ដីហើយ គួនអ៊ីក៏មានសេចក្ដីត្រេកអរគិតថា ខុនចេននោះសមគួរជាគ្រូអាចារ្យប្រដៅយើងបានណាស់ ទើបយកសំបុត្រនោះបង្ហាញអស់នាម៉ឺនមុខមន្ត្រីនឹងទាហានទាំងពួងហើយថា ពីដើមយើងគិតវិតក្កព្រោះឮថា ម៉ាឈៀវមានថ្វីដៃខ្លាំងពូកែណាស់ គិតនឹងចង់ទៅល្បងថ្វីដៃមើល ឥឡូវយើងក៏អស់សេចក្ដីវិតក្កហើយ ៗ

## សាមក្កុកខ្សែ៥៥

តាំងពីស៊ិនគួនដឹងថា ឡៅពីវ៉ាយបានស្រុកសែឈួន ស៊ិនគួនគិតនឹងវ៉ាយយកស្រុកកេងដីវវិញ ហេតុដល់ចូចូវ៉ាយយកបានស្រុកហាន់តុងតាំងទៀវឡូឲ្យឈរជាចៅហ្វាយស្រុកដូចដើម ។

ឯស៊ិនគួននោះ លុះដឹងកិត្តិស័ព្ទថា ឡៅពីវ៉ាយយកបានស្រុកសែ-ឈួនហើយ ឲ្យឡៅជៀងទៅនៅស្រុកកងអានជូហ្ចោះ ក៏ពិគ្រោះនឹងទីប្រឹក្សាទាំងពួងថា ឡៅពីខ្ចីស្រុកកេងដីវទុកជាទីអាស្រ័យ យើងត្រូវតែឲ្យទារយកស្រុកនោះមកឡើងស្រុកយើងវិញ បើឡៅពីវឹងទទឹងមិនព្រមឲ្យ យើងនឹងលើកកងទ័ពទៅវ៉ាយយកឲ្យខាងតែបាន អ្នកទាំងពួងនឹងយល់ឃើញដូចម្តេច ? ។

ទៀវចៀវឆ្លើយថា សឹកសង្គ្រាមទើបតែនឹងស្ងប់ ពលទាហានក៏កំពុងហត់នឿយណាស់ ដែលនឹងលើកកងទ័ពទៅវ៉ាយយកស្រុកកេង-ដីវទៀតនោះ សុំឲ្យលោកឈប់បង្អង់សិន ខ្ញុំបាទនឹងរិះគិតឲ្យឡៅពីលើកបង្វិលស្រុកកេងដីវឲ្យលោកវិញតាមស្រួល ។ ស៊ិនគួនសួរថា គំ-និតអ្នកនឹងរិះគិតប្រការម្តេច ។ ទៀវចៀវថា ដែលឡៅពីគិតធ្វើការទាំង-ពួងនោះ ក៏ប្រស្រ័យសេចក្តីរិះគិតរបស់ខុងបេង ឯខុងបេងនោះជាប្អូនជូ-កាត់គិន សុំឲ្យលោកយកគ្រប់គ្រួរបស់ជូកាត់គិនដាក់គុកទុក ហើយឲ្យ

ជូកាត់កីនទៅនិយាយនឹងខុនបេង ឲ្យបង្វិលស្រុកកេងដីវជូនលោកវិញជា
ប្រញាប់ កំមុខជានឹងបាន ។

ស៊ិនគួនតបថា ជូកាត់កិននោះ ជាមនុស្សទៀងត្រង់សុចរិតណាស់ ហើយគ្មានទោសខុសពីអ្វីផង បើយើងនឹងធ្វើទោសដូចពាក្យអ្នកថា កាលណាជូកាត់កិននឹងមិនចូលចិត្តគិតខឹងនឹងយើង ម្យ៉ាងទៀត មនុស្សទាំងពួង ក៏គង់នឹងតរហានិន្ទាយើងទៀត ។ ទៀវបៀវថា បើជាលោកនឹងត្រូវធ្វើការនេះ មានតែត្រូវហៅជូកាត់កិនមកប្រាប់ឲ្យដឹងជាមុនថា ដែលលោកយកគ្រប់គ្រួវមកធ្វើទោសនោះគឺកលឧបាយទេ កុំឲ្យតូចចិត្តឡើយ ជូកាត់កិនជាមនុស្សមានសតិបញ្ញា ក៏គង់នឹងយល់តាមអធ្យាស្រ័យលោកមិនខានស៊ិនគួនយល់ឃើញត្រូវ ក៏ឲ្យហៅជូកាត់កិនមកនិយាយតាមដំណើរឧបាយដែលគិតនោះឲ្យស្ដាប់គ្រប់ប្រការ ហើយក៏តែងជាសំបុត្រប្រគល់ឲ្យជូកាត់កិនកាន់យកទៅ ឯគ្រួសារជូកាត់កិនទាំងប៉ុន្មានក៏ឲ្យយកទៅដាក់គុកឃុំទុកទាំងអស់ ជូកាត់កិនក៏កាន់សំបុត្រនោះលាស៊ិនគួនចេញទៅស្រុកសៃឈួន លុះទៅដល់ហើយក៏ប្រាប់អ្នកចាំទ្វារ ។ អ្នកចាំទ្វារ ក៏ចូលទៅជំរាបឡៅពីថា ឥឡូវជូកាត់កិននឹងចូលមករកលោក ។

ឡៅពីដឹងសេចក្ដីក៏សួរខុនបេងថា ជូកាត់កិនបងលោកដែលមករកយើងក្នុងវេលានេះដោយហេតុអ្វីអេះ ។ ខុនបេងថាដែលបងខ្ញុំមកនេះប្រាកដជាស៊ិនគួនប្រើឲ្យមកទារយកស្រុកកេងដីវហើយ ឡៅពីសួរថា

បើដូច្នោះលោកនឹងឲ្យនិយាយការនេះថាម្ដេច ខុនបែនក៏ចូលទៅខ្សឹបប្រាប់ឡៅពីឲ្យឆ្លើយតបតាមពាក្យខុនបែនពន្យល់សព្វគ្រប់ ហើយខុនបែនក៏ចេញទៅតំនាប់ទទួលដូកាន់កិននាំទៅឈប់ឯផ្ទះទទួលភ្ញៀវ ដូកាត់កិនក៏ក្លែងធ្វើជាយំខ្សឹកខ្សួលយូរណាស់ ខុនបែនឃើញដូច្នោះក៏ក្លែងសួរថា អ្នកបងមកឃើញមុខខ្ញុំជាប្អូនហើយ ហេតុម្ដេចត្រឡប់ទៅជាយំវិញ គួរតែត្រេកអរសោទរ ដូកាត់កិនថា ឥឡូវនេះ ស៊ិនគួនចាប់យកភរិយាបុត្ររបស់បងទៅដាក់គុកអស់ទៅហើយ មុខជានឹងដល់នូវសេចក្ដីស្លាប់ទាំងអស់គ្នា ខុនបែនថា កើតហេតុទាំងនេះ ព្រោះស៊ិនគួនចង់បានស្រុកកេងដីវទៅវិញ បានជាធ្វើដូច្នេះ ហើយធ្វើជាសួរថា ដែលអ្នកបងអញ្ជើញមកនេះ ស៊ិនគួនប្រើមកឬតែមកទេ? ដូកាត់កិនថា ស៊ិនគួនប្រើឲ្យបងមក យកទាំងសំបុត្រនេះមកជូនឡៅពីផង ។ ខុនបែនថា បើការតែប៉ុណ្ណេះ កុំឲ្យអ្នកបងព្រួយ សឹមយើងនាំគ្នាទៅជួបនឹងឡៅពី ហើយខ្ញុំនឹងនិយាយឲ្យឡៅពីបង្វិលស្រុកកេងដីវឲ្យស៊ិនគួនវិញ ។ ដូកាត់កិនឮដូច្នោះក៏ត្រេកអរណាស់ ។

ខុនបែនក៏នាំដូកាត់កិនចូលទៅគំនាប់ឡៅពី ហើយដូកាត់កិនក៏ជូនសំបុត្រនោះទៅឲ្យឡៅពី ។ ទទួលយកសំបុត្រនោះទៅមើលឃើញសេចក្ដីថា ពីដើមឡៅពីបានខ្ចីស្រុកកេងដីវទុកជាទីអាស្រ័យ ឥឡូវដល់សន្យាហើយ ត្រូវឲ្យឡៅពីបង្វិលស្រុកនោះឲ្យស៊ិនគួនវិញ ឡៅពីឃើញ

សេចក្ដីដូច្នេះ ក៏ធ្វើជាខឹងប្រឡោតខ្លាំង តាំងតែឆ្លើយតបទៅជូកាត់កិនតាម ពាក្យខុងបេងពន្យល់ថា កាលថ្ងៃមុន ស៊ិនគួនបានលើកប្អូនក្រមុំឲ្យយើង យកធ្វើជាភរិយា យើងក៏បាននាំយកទុកស្រុកកេងជីវ លុះយើងលើក ទ័ពមកវាយយកស្រុកសៃល្អួន ស៊ិនគួនក៏មិនមានកោតក្រែងចិត្ត គិតប្រើ ឧបាយមកបញ្ឆោតយកភរិយាយើងទៅទុកឯស្រុកកាំងតាំងវិញ ឥឡូវនៅ ទទូចឲ្យមកពង់ទារយកស្រុកកេងជីវទៀត គឺស៊ិនគួនគិតធ្វើការទាំងម៉្លេះ ដូចជាមិនជាអ្នកធំសោះ ហេតុនេះ គួរយើងលើកទ័ពទៅវាយយកស្រុក កាំងតាំងឲ្យបាន ៗ

ខុងបេងបានស្ដាប់ហើយ ក៏ធ្វើជាយំយែកនិយាយនឹងឡៀវពីថា វេលានេះ ស៊ិនគួនឲ្យចាប់ភរិយាបុត្រនិងស្ម័គ្របក្សពួកបងខ្ញុំទៅដាក់គុក ទុកទាំងអស់ ប្រាថ្នាតែនឹងទារយកស្រុកកេងជីវឲ្យបាន បើមិនបានក៏នឹង ធ្វើអន្តរាយបងខ្ញុំ និងភរិយាបុត្រឲ្យបានសេចក្ដីព្រួយលំបាកដល់នូវជីវិត អន្តរាយ បើបងខ្ញុំបាទស្លាប់ខ្វាត់ខ្វាយវេលាណា ខ្លួនខ្ញុំបាទក៏គង់នឹងមរណា វេលានោះជាប្រាកដ ហេតុនេះ សូមឲ្យលោកអាណិតអាសូរបង្វិលស្រុក កេងជីវឲ្យស៊ិនគួនចុះ ដើម្បីជាផ្លូវសង្គ្រោះឲ្យជូកាត់កិននិងខ្ញុំបាទ បានគង់ ជីវិតនៅឃើញមុខគ្នាតទៅ ៗ ឡៀវពីក៏ធ្វើជាព្រងើយ បែបមិនឮមិន ដឹងមិនយល់ ៗ ខុងបេងក៏រឹតតែយំសោកជាទុក្ខទូលអង្វរឡៀវពីយូរ ណាស់ ៗ ឡៀវពីថាស្រុកកេងជីវនោះ មានខែត្រសម្រាប់ឡើង

ដល់ ៦ មណ្ឌល យើងនឹងឲ្យខូចដូចម្តេចបាន តែយើងយោគយល់ដល់មុខទាំងពីរនាក់ ដែលខទូបមកនិយាយហើយ យើងត្រូវឲ្យស្រុកទៀង-សា ១ ស្រុកឡេងឡេង ១ និងស្រុកហ៊ុយអៀង ១ ទាំង ៣ តំបន់នេះបែងឲ្យស៊ិនគួនពាក់កណ្តាលចុះ ៗ

ខុងបេងឮដូច្នោះ ក៏ធ្វើជាក្រេកអរពេកពេកនិយាយថា បើលោកមានមេត្តាដូច្នោះហើយ សុំឲ្យធ្វើយសំបុត្រឲ្យដូកាត់កិនទៅដល់គួនអ៊ូឲ្យដឹងជាមុន ទើបបានបែងស្រុក ៣ តំបន់នោះឲ្យទៅស៊ិនគួន ៗ ឡៅពីក៏ធ្វើសំបុត្រជាសេចក្តីថា ឡៅពីព្រមលើកស្រុកទៀងសា ១ ស្រុកឡេងឡេង ១ ស្រុកហ៊ុយអៀង ១ ដែលឡើងស្រុកកេងជីវនោះឲ្យទៅជាចំណុះរបស់ស៊ិនគួនចុះ លុះតែងសំបុត្រនោះរួចហើយ ក៏ប្រគល់ឲ្យដូកាត់កិនហើយថា បើកាលណាអ្នកនឹងទៅរកគួនអ៊ូនោះ ចូរឲ្យលំអុតលំទុននិយាយដោយសុភាព ព្រោះចិត្តគួនអ៊ូនោះរួសរហ័សណាស់ សូម្បីខ្ញុំយើងឯងក៏ក្រែងខ្លាចណាស់ដែរ ៗ ដូកាត់កិនទទួលប្រសាសន៍និងសំបុត្រហើយក៏លាត្រឡប់ទៅស្រុកកេងជីវ ហើយឲ្យពាហាននាំចូលទៅជួបនឹងគួនអ៊ូពណ៌នារឿងរ៉ាវឲ្យគួនអ៊ូស្តាប់គ្រប់ប្រការ ជូនទាំងសំបុត្រនោះឲ្យទៅគួន-អ៊ូមើល ៗ

គួនអ៊ូឃើញសំបុត្រដូច្នោះក៏និយាយថា ឡៅពី ទៀវហ៊ុយនឹងយើងក៏បានរួមចិត្តជីវិតមួយនឹងគ្នា ប្រាថ្នាធ្វើការដកាបមកបំរុងនឹងជួយរក្សាផែន

ដីឲ្យបានសេចក្ដីសុខ អាណាខេត្រទាំងអស់នេះ ក៏សុទ្ធតែជាផែនដីរបស់ព្រះចៅហៀនតេ តែវេលានេះមានមនុស្សអ្នកមានថ្វីដៃខ្លាំងពូកែច្រើនយល់ឃើញថា ផែនដីកើតចលាចលគ្រប់មណ្ឌលខេត្រខណ្ឌ បានជានាំគ្នាកកាំងតាំងតារខេត្រខណ្ឌផែន ជាកំណាន់របស់ខ្លួននោះទុកតាមចំណែកៗ ឯធម្មតាអ្នកធ្វើរាជការ ជាចៅហ្វាយខេត្រខណ្ឌនិមួយៗ នោះក៏ត្រូវតែតាំងចិត្តជាសុចរិតក្នុងរាជការ បើមានព្រះតម្រាស់បង្គាប់មកយ៉ាងណា ក៏ត្រូវឲ្យពិចារណាមើលតាមគួរនឹងអធ្យាស្រ័យ បើឃើញត្រូវ គួរឲ្យធ្វើតាម បើឃើញទាស់ខុសពីបទបំរាមត្រង់ប្រការឯណា ត្រូវឲ្យមកប្ដឹងទៅអ្នកកាន់កាប់រាជការជាធំឲ្យបានជ្រាប ឥឡូវ ទៀតពីបងយើងនឹងឲ្យបង្វិលស្រុក ៣ ដំបន់ទៅឲ្យស៊ុនគួននោះ យើងយល់ឃើញមិនគួរ យើងមិនព្រមធ្វើតាមបង្គាប់ទៀតពីទេ អ្នកចូលទៅប្រាប់ស៊ុនគួនឲ្យដឹងចុះៗ

ដូកាត់កិនឧញ្ញគួនអ៊ូថាដូបោះក៏បេះតែអង្វរថា សូមឲ្យលោកអាណិតឈេងយល់ទៅដល់ខ្ញុំចុះ ស៊ុនគួនឃើញថា ខ្ញុំនឹងខុងបេងជាបងប្អូននឹងគ្នា បានជាគេចាប់យកបុត្រភរិយារបស់ខ្ញុំទៅដាក់គុកទុក ហើយប្រើខ្ញុំឲ្យនាំសំបុត្រមកទារស្រុកកេងជីវឲ្យបាន បើមិនបានបង្វិលស្រុកនេះឲ្យវិញទេ គេឲ្យសម្លាប់បុត្រភរិយារបស់ខ្ញុំទាំងអស់ គួនអ៊ូថាដែលស៊ុនគួនធ្វើដូច្នេះជាកលឧបាយបញ្ឆោត ប្រាថ្នាតែនឹងទារយកស្រុកកេងជីវឲ្យបាន ដូកាត់កិនថា លោកចរចាដូច្នេះដូចជាមនុស្សមិនបេះគិតអ្វីសោះ ។

គួនអ៊ី ឮដូច្នោះក៏ខឹងណាស់ ហូតក្រចែចេញហើយថា បើយើងមិនគិតយល់ដល់ខុនចេង ក៏នឹងត្រូវកាត់ក្បាលអ្នកឥឡូវនេះចេញ តាំងពីនេះតទៅ អ្នកកុំមកនិយាយមើលងាយប្រមាថយើងដូច្នេះទៀត បើមិនស្តាប់ទេយើងក៏មិនអត់ឡើយ ។ គួនប៉េងឮហើយ ក៏ចូលទៅអង្វរឃាត់ថា បិតាកុំអាលធ្វើវិវដូច្នេះឡើយ គួរឃើញយល់ទៅដល់ខុនចេងចុះ ។ គួនអ៊ីតបថា ដូកាត់កិននេះ ព្រហើនមើលងាយយើងពេកណាស់ បើកុំតែយើងយោគយល់ទៅដល់ខុនចេង នឹងកាត់ក្បាលចេញឥឡូវនេះ ។ ដូកាន់កិនបានសេចក្តីអប្បយសណាស់ ក៏វិលត្រឡប់ទៅស្រុកសៃឈួនវិញ ខណៈនោះខុនចេង យុំនាំទាហានចេញទៅត្រួតគយ ។ ដូកាន់កិន ក៏ចូលទៅជួបនឹងឡៅពី ហើយយំរៀបនិយាយឲ្យឡៅពីស្តាប់ តាមហេតុដែលគួនអ៊ីប្រុងនឹងសម្លាប់នោះគ្រប់ប្រការ ។

ឡៅពីតបថា យើងបានប្រាប់អ្នកហើយថា ចិត្តគួនអ៊ីនោះកាចរួសរាស់ណាស់ អ្នកចូលវិលត្រឡប់ទៅប្រាប់ស៊ុនគួនដោយល្អសិនចុះថា សូមឲ្យបង្អង់ទំរាំយើងលើកទ័ពទៅវាយយកស្រុកហាន់តុង បានវេលាណា យើងនឹងយកគួនអ៊ី ឲ្យទៅឈរធ្វើជាចៅហ្វាយស្រុកហាន់តុង នឹងប្រគល់ស្រុកកេងជីវ ព្រមទាំងស្រុកដែលយើងទាំងប៉ុន្មានឲ្យស៊ុនគួនវិញទាំងអស់ ។ ដូកាត់កិនមិនដឹងតបថាយ៉ាងណា ក៏លាត្រឡប់វិលទៅស្រុកកាំងតាំងវិញ លុះទៅដល់ហើយក៏ពណ៌នារឿងរ៉ាវឲ្យស៊ុនគួនស្តាប់ តាម

ដែលឡៅពីនិងគួនអ៊ូថា ប្រការម្តេច ៗ នោះគ្រប់ប្រការ ៗ

ស៊ិនគួនស្តាប់ហើយក៏ខឹងណាស់ថា ដែលឡៅពីនិងគួនអ៊ូនិយាយឲ្យយ៉ាងម្តេចនោះ គឺជាសេចក្តីចេញមកពីគំនិតខុងបេងជាប្អូនអ្នកឯងទាំងអស់ ៗ ជូកាត់កិនឆ្លើយថា ខុងបេងក៏ជាទុក្ខទោមស្យអាណិតខ្ញុំបាទណាស់ដែរ បានទាំងជួយអង្វរលន់តួទោសឡៅពី ៗ ក៏បង្គាប់ទៅគួនអ៊ូឲ្យបង្វិលស្រុក ៣ ដំបន់ជូនមកលោក លុះខ្ញុំបាទទៅប្រាប់គួនអ៊ូ ៗ ខឹងប្រកែកមិនព្រមឲ្យ ហើយគិតនឹងសម្លាប់ខ្ញុំបាទទៀត ។ ស៊ិនគួនថា គេបានចេញពាក្យថា នឹងបង្វិលស្រុក ៣ ដំបន់ឲ្យយើងហើយ យើងត្រូវតែចាត់ទាហាន ដែលមានថ្វីដៃខ្លាំងពូកែទៅឈររក្សាស្រុកទាំង ៣ ដំបន់នោះទុក ដើម្បីនឹងមើលកលការគួនអ៊ូ តើនឹងធ្វើប្រការម្តេច ៗ

ជូកាន់កិនថា លោកគិតនោះគួរប្រពៃណាស់ ស៊ិនគួនក៏បង្គាប់ឲ្យបើកលែងបុត្រភរិយាជូកាន់កិនដែលឃុំនោះចេញអស់ ហើយចាត់ប្រើទាហានដែលមានថ្វីដៃទៅឈររក្សាស្រុកទាំង ៣ ដំបន់ តែនាយទាហានទាំង ៣ នាក់ដែលទៅនោះ វិលមកប្តឹងស៊ិនគួនថា បានលើកគ្នាទៅជិតនឹងដល់ស្រុកទាំង ៣ អន្លើនោះហើយ គួនអ៊ូលើកពលទៅដេញកំចាត់កំចាយ មិនព្រមឲ្យចូលទៅក្នុងស្រុកនិមួយ ៗ បាន បើខំបំពានបំពារចូលទៅតាមពេលការ ឃើញថា គួនអ៊ូនឹងប្រហារជីវិតឲ្យអន្តរាយទាំងអស់គ្នា ។

ស៊ិនគួនឮដូច្នោះក៏ខឹងណាស់ទើបឲ្យគេហៅឡោសុកចូលមកសួរថា

ឡៅពីបាទខ្ញុំស្រុកកេងដីវទុកប្រស្រ័យនោះ បានប្តេជ្ញាថាបើកាលណាវាយបានស្រុកសែឈួនហើយ នឹងបង្វិលស្រុកកេងដីវឲ្យយើងវិញ ខ្លួនអ្នកក៏ចូលជាអ្នកធានាក្នុងរឿងនេះ ឥឡូវឡៅពាកយបានស្រុកសែឈួនហើយ បានចេញសំបុត្រប្រាប់ទៅគួនអ៊ូឲ្យបង្វិលស្រុក ៣ ដំបន់ឲ្យយើង ឥឡូវគួនអ៊ូរឹងទទឹងមិនព្រមឲ្យ ថែមទាំងធ្វើទុក្ខបុកម្នេញដោយវាលោភទៀត ខ្លួនអ្នកជាធានាតើធ្វើលេងទេឬ ?

ឡៅសុកថា ការនេះមិនមែនខ្ញុំបាទនឹងស្ងៀមព្រងើយទេ ដែលគួនអ៊ូធ្វើដូច្នេះ ខ្ញុំបាទនឹងសុំគិតធ្វើកលឧបាយមួយ ១ មុខជានឹងបានស្រុកកេងដីវដោយងាយ ស៊ុនគួនសួរថា ឧបាយអ្នកប្រការម្តេច ? ឡៅសុកថា ខ្ញុំបាទគិតឲ្យទៅតាំងបន្ទាយនៅមាត់ពាមស្រុកយើង ឲ្យទាហានពួនបង្កប់ចាំគ្រប់ច្រក ហើយឲ្យទៅអញ្ជើញគួនអ៊ូមកស៊ីលៀង ខ្ញុំបាទនឹងនិយាយទារយកស្រុកកេងដីវវិញដោយល្អ បើគួនអ៊ូរឹងទទឹងនឹងឲ្យទាហានដែលបង្កប់នោះចាប់ខ្លួនសម្លាប់ចេញ បើគួនអ៊ូមិនមកតាមសេចក្តីខ្ញុំបាទទេ សឹមលោកលើកកងទ័ពចេញទៅច្បាំងយកស្រុកកេងដីវចុះ ។

(នៅមានត)

# រឿងល្បើកឡាហ្វុងតែន

ប្រែពីភាសាបារាំងដោយ លោក ដេង-ជ្រឿវ

---

## ៨៦) យាយចាស់នឹងស្រីបំរើពីរនាក់

យាយចាស់ម្នាក់ មានស្រីបំរើពីរនាក់ ។ នាងទាំងពីរ ត្រូវតែរវៃនឹងការអម្បោះពល់ថ្ងៃ គ្មានឈប់ទំនេរ ។ យាយចាស់គ្មានព្រួយអ្វី ក្រៅតែពីចែកមុខការ ឲ្យនាងទាំងពីរធ្វើប៉ុណ្ណោះ ។

កាលណាព្រះអាទិត្យបំរុងនឹងរះ រហាត់ត្រូវតែវិល ខ្នារអម្បោះត្រូវឲ្យមាន គឺថា ត្រូវតែឲ្យមានការធ្វើ ឥតឈប់ឈរឲ្យសោះ ។

កាលណាមេឃក្រហមឯកើត មាន់ឈ្មោលចង្រៃមួយ ចាប់រងាវភ្លាម យាយចាស់យើង ចង្រៃជាងមាន់ទៅទៀត ចាប់ស្លៀកសំពត់ក្អួលក្រខ្វក់ គួរឲ្យខ្ពើម អុជចង្កៀងកាន់ដើរតម្រង់ទៅគ្រែដែលស្រីបំរើទាំងពីរកំពុងតែ-ដេក តាមអំពើចិត្តនឹងយ៉ាងឆ្ងាញ់ ។

នាងមួយ បើកភ្នែកម្ខាងព្រឹមៗ នាងមួយ លាតសន្ធឹងដៃម្ខាង ហើយ នាងទាំងពីរនេះក្តៅចិត្តពេក ទើបនិយាយរអ៊ូៗ ថា: អាមាន់ចង្រៃ! អាឯងទៀងតែស្លាប់មិនខាន! ថាដូច្នោះហើយ ស្រីបំរើទាំងពីរលបទៅចាប់មួលកមាន់ស្លាប់ ដែលជាសត្វសម្រាប់រងាវដាស់ពល់ព្រឹកនោះ ។

ឃាតកម្មនេះ មិនបានធ្វើឲ្យមានការចំរើនអ្វីដល់ខ្លួនសោះ មានតែទំលាក់ទម្ងន់មកលើអាត្មាលើសមុនថែមទៀត គឺថាផ្ទុយទៅវិញ ស្រីបំរើ

ទើបតែនឹងដេក យាយចាស់ ដោយបារម្ភខ្លាចក្រែងហួសម៉ោង ក៏ដើរកុប ៗ ដូចជាម្រេញគង្វាល ពេញពាំងផ្ទះ (ដាស់ស្រីបំរើឲ្យឡើងធ្វើការ) ។

ដូច្នេះហើយ បានជា: ជាញឹកញយណាស់ កាលណាគេគិតនឹងដោះខ្លួនឲ្យចេញរួចពីកិច្ចការដ៏អាក្រក់អ្វីមួយ ( ជួនកាល ) គេរឹតចូលកាន់តែជ្រៅលើសមុនថែមទៀត ភស្តុតាងដូចស្រីបំរើទាំងពីរដែលត្រូវទទួលរង្គាន់ធ្ងន់លើសមុន ។

លុះអត់ពីមាន់ទៅ (គ្មានអ្វីជាគោល) យាយចាស់ធ្វើឲ្យស្រីបំរើមានការលំបាកច្រើនហួសប្រមាណ ។

## ៨២ – មនុស្សព្រៃនិងអ្នកដំណើរ

នៅរូងភ្នំ មនុស្សព្រៃនិងកូន រៀបចំនឹងបរិភោគបបរ ដោយលើកភាជន៍ហុត ។

គេបានឃើញប្តីប្រពន្ធនិងកូន នាំគ្នាអង្គុយលើស្មៅគ្មានកម្រាល គ្មានសំពត់អ្វីឡើយ តែទាំងអស់គ្នា បរិភោគយ៉ាងឆ្ងាញ់ ។

(ឱកាសនោះ) មានអ្នកដំណើរម្នាក់ រងាញាក់ ចូលទៅក្នុងរូងនោះ ដើម្បីសុំជ្រកភ្លៀង ។ មនុស្សព្រៃក៏អញ្ជើញអ្នកដំណើរឲ្យបរិភោគបបររបស់ខ្លួនជាមួយ ។ ភ្ញៀវក៏ព្រមទទួលតាមសេចក្តីអញ្ជើញឥតបង្អែបង្អង់ ។ ដំបូង អ្នកនេះ កំដៅម្រាមដៃខ្លួន ដោយផ្លុំខ្យល់ដាក់ ៗ រួចគាត់ផ្លុំដាក់ចានបបរក្តៅ ដែលគេហុចឲ្យមកនោះទៀត ។

ឃើញដូច្នោះ មនុស្សព្រៃនឿងឆ្ងល់ ទើបសួរថា «អ្នកធ្វើយ៉ាងនេះ ប្រយោជន៍អ្វី ? » ។ – អ្នកដំណើរឆ្លើយប្រាប់ថា «ផ្លុំដំបូង ដើម្បីកំដៅដៃរបស់ខ្ញុំ ផ្លុំម្ដងទៀត ដើម្បីធ្វើឲ្យបបរត្រជាក់» ។ – មនុស្សព្រៃពោលថា : «អ្នកត្រូវបន្តដំណើររបស់អ្នកទៅទៀតចុះ» ។ ឱទេព្ដាអើយ ! ខ្ញុំមិនអាចអាស្រ័យដំណេកក្នុងផ្ទះជាមួយអ្នកបានទេ ។

ចូរថយចេញ លោកអ្នកណា ដែលមានមាត់អាចផ្លុំក្ដៅផង ត្រជាក់ផងបាន ។

## ៨៨ – ខ្លាឃ្មុំនឹងមិត្តពីរនាក់

មិត្តពីរនាក់ ដោយត្រូវការប្រាក់ជាប្រញាប់ ក៏ទៅនិយាយលក់ស្បែកខ្លាឃ្មុំនៅរស់ (មិនទាន់ចាប់បាន) នឹងអ្នកជិតខាង ជាអ្នកជំនួញស្បែកសត្វមានកេម ។ លុះនិយាយត្រូវថ្លៃគ្នា ព្រមទាំងចុះកិច្ចសន្យាហើយ មិត្តទាំងពីរក៏ចេញស្វែងរកខ្លាឃ្មុំ ហើយប្រទះឃើញមួយយ៉ាងធំ រត់ជាក់មក អ្នកទាំងពីរភ័យស្លុត ដូចជារន្ទះបាញ់ត្រូវ ។

អាម្នាក់ស្ទុះឡើងទៅពួនឯចុងឈើទាន់ អាម្នាក់ទៀត ភ័យត្រជាក់ខ្លួនស្រេងគិតអ្វីមិនទាន់ ក៏ដេកផ្កាប់មុខធ្វើជាស្លាប់ ព្រោះបានឮគេនិយាយថា ខ្លាឃ្មុំមិនសូវដែលស៊ីខ្មោចស្លាប់ស្រាប់ទេ ។ ខ្លាឃ្មុំ ឃើញមនុស្សដេកស្រប៉ាប់នៅដី ក៏ស្មានជាមនុស្សស្លាប់មែន ។ ដោយខ្លាចគេបោកបញ្ឆោត វាដើរទៅចាប់បង្វិលទៅ បង្វិលមក ដើម្បីពិនិត្យមើល

ហើយថែមទាំងយកច្រមុះទៅជិតហិតដង្ហើមមើលផង ៗ ខ្លាឃ្មុំនិយាយថា: ប្រាកដជាខ្មោចមែន ត្រូវតែថយចេញ ព្រោះធុំក្លិនហើយ ៗ ពោលដូច្នោះហើយ ខ្លាឃ្មុំដើរចូលទៅក្នុងព្រៃជិតខាងបាត់ទៅ ៗ

មិត្តម្នាក់ដែលឡើងដើមឈើ ត្រឡប់ចុះមកវិញ រត់ឆ្ពោះទៅរកមិត្តរបស់ខ្លួន ហើយនិយាយថា: ជាការអស្ចារ្យពេកណាស់ហើយ ដែលគ្រាន់តែបានភ័យប៉ុណ្ណោះ រួចគេសួរបន្ថែមថា: អើ! ចុះម្ដេចទៅ ស្បែកវានោះ? វាខ្សឹបដាក់ត្រចៀកមិត្តឯង ថាម្ដេចខ្លះ? ព្រោះឃើញវាចូលទៅជិតណាស់ ហើយចាប់បង្វិលមិត្តឯងនឹងជើងវាផង ៗ

- វាបានប្រាប់អញថា: មិនត្រូវលក់ស្បែកខ្លាឃ្មុំ ដែលគេមិនទាន់សម្លាប់នោះទេ ៗ

## ៨៩ – សត្វសិង្ហនឹងព្រានព្រៃ

មនុស្សអំនួតម្នាក់ ជាអ្នកលេងខាងបាញ់ ទើបនឹងបាត់ឆ្កែពូជល្អមួយ ហើយសង្ស័យក្រែងសិង្ហចាប់ស៊ី ក៏ទៅជួបនឹងអ្នកគង្វាលពពែ រួចសួរថា: សូមមេត្តាប្រាប់ខ្ញុំឲ្យដឹងនូវទីកន្លែងនៃអាមេចោរលួចឆ្កែខ្ញុំផង ខ្ញុំនឹងសងសឹកឆ្កែខ្ញុំឲ្យបាន ៗ

អ្នកគង្វាលពោលថា: នឹ វានៅក្នុងភ្នំនុះ ខ្ញុំតែងជូនចៀមមួយឲ្យដល់វាទុកជាសួយ រាល់ខែ បានជាខ្ញុំអាចគោចរបាននៅទីវាល តាមសេចក្ដីប្រាថ្នា ហើយខ្ញុំក៏បានសុខ អំពីរឿងនេះដែរ ៗ

ក្នុងពេលដែលជនទាំងពីរនាក់ កំពុងតែសន្ទនាគ្នា ស្រាប់តែសិង្ហមួយចេញមក ដើរយ៉ាងរហ័សមករក ។

អ្នកអំនួតស្ទុះរត់ក្លូត ហើយស្រែកបន់ថា : ឱព្រះគុណទេព្ដាអើយ ! សូមលោកមេត្តាជួយបង្ហាញប្រាប់ខ្ញុំ នូវកន្លែងណាមួយ ដែលអាចឲ្យខ្ញុំរួចរស់ជីវិតបាន ។

ដែលហៅថា មានសេចក្ដីក្លាហានដ៏ពិតក្រដនោះ គឺនៅត្រង់ដែលមានគ្រោះភ័យ ជាបន្ទាន់នោះឯង ។ ឧទាហរណ៍ ដូចអ្នកអំនួត ដែលជាខ្លួនស្វែងរកសិង្ហ ស្រាប់តែផ្លាស់ប្ដូរពាក្យសំដី រួចស្ទុះរត់ភ្លាមនៅពេលដែលឃើញសិង្ហមក ។

> គួរគប្បីឲ្យមួយរយ តែមិនគួរធ្វើឲ្យកើតវិវាទមួយទេ នេះជាមតិនៃអ្នកប្រាជ្ញ សូម្បីមិនមានមូលហេតុអ្វីជាមាំមួន ហើយក៏ធ្វើវិវាទដែរ នេះជាលក្ខណៈ មនុស្សល្ងង់ទេ ។
>
> ហិតោបទេស

# ១២ – យើងត្រូវចែកការគ្នាធ្វើ

## Partageons le travail

## រឿងព្រេងទំនេត

*ប្រែពីភាសាបារាំង ដោយលោក ក៉យ-ប៊ុក*

---

មានចូជីអិដ្ឋ ១ ឆ្នាំងខ្ទះដី (tourte de terre) (1) ១ ស្ពៃក្តោប ១ រុយ ១ កន្ទោមគ្រាប់ថ្លៅ ១ នឹងម្លូល ១ បានទៅប្រជុំគ្នាដើម្បីចែកការគ្នាធ្វើសព្វៗខ្លួន ។ ចូជីអិដ្ឋជាអ្នកទទួលចាត់ការនេះ ។ ចូនេះបានបង្គាប់ឲ្យឆ្នាំងខ្ទះដីទៅរកដងទឹក ឲ្យស្ពៃក្តោបនាំគោញីទៅចម្ការ រុយនាំគោឈ្មោលទៅឲ្យស៊ីស្មៅ គ្រាប់ថ្លៅកិនគ្រាប់ស្រូវសាឡី ហើយយកទៅបក់នឹងត្បាលបក់ ម្លូលត្រូវបោសប្រាស នៅចាំគេហដ្ឋាន ។

ចូជីអិដ្ឋ ដល់ចែកការគ្រប់គ្នារួចស្រេច ក៏ឡើងទៅសិតនៅលើទូជាក់មួយ ហើយក៏អង្គុយស្ញៀមគិតដញ្ញឹងអំពីការដែលខ្លួនត្រូវធ្វើក្នុងថ្ងៃនេះ ។

ឆ្នាំងខ្ទះដីបានយកក្អមទៅដងទឹក ។ តែឆ្នាំងខ្ទះដីអិដ្ឋនោះ ត្រូវទឹកខ្លាតទៅលើក៏រលាយអស់គ្មានសល់ ។ ព្រោះហេតុដូច្នេះ គេហដ្ឋានក៏គ្មានទឹកប្រើប្រាសទេ ។ ស្ពៃក្តោបបាននាំគោញីទៅចម្ការ រុយនាំគោឈ្មោលទៅស៊ីស្មៅ ។ នៅតាមផ្លូវដែលទៅ គោញីដោយសេចក្តីស្រេកឃ្លានក៏ស៊ីស្ពៃក្តោបអស់ ។ រស្មានៃរុយត្រូវធ្លាក់កប់ទៅក្នុងអាចម៍គោ ដោយខ្លួនហើរជិតគោឈ្មោលនោះពេក ។ ព្រោះហេតុដូច្នោះ គោ

---

1—tourte de terre ប្រែថានំដី នំធ្លូចផាមិនសម ប្រហែលជាអ្នកនិពន្ធច្រលំនឹងពាក្យថា tourtière ប្រែថា ឆ្នាំងខ្ទះទេដឹង ?

ញីនឹងគោឈ្មោលនោះមិនបានវិលត្រឡប់មកកាន់គេហដ្ឋានវិញទេ ។

កន្ទ្រាមគ្រាប់ថ្មៅបានទៅចក់ស្រូវឯត្បាល់បុក ។ ដល់កន្ទ្រាមគ្រាប់ថ្មៅទៅដល់ទីនោះ ស្រាប់តែកំយោបក់ទៅណាបាត់ ។ កន្ទ្រាមគ្រាប់ថ្មៅក៏មិនបានវិលត្រឡប់ទៅគេហដ្ឋានវិញ ។

ម្ជុលបានគ្រាប់ដើររកអំបោស តែរកមិនឃើញ ។ រួចម្ជុលនោះរត់ចុះឡើង ក៏រមៀលទៅតាមចន្លុះទឹកបាត់ ។ ព្រោះហេតុដូច្នេះ គេហដ្ឋានក៏មិនបានបោសសំអាត ។

ចូដីនោះក៏ស្ថិតនៅអស់យូរកាល លើទូថាក់នោះ មានចិត្តព្រួយបារម្ភជាខ្លាំង ដោយមិនឃើញតាសាដែលប្រើទៅ មិនបានឃើញវិលត្រឡប់មកគេហដ្ឋានវិញ ។ ចូដីក៏នឹកខ្លួនឯងថា: « ពួកនេះជាពួកគ្មានសមត្ថភាពគ្រប់គ្រាន់ ត្រូវតែអញទៅមើលត្រួតត្រាខ្លួនឯង តើវាទៅទីណាកន្លែងណា ! » ។

ក្រោយដែលបានត្រិះរិះដូច្នេះ ចូដីអង្គុំលោតពីលើទូមកក្រោម មិនបានគិតថាខ្លួនធ្វើពីដីអិដ្ឋ ក៏បែកបាក់ខ្ទេចខ្ទីគ្មានសល់ ។ ព្រោះហេតុដូច្នេះ គ្មានអ្នកណាថែទាំផ្ទះសម្បែងនោះឡើយ ។

គតិទៀង: មនុស្សល្ងង់គ្មានប្រាជ្ញា ចាំរបនាការទាំងឡាយ មិនបានសម្រេចឆ័យ វិនាសកាយខ្ចាយមរណា ។ ធ្វើការមិនស្គាល់កាលយល់ធ្ងន់ជាស្រាលតាមលក្ខណា មិនដឹងហេតុផលា អវិជ្ជាបានទោសភ័យ ។

ទំនៀមទម្លាប់ នៃខេមរជាតិ
ខ្មែរគួរខ្មីឃ្មាត សិក្សាពេញទី ។
ព្រោះខេមរជាតិ ជាជាតិសោភី
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

— ប. ព. —

# ប្រាសាទវត្តនគរ

## ( នៅខេត្តកំពង់ចាម )

នៅខាងលិចចំ នៃក្រុងកំពង់ចាម, តាមផ្លូវជាតិលេខ ៧ ទៅពីក្រុងភ្នំពេញ, មានប្រាសាទបុរាណមួយ ដែលអ្នកស្រុកស្គាល់ឈ្មោះថា « ប្រាសាទវត្តនគរ » ។ ចម្ងាយចូលពីផ្លូវជាតិតែប្រមាណ ២០០ ម៉ែត្រប៉ុណ្ណោះ មានក្រាលថ្មស្អាតស្រួល ហើយធ្វើដំណើរបានគ្រប់រដូវ ។ អ្នកស្រុករមែងចេញចូលក្នុងបុរាណដ្ឋាននេះរៀងរាល់ថ្ងៃពុំមានដាច់ ព្រោះនៅជិតទីប្រជុំជនខេត្ត ដែលមានមនុស្សច្រើនផង ទីងដោយមានប្រាសាទបុរាណ, វត្តពីរ ព្រមទាំងបូជនីយដ្ឋានដទៃទៀតផង ។ អាស្រ័យហេតុនេះ អ្នកនៅជិតខាងក្រុងកំពង់ចាម ឬអ្នកជាទេសចរទៅកំសាន្តក្រុងកំពង់ចាម រមែងធ្លាប់ស្គាល់ប្រាសាទនេះច្បាស់លាស់ណាស់ ប៉ុន្តែប្រវត្តិពង្សាវតារនៃបុរាណដ្ឋាននេះ ច្រើនពុំសូវបានច្បាស់ក្នុងសន្តានចិត្តអ្នកទាំងនោះនៅឡើយ ដ្បិតគេច្រើនតែនិយាយតាមឮត ៗ គ្នាហូរហែមក

រកហេតុផលពុំបានជាក់លាក់ ។ ដូច្នេះហើយ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ជាមជ្ឈមណ្ឌលរក្សា និងប្រមូលឯកសារបុរមបុរាណ, ដែលកើតមានឡើង ជាង ៣០ ឆ្នាំមកហើយនោះ ត្រូវតែអធិប្បាយឡើងវិញជូនជនរួមជាតិយើង បានយល់ច្បាស់ហើយបណ្ដុះការស្រឡាញ់កេតិកភណ្ឌជាតិ ដែលមាន សឹងពាសពេញក្នុងប្រទេស ។

បើយើងធ្វើដំណើរពីភ្នំពេញទៅ យើងបានដល់ប្រាសាទនេះ មុននឹងដល់ក្រុងកំពង់ចាម គឺនៅខ្វះតែបីគីឡូម៉ែត្រ ហើយបែរខាងលិចផ្លូវជាតិគឺខាងស្ដាំដៃ, យើងនឹងប្រទះផ្លូវលំយ៉ាងស្អាតត្រង់ក្លឹងតាមចន្លោះដើមរុក្ខជាតិសងខាង គួរជាទីមនោរម្យ ។ សព្វថ្ងៃទីតាំងនៃប្រាសាទនេះ ស្ថិតនៅក្នុងឃុំអំពិល ស្រុកកំពង់សៀម ( កំពង់ចាម ) ។

តួប្រាសាទ នឹងបរិវេណប្រាសាទទាំងមូល បែរមុខឆ្ពោះទៅទិសខាងកើត តម្រង់ទៅរកផ្លូវជាតិ ។

កាលណាចូលមកកាន់បុរាណដ្ឋាននេះ យើងប្រទះជាបឋមនូវខ្លោងទ្វារមួយធ្វើពីថ្មបាយក្រៀម មានចន្លោះប្រកប្រមាណជា ៣ ម៉ែត្រប៉ុណ្ណោះ នៅខាងលើពុំមានកំពូលអ្វីជាចេតដាយទេ ទំនងជារុះធ្លាក់អស់ដោយសារការចាស់ទ្រុឌទ្រោមក្នុងភាពជក នៅសល់តែថ្មសន្ទឹកជួនជ្រុងវែង ៗ បំពាក់តងគាក់លើគ្នា គ្រាន់តែនៅសល់សណ្ឋានជាពងខ្លោងទ្វារ ឬហៅតាមពាក្យអ្នកស្រាវជ្រាវថា « គោបុរៈ » ប៉ុណ្ណោះ ។ ភ្ជាប់នឹងគោបុរៈនេះ សងខាងមាន

កំពែងថ្មដែលមានកំពស់ប្រមាណជា ៣ ម៉ែត្រ កម្រាស់ ០ ម ៦០ សព្វថ្ងៃជ្រុះធ្លាក់អស់ច្រើនអន្លើណាស់ទៅហើយ ។ នៅពីលើកំពែងនេះទៀតមានលំអដោយថ្មស់លៀង ដែលឆ្លាក់ជាសន្លឹក ចុងស្រួចទំនងជាស្លឹកឈើមានរៀងដង្ហែគ្នាញឹករមេញ ។ ខ្លោងទ្វារនេះរថយន្តតូចអាចចេញចូលបានយ៉ាងស្រួល ឯរថយន្តធំតោងមានការប្រយ័ត្នប្រយែងបន្តិច ព្រោះចង្អៀតសងខាងផង ពីលើផង ក្រែងប៉ះ នាំឲ្យមានគ្រោះថ្នាក់ ។

ចូលផុតពីខ្លោងទ្វារនេះភ្លាម យើងប្រទះឃើញខាងឆ្វេងដៃមានស្រះមួយធំ មានទឹកថ្លាឆ្វង់ដក់ខួបប្រាំងខួបវស្សាសំរាប់ផ្តល់ជាសេចក្តីត្រូវការប្រើប្រាស់បានគ្រប់ពេល ។ ជុំវិញស្រះ មានខឿនថ្មព័ទ្ធជុំ តែយើងឃើញរៀបថ្មដោយមានបាយអបូកភ្ជាប់ផង មានតែជណ្តើរពីរគឺខាងជើងមួយ ខាងត្បូងមួយប៉ុណ្ណោះ ដែលនៅជាប់ជាកាំថ្មបុរាណ ឥតភ្ជាប់ដោយបាយអទេ ។ មាត់ស្រះចំហៀងខាងត្បូង មានដើមដូងដុះត្រៀបពោលម្លប់ត្រឈៃគួរជាទីមនោរម្យ គ្របដណ្តប់លើដីវាលយ៉ាងស្រឡះទូលាយ ។ ត្រង់វាលនេះ មានវត្តមួយប្រកបដោយព្រះវិហារ កុដិ សាលាយ៉ាងរៀបរយក្នុងស្រុកហៅថា " វត្តនគរក្រៅ " ។

យើងដាក់បែរមកខាងស្តាំដៃម្តង ។ ខាងនេះ មានគុហាមួយសង់របៀបជាផ្ទះអ្នកតាចិន ដ៏មានខ្លោងទ្វារតូចមួយស្លុយទ្រុងទូអក្សរចិនជាលំអរ(១) ។ ក្នុងផ្ទាតូចមួយក្រាលឥដ្ឋយ៉ាងស្អាត សំពថនាំដំហានទេសចរ

១- អក្សរចិនបីម៉ាត់ថា សាម-ប៉ាវ-កុង ប្រែថាព្រឹទ្ធាចារ្យប្រកបដោយចំណេះបីយ៉ាង ។

តាំងឲ្យយើងដើរចូលទៅក្នុងគូហានេះបានយ៉ាងស្រួល ។ ពិតមែនតែគូហានេះបែរមុខមកត្បូង ប៉ុន្តែរូបបដិមាករធំតាំងបីនៅក្នុងនេះ មិនបែរមុខត្រង់មកត្បូងទទួលអ្នកដើរចូលទៅទេ បែរជាឆ្ពោះមុខទៅខាងលិចវិញ ដូច្នេះអ្នកដើរចូលទៅ ត្រូវត្រឡប់ខ្លួនមកខាងស្តាំដៃទៀត ទើបបានប្រទះនឹងរូបនេះ ។ បដិមាករបីអង្គនេះ មានទំហំធំជាងមនុស្សធម្មតា ហើយនៅក្បាលមានកំពូលស្រួចបន្តិចទំនងដូចជាមូលីព្រះពុទ្ធរូប ។ រូបនៅចំកណ្តាល ដំកល់ខ្ពស់លើអាសនៈអង្គុយពែនភ្នែន ដៃសំពះប្រណម្យឆ្ពោះទៅខាងមុខ គឺទិសខាងលិចចំ ។ រូបពីរសងខាងនៅទាបគ្មានអាសនៈទេ ហើយជារូបឈរកាន់ដំបងបញ្ឈរចំពីមុខ ។ រូបតាំងបីនេះ ធ្វើពីថ្មដូចគ្នា តែសព្វថ្ងៃគេបិទមាសភ្លឺចិញ្ចាចបាត់សាច់ថ្មទៅហើយ ។ អ្នកស្រុកហៅបដិមាករនេះថា "តាព្រហ្ម" ។ សឹងមានរឿងព្រេងមួយនិទានពីប្រវត្តិ តាព្រហ្មនេះថា គាត់ភ័ន្តច្រឡំស្រឡាញ់ម្តាយឯង យកធ្វើជាប្រពន្ធ ម៉្លោះហើយបានជាគាត់ត្រូវធ្វើរូបគាត់អង្គុយសំពះម្តាយ ដែលគេបញ្ចុះអដ្ឋិក្នុងចេតិយមួយនៅចំខាងលិច គឺពីមុខគាត់ចំនោះឯង (១) ។

ហួសពីគូហានេះបន្តិច មានផ្លូវមួយបែកទៅស្តាំដៃសសៀរជាប់នឹងគុហាតាព្រហ្ម ។ ជងផ្លូវនេះគោង ដីមានចេតិយតម្រៀបគ្នា និងគុហាតូចមួយទៀតជ្រកក្រោមដើមពោធិ ដែលក្នុងនោះមានដំកល់ព្រះពុទ្ធរូបបដិមាករធ្វើទុក្ករកិរិយាមួយអង្គ, នៅជិតគ្នាជាប់ខាងជើងផ្លូវផង ។

---

១– សូមអានរឿងតាព្រហ្មនៅក្នុងសៀវភៅរឿងព្រេងខ្មែរភាគ៥ផ្សាយពីពុទ្ធសាសនបណ្ឌិត្យ។

យើងមើលមកផ្លូវត្រង់ទៅលិចវិញ, នេះពិតជាផ្លូវពីបុរាណ, ឃើញមានសភាពត្រង់ក្អឹង ឆ្ពោះទៅកាន់ខ្លោងទ្វារកំពែងមួយជាន់ទៀត ។ មុនដល់ខ្លោងទ្វារ មានពាលមួយកបស៊ើនៅខាងស្ដាំដៃ ប្រកបដោយខឿនថ្មបាយក្រៀមព័ទ្ធជុំវិញ ព្រមទាំងមានក្បាច់ឆ្លាក់ជារូបនាគ សន្ធឹងខ្លួនជាបង្កាន់ដៃនឹងតោថ្មធំ ៗ នៅអើតកស៊ើនតម្រៀបគ្នាបែបជាព្រលានមួយ ៗ

គោបុរៈជាន់ទី ២ នេះ មានទំហំប្រហែលគ្នានឹងជាន់ទី ១ ដែលយើងពោលរួចមកពីខាងដើមដែរ ប៉ុន្តែ នៅមានសភាពគង់វង្សក្បាច់ក្បូរច្រើនជាង ៗ ចូលផុះទៅទៀត យើងប្រទះនឹងកូនសាលាពីរសងខាងផ្លូវនៅជ្រកក្រោមដើមពោធិធំៗ ម្ខាងមួយ ៗ កូនសាលាទាំងនេះ ទើបតែសង់ក្នុងរវាង ៥០-៦០ ឆ្នាំ កន្លងទៅប៉ុណ្ណោះទេ សំរាប់ឲ្យអ្នកដំណើរទាំងឡាយឈប់សំរាក ព្រោះជាទីចំហឥតមានជញ្ជាំង មានតែដំបូលក្បឿងនិងផ្ទៃក្រោមក្រាលឥដ្ឋកន្សែងយ៉ាងស្អាត ៗ នៅបាំងសាចជុំវិញផ្នែកខាងក្នុងមានគំនូរនិទានរឿងផ្សេង ៗ ក្នុងទសជាតក៍យ៉ាងល្អមើល ។ នៅជាប់នឹងសាលាទាំងពីរនេះ មានស្រះធំ ៗ ពីរទៀតនៅម្ខាងមួយ ដែលមានទ្រង់ទ្រាយដូចស្រះមួយនៅពីមុខគុហាតាព្រហ្ម ដែលយើងនិយាយរួចម្ដងមកហើយដែរ តែស្រះពីរនេះតូចជាង ហើយមានទឹកតែក្នុងរដូវវស្សាប៉ុណ្ណោះ ។ យើងដើរឆ្ពោះទៅមុខតែបន្តិច ក៏ដល់គោបុរៈមួយជាន់ទៀត ជាជាន់ទី ៣ ដែលមានសណ្ឋានបែបពង ដូចជាទី ១ និងទី ២ ដែរ តែមាននៅសេស

សល់កំពូលប្រាង្គណ៍ខ្ពស់ជាងគោបុរៈមុខ ។ ហើយកំពែងក៏នៅល្អស្អាតព័ទ្ធជុំវិញ ។ កំពែងនេះ មានសណ្ឋានជាកេងខង គឺមានផញ្ចាំងសងខាងសំកប់ទុកចន្លោះកណ្ដាលនៅចំហ អាចឲ្យមនុស្សជ្រែកនៅបាន ។ បរិវេណកេងខងនេះកង់បួនជ្រុងទ្រវែង មានប្រកប្រកបដោយកំពូល តែពីរទេ គឺខាងកើតនឹងខាងលិច ។ ខាងក្នុងនឹងខាងក្រៅកំពែងនេះ ដីស្រឡះស្រឡៃជាទីគេកាយដល់អ្នកទេសចរទាំងឡាយ ។ ចូលផុតពីកំពែងនេះភ្លាម គេឃើញនៅចំកណ្ដាលទី មានប្រាង្គណ៍មួយខ្ពស់ប្រមាណជា ១៥ ម៉ែត្រ។ បាតក្រោមកង់បួនជ្រុង មានទំហំមួយជ្រុង ។ ប្រមាណ ៨ ម៉ែត្រ ។ នៅលើកំពូលគ្មានចេតិយមុខលោកេស្វរៈទេ គ្រាន់តែមានជាក្បាច់សន្ទាប់ថ្នាក់ ។ ទំនងជាត្របកផ្កាឈូក ឯចុងស្រួចបំផុតជ្រុះធ្លាក់បាត់ពុំដឹងជាបែបណា គ្រាន់តែនៅឃើញជានជាសណ្ឋានមូល ប្រហែលកំពូលចេតិយ ។.

ចុះពីថ្នាក់លើដែលមានក្បាច់ជាត្របកផ្កាឈូកកង់មូលនោះមក ថ្នាក់ក្រោមបែរជាមានកង់បួនជ្រុងរហូតដល់ដី ។ ត្រង់ផ្ទាល់នឹងដីនេះ មានស៊ុមប្រកបដោយក្បាច់បែបចេនាអន្តរ ហើយនៅផ្ទាំងថ្មជាផ្ទៃនៃស៊ុមទ្វារទាំង ៤ ទិស គឺខាងកើត ខាងជើង ខាងត្បូង និង ខាងលិច មានឆ្លាក់ជារឿងពុទ្ធប្បវត្តិ គ្រប់ផ្ទៃទាំងបួន ។ គឺផ្ទៃលើស៊ុមទ្វារទិសបូពិ ឆ្លាក់រូបភាពដំណាលកាលព្រះពុទ្ធទ្រង់ផ្ចាញ់មារកចិកជ, ផ្នែកខាងជើង ដំណាលកាលព្រះសិទ្ធត្ថកុមារយាងចាកព្រះរាជនិវេសន៍ គង់លើកណ្ឋកអាជានេយ្យ .

ផ្នែកខាងត្បូង ដំណាលកាលព្រះពោធិសត្វទ្រង់កាត់ព្រះផ្នួងនៅក្បែរស្ទឹងអនោមា ឯផ្ទៃទី ៤ នៅខាងលិច ដំណាលត្រង់ព្រះពុទ្ធទ្រង់គង់មានអគ្គសាវ័កអមអង្គ ។ ក្បាច់ក្របវ័ណ្ណរូបចម្លាក់ផ្ទៃនិមួយ ៗ ឆ្លាក់ជារូបនាគពីរ សន្ធឹងខ្លួនព័ទ្ធតាមកង់ត្រកោន ប្រទាក់កន្ទុយគ្នាទៅលើ ក្បាលសំយុងចុះក្រោមអើតចេញទៅចុងម្ខាងម្នាក់ ៗ ។ នៅចន្លោះស៊ុមទាំង ៤ នេះមានដំកល់ព្រះពុទ្ធរូបមារវិជ័យមួយអង្គ ៗ គ្រប់ចន្លោះទ្វារទាំងបួន ៗ សព្វថ្ងៃព្រះពុទ្ធបដិមាទាំងបួននេះ បិទមាសភ្លឺចិញ្ចាច ៗ មិនតែប៉ុណ្ណោះ អ្នកស្រុកសម័យក្រោយ បានសាងព្រះវិហារមួយបំពីខាងកើតប្រាង្គណ៍ ហើយយកដំបូលម្ខាង ទៅបំពាក់លើប្រាង្គណ៍នោះផង ៗ ព្រះវិហារនេះសង់ពីបាយអ ដំបូលប្រក់ក្បឿងពណ៌ក្ដីផ្ទុកផ្អិនផ្អៅ តែឥតមានជញ្ជាំងទេ ៗ នៅក្រោមដំបូលវិហារផ្នែកខាងកើត មានសិលាចារឹកមួយផ្ទាំងដំកល់យ៉ាងស្អាតបាត ដូចជាសន្ធឹកសីមាពងបួនជ្រុងសំប៉ែត ៗ អក្សរនៅច្បាស់ឥតមានរបករបេះឡើយ គឺនៅផ្នែកខាងមុខជាអត្ថបទភាសាបាលី ហើយនៅផ្នែកខាងចំហៀង ជាអត្ថបទភាសាខ្មែរ ។ នៅផ្នែកភាសាបាលី គេអាចដកស្រង់សេចក្ដីបានយ៉ាងសង្ខេបថា ៖

" ខ្ញុំស្រីសុគន្ធបទ និងមហេសី ទាំងពីរនាក់មានចិត្តសទ្ធាចំពោះព្រះពុទ្ធសាសនា មានបំណងឲ្យបានរស់នៅជានិច្ចក្នុងលោកនេះ ដើម្បីសាងកុសលសំអាតមន្ទិល , សូមឲ្យការប្រតិបត្តិរបស់យើងបានបិតថេរ ,

សូមសម្បត្តិទ្រព្យយើងខ្ញុំបានជាការបំណាយក្នុងផ្លូវធម៌ ហើយយើងខ្ញុំទឹកគិតជានិច្ចដល់ព្រះនិព្វានបរមសុខ ៗ លុះកណាពន្ធព្រះអាទិត្យបានដើរដល់ទីបំផុតនៃទ្វីបលោកលែងមានឡើងវិញ យើងខ្ញុំក៏សូមលាចាកផែនដីនេះទៅកាន់សុគតិភព ប្រកបដោយនាមពិរោះពិសាជានិច្ចដែរ „ ។

នៅផ្នែកបំហៀង គេអានបានជាភាសាខ្មែរ ដែលចាប់ន័យយ៉ាងសង្ខេបបានថា ៖

„ ខុកញ៉ា យស មានសទ្ធាជ្រះថ្លាបានសាងព្រះពុទ្ធរូបជាច្រើនអង្គដំកល់នៅចំកណ្តាលវត្តកំពុជាជ័យ (ប្រាង្គណ៌កណ្តាល) ដើម្បីថ្វាយចំពោះព្រះនាគសេនបពិត្រ (នាយកនៃភាពមនោះ) កាលពីថ្ងៃព្រហស្បតិ៍ ១៤ កើតខែអាសាធ ឆ្នាំខាល ១៤៨៨ សក[1] (រវាង គ្រិស្តសតវត្សទី ១៦) „ ។

តាមពត៌មានដែលស្រង់បានពីក្នុងអត្ថបទខាងលើនេះ យើងសន្និដ្ឋានបានថា ប្រាសាទនេះ មានរូបរាងច្បាស់លាស់មកអង្វែងហើយ គឺតាមការស្រាវជ្រាវរបស់អ្នកប្រាជ្ញជាច្រើន បានរកឃើញថា ប្រាសាទនេះកសាងឡើងតាំងពីក្នុងរជ្យព្រះបាទជ័យវរ្ម័នទី ៧[2] ព្រោះគេសំគាល់បានត្រង់បែបបទរចនាជាបែបព្រះពុទ្ធសាសនា មានរូបចំឡាក់នៅផ្ទៃនិទានពីរឿងពុទ្ធប្បវត្តិជាដើម ៗ ម្យ៉ាងទៀតអ្នកស្រាវជ្រាវបានរកឃើញ ថាប្រាសាទវត្តនគរនេះ មានទ្រង់ទ្រាយដូចគ្នាបេះបិទនឹងប្រាសាទតាព្រហ្ម នៅ

១– Notice sur le Wat-Nokor ដំកល់នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ លេខ M.S.P. M-8 ។ ២ - ប្រវត្តិពុទ្ធសាសនាប្រទេសខ្មែរ របស់ព្រះភិក្ខុប៉ាង . ខាត់ ទំព័រ ៨១ ។

ទន្លេបាទី (តាកែវ) ទាំងសិល្បៈស្ថាបត្យកម្ម (Art architectural), ទាំងទំហំបែបផែន (Schéma) នៃប្រាសាទទាំងមូល ៗ បើឃើញដូចនេះ យើងបាច់សេចក្ដីបានថា សេចក្ដីសន្និដ្ឋានខាងលើ សមហេតុផលហើយ ព្រោះថាក្នុងរជ្ជកាលនៃព្រះបាទជ័យវរ្ម័នទី ៧ រវាងសតវត្សទី ១៣ ពិតជាព្រះអង្គទ្រង់បានពង្រីកពុទ្ធសាសនាមែន ដែលពីរជ្ជកាលមុន ៗ មក ពុំសូវបានដុះដាលទេ ៗ សកម្មភាពនេះរីកដោយសារសេចក្ដីផ្ដើមគំនិតរបស់ព្រះនាងឥន្ទ្រទេវី ជាព្រះអគ្គមហេសីនៃព្រះអង្គ ៗ

បន្ទាប់ពីប្រាសាទដែលមានវិហារសង់ជាប់ជាមួយផង នៅចំកណ្ដាលបរិវេណដែលពោលមកនេះ ទេសចរអាចធ្វើដំណើរបានតាមផ្លូវព័ទ្ធជុំវិញហើយចេញតាមបន្ទោះខ្លោងទ្វារខាងលិចព័ទ្ធទៅឆ្វេងក៏បាន ទៅស្ដាំក៏បាន គឺចេញផុតពីបរិវេណកំពែងទី ៣ ហើយ ៗ ឥឡូវយើងទៅក្នុងបរិវេណទី ២ បើងាកទៅខាងឆ្វេងមុន យើងប្រទះគុហាពីរនៅទន្ទឹមគ្នា គឺមួយខាងលិចមានតែព្រះពុទ្ធរូបតូចធំជាច្រើនដំកល់ក្នុងនោះ ឯមួយទៀតខាងកើត មានជញ្ជាំងជិតជិតស្រួលបួលដំកល់ព្រះពុទ្ធរូបបរិនិព្វានប្រវែងពីព្រះសិរដល់ព្រះបាទប្រមាណជា ១០ ម៉ែត្រ ៗ លុះដើរហួសពីនេះងាកព័ទ្ធទៅចំហៀងខាងស្ដាំវិញ យើងឃើញគុហាពីរទន្ទឹមគ្នាដែរ គឺមួយខាងលិចគ្រាន់តែជាទីដំកល់ព្រះពុទ្ធរូបតូចធំប៉ុណ្ណោះ ឯមួយទៀតខាងកើតទើបឃើញមានចេតិយមួយកង់តាបទទារ លាបល័ខពណ៌ក្រហមក្រមៅ[1]

---

១- ចេតិយនេះ ដែលរឿងព្រេងនិទានថាជាចេតិយយាយពៅម្ដាយតាព្រហ្ម ដែលគាត់សំពះផ្ដោះមករក ៗ

នឹងមានព្រះពុទ្ធរូប ៤ ព្រះអង្គ ក្នុងមួយអង្គៗ មានទំហំក្មួនប្រមាណជាជាង ១ ម៉ែត្រ គង់ព័ទ្ធជុំវិញបែរព្រះភក្ត្រឆ្ពោះទៅកាន់ទិសធំទាំងបួន ។

កាលណាយើងធ្វើដំណើរចេញពីទីនេះទៅទៀត សសៀរតាមកំពែងថ្មជាន់ទី ២ ត្រង់ជ្រុងខាងជើងចំ យើងអាចចេញបានតាមចន្លោះថ្មដែលរុះធ្លាក់មកនៅទាបនឹងដី, ហើយយើងប្រទះឃើញស្រះបុរាណ យ៉ាងធំមួយទៀតប៉ុនគ្នានឹងស្រះនៅពីមុខគុហាតាព្រហ្មដែរ ។ ចាប់ពីមាត់ស្រះទៅលិច មានគុដិ·សាលាជាអាគមមួយទៀត ដែលអ្នកស្រុក ហៅថា „វត្តនគរក្នុង,, ។

ការទស្សនាប្រាសាទបុរាណនេះ ពុំមែនជាហត់នឿយប៉ុន្មានទេ ព្រោះបរិវេណតូចល្មម ហើយគ្មានថ្នាក់ថ្មើរឲ្យយើងពិបាកឡើងចុះឡើយ ។ ដូច្នេះ យើងអាចចូលទៅទស្សនាបានគ្រប់ពេលឲ្យតែជាវេលាថ្ងៃ ប៉ុន្តែបើជួនជាយើងដើរមើលនៅពេលរសៀលទាបវិញ យើងនឹងមានចិត្តអណ្តែតអណ្តូងថ្ងែក ព្រោះប្រទះនឹងព្រះសុរិយាដែលហៀបនឹងអស្តង្គត ហើយបាចសាចកំទេចរស្មីជះមកកាយលើប្រាង្គណ៍ នឹងកំពែងថ្ម ជាប់ជាមួយក្លិនប្រហើរនៃដើមស្រូវដែលនៅក្នុងវាលស្រែ ព័ទ្ធជុំវិញបុរាណស្ថាននេះ ហាក់ដូចជាក្លិនក្រអូបនៃកិត្តិនាមខ្មែរ ដែលធ្លាប់មានមកពីអន្លែងហើយ ។

លី-ធាមតេង

## ផ្នែកកំណត់និងប្រវត្តិការណ៍

# អនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ២០

## គ.ស. ១៩៦៤

អនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ២០ បានធ្វើពីថ្ងៃពុធ ៩ កើត ដល់ថ្ងៃចន្ទ ១៤ កើតខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥០៦ (៨-១-៦៤) នៅវត្តបទុមវតីរាជវរារាម និងវត្តឧណ្ណាលោម ក្រោមព្រះរាជាធិបតីភាព នៃសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ។

## ថ្ងៃទី ១

ថ្ងៃពុធ ៩ កើតខែបុស្ស (៨-១-៦៤) វេលាម៉ោង ១៤ និង ៣០ទៅម៉ោង ១៩ ជាពេលបើកឱកាសធ្វើមហាសន្និបាត នៃមន្ត្រីសង្ឃទាំងពីរគណៈដោយលោក ក៉យ-ប៊ុក នាយកការិយាល័យក្រសួងធម្មការ លោក យិន-ប៊ឹម អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ លោក តែ-ម៉ុងហាប់ អគ្គលេខាធិការនៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ព្រមទាំងសហការីឯទៀតដែល បានអញ្ជើញជូនដំណើរទៅកាន់វត្តបទុមវតី និងវត្តឧណ្ណាលោមផង ដើម្បីបើកសម័យប្រជុំមហាសន្និបាតសម្រាប់ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥០៦ ។



សម្ដេចព្រះប្រមុខរដ្ឋ ទ្រង់ថ្លែងព្រះសុន្ទរកថា នៅឱកាសពិធីអនុស្សាវរីយ៍ប្រគល់សញ្ញាបត្រ មន្ត្រីសង្ឃលើកទី ២០ នៅយ៉ពុទ្ធិកវិទ្យាល័យ
ព្រះសុរាម្រឹត ថ្ងៃទី ១០–១.៦៤

## ថ្ងៃទី ២

ថ្ងៃព្រហស្បតិ៍ ១០ កើត ខែបុស្ស (៩-១-៦៤) ពេលម៉ោង ៨ ព្រឹក មានការនិមន្តព្រះសង្ឃទាំងពីរគណៈ ចំនួន ៤០ អង្គ ចំរើនសត្តប្បករណាភិធម្ម ឧទ្ទិសព្រះរាជកុសលថ្វាយព្រះបិតា នៅចេតិយទាំងគូខាងមុខព្រះវិហារព្រះកែវមរកត ។ នៅម៉ោង ១០ និង ៣០ នាទី ព្រះសង្ឃទាំងពីរគណៈទទួលចង្ហាន់ថ្ងៃត្រង់នៅវត្តបទុមវតី និងវត្តឧណ្ណាលោម ចំពោះមុខអនុរដ្ឋលេខាធិការក្រសួងធម្មការ ។

## ថ្ងៃទី ៣

ថ្ងៃសុក្រ ១១ កើត ខែបុស្ស (១០-១-៦៤) ពេលម៉ោង ៨ ព្រឹក ក្រសួងធម្មការ បានបើកអនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ២០ នៅយ៉ៃនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ក្រោមព្រះអធិបតីភាពនៃសម្តេចព្រះប្រមុខរដ្ឋ ។

ចាប់តាំងពីម៉ោង ៧ និង ៣០ នាទីទៅ នៅកន្លែងប្រារព្ធពិធីនោះ គេសង្កេតឃើញផ្នែកខាងបព្វជិត គឺ សម្តេចព្រះសង្ឃរាជគណៈមហានិកាយ សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ ព្រះពោធិវង្ស-ហួត-តាត ចាងហ្វាងទូទៅនៃពុទ្ធិកសិក្សា ព្រះសង្ឃរាជាគណៈឋានានុក្រម មេគណ អនុគណ គ្រប់ខេត្ត-ស្រុក ចៅអធិការគ្រប់វត្តក្នុងរាជ

ធានី ព្រមទាំងព្រះសង្ឃជាច្រើនរយអង្គទៀត ដែលនិមន្តមកពីវត្តនានាក្នុងក្រុងនិងខេត្តក្រៅ ដើម្បីប្រជុំក្នុងមហាសន្និបាតនេះ ។

ផ្នែកខាងគ្រហស្ថ គេសង្កេតឃើញ សម្ដេចព្រះស្នង្គវង្សនារាជ-កញ្ញា ចំរើនរដ្ឋ ប៉េង-ប៉ោះ យុគន្ធរ សម្ដេច រាំងវរវៀងជ័យអធិបតីស្រិង្គារ ប៉ែន-នុត ទីប្រឹក្សាអមព្រះអង្គ ឯកឧត្តម អ៊ឹង-ហុងសាត ប្រធានរដ្ឋសភា អ្នកអង្គម្ចាស់ នរោត្តម ម៉ុងតាណា ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ អ្នកអង្គម្ចាស់នរោត្តមកន្តុល នាយករដ្ឋមន្ត្រី សមាជិកខ្លះនៃសភាទាំងពីរ និងសមាជិកខ្លះនៃរាជរដ្ឋាភិបាល ព្រមទាំងវរជនឯទៀតជាច្រើនដែលយើងសូមអភ័យទោសដោយមិនបានរាប់នាមក្នុងទីនេះ ខាងក្រសួងធម្មការមានសហជីវិន មែន-ឈុំ អនុរដ្ឋលេខាធិការក្រសួងធម្មការជាអ្នកចាត់ចែងពិធី សហជីវិន រ៉ាយ-ប៊ុក នាយកការិយាល័យ ព្រមទាំងមន្ត្រីតំណាងក្រសួងនានា ប្រធានពុទ្ធិកសមាគម ប្រធានពុទ្ធិកសមាគមវិទ្យាល័យព្រះសុរា-ម្រិត ប្រធានសមាគមគិលានសង្គ្រោះ សាស្ត្រាចារ្យនៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ព្រមទាំងមន្ត្រីភ្នាក់ងាររាជការនិងប្រជាពលរដ្ឋជាច្រើនរូបទៀត បានស្ដេចយាងអញ្ជើញមក ដើម្បីប្រជុំជាកិត្តិយសក្នុងពិធីនេះដែរ ។

នៅវេលាម៉ោង ៨ និង ៣០ នាទី សម្ដេចព្រះប្រមុខរដ្ឋ ដោយមានសមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក និងព្រះរាជបរិពារផ្ទាល់ព្រះអង្គអម



ព្រះសង្ឃកំពុងគង់ស្តាប់ ព្រះសុន្ទរកថា នៃសម្តេចព្រះប្រមុខរដ្ឋ នៅឱកាសពិធីអនុសំវច្ឆរមន្ត្រីសង្ឃនៃលើកទី ២០
ថ្ងៃទី ១០ - ១ - ៦៤ នាពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត

ព្រះរាជដំណើរផង បានស្តេចយាងមកដល់កន្លែងប្រារព្ធពិធី ដោយបានទទួលការរៀបចំដ៏ខ្ពង់ខ្ពស់បំផុតអំពីក្រុមទាហានរក្សាព្រះអង្គ ដែលលើកអាវុធធ្វើវន្ទនកិច្ច ទាំងបន្លឺនូវបទភ្លេងចរលើលាថ្វាយជាព្រះរាជកិត្តិយស ។

បន្ទាប់មក សម្តេចឪ ទ្រង់បានទទួលការក្រាបថ្វាយបង្គំអំពីឥស្សរជនជាន់ខ្ពស់នឹងមន្ត្រីអគ្គរាជការទាំងឡាយ ដែលរង់ចាំក្រាបថ្វាយបង្គំសំដែងសេចក្តីស្វាមីភក្តិចំពោះព្រះអង្គនៅក្បែរទ្វារចូល ហើយដង្ហែព្រះរាជដំណើរចូលទៅថ្វាយបង្គំព្រះសង្ឃ ដែលមានសម្តេចព្រះសង្ឃរាជទាំងពីរគណៈជាប្រធាន ។ ខណៈនោះ បទភ្លេងជាតិក៏បន្លឺឡើងជាគ្រឿងញ៉ាំងកម្មវិធីឲ្យប្រព្រឹត្តទៅដោយសភាពយ៉ាងរុងរឿងក្រៃលែង ។

សូមបញ្ជាក់ថា នៅតាមដងផ្លូវពីមុខមន្ទីររដ្ឋសភាមកដល់ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ មានប្រជាពលរដ្ឋជាច្រើនរយនាក់បានឈររណែនណាប់កកស្រទាប់ ដើម្បីរង់ចាំគោរពនឹងថ្លែងសេចក្តីគោរពចំពោះសម្តេចព្រះបិតាឯករាជ្យជាតិ ជាទីស្នេហានឹងជាទីរលឹករបស់ខ្លួន ហើយបានទះដៃថ្វាយព្រះពរជ័យយ៉ាងកងរំពងនឹងយ៉ាងយូរ នៅវេលាដែលសម្តេចជាអម្ចាស់ស្តេចយាងមកដល់ ។

ក្រោយដែលសម្តេចឪ ព្រះបិតាឯករាជ្យជាតិ ស្តេចគង់ប្រថាប់លើព្រះសុវណ្ណគោច្ឆៈ ក្នុងរោងនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត សម្រួលព្រះឥរិយាបថហើយ ព្រះសង្ឃក៏បានស្វាធ្យាយធម៌ជយន្តោប្រសិទ្ធិពរថ្វាយ

ចំពោះសម្តេចព្រះប្រមុខរដ្ឋ ដើម្បីជាសុភមង្គលដ៏ប្រសើរចំពោះព្រះអង្គ

លុះស្រេចហើយ សហជីវិន ម៉ែន-ឈុំ អនុរដ្ឋលេខាធិការក្រសួងធម្មការ

បានថ្វាយសុន្ទរកថាថ្វាយព្រះពរស្វាគមន៍ចំពោះព្រះអង្គ ។ ឯសុន្ទរកថានេះ

យើងចុះផ្សាយនៅទំព័រខាងក្រោយ ។

បន្ទាប់ពីសុន្ទរកថាស្វាគមន៍នៃសហជីវិន ម៉ែន-ឈុំមក ព្រះតេជព្រះគុណ

កែ-អឿន មេគណខេត្តសៀមរាប បានថ្វាយសុន្ទរកថាមួយក្នុងនាមនៃ

មន្ត្រីសង្ឃ ដែលមានសម្តេចព្រះសង្ឃរាជទាំងពីរគណៈជាប្រធាន ដោយ

បញ្ជាក់អំពីការប្រព្រឹត្តទៅប្រកបដោយការរីកចំរើនយ៉ាងប្រពៃ នៃពុទ្ធសា-

សនា ក្នុងកម្ពុជរដ្ឋទាំងមូល ក្នុងសម័យសង្គម ។

តមក សម្តេចព្រះបិតាឯករាជ្យជាតិ បានថ្វាយព្រះសង្ឃកថាឥតព្រាង

ទុកមួយ បញ្ជាក់អំពីការកសាងនឹងសមិទ្ធិ ។ ជាអសង្ខារិមរបស់សង្គម

រាស្ត្រនិយម ចាប់តាំងពីអនុសំវច្ឆរៈ ទី ១៩ មកដល់អនុសំវច្ឆរៈ ទី ២០

នេះ ទីងនយោបាយក្នុងប្រទេស ក្រៅប្រទេស ក្នុងបច្ចុប្បន្ន ដោយ

ទ្រង់ដៅបញ្ជាក់ថា ព្រោះតែយើងកាន់យ៉ាងខ្ជាប់ខ្ជួននូវអព្យាក្រិតមិន

សំអៀងទៅប្លុកណាមួយនិងស្ត ឬ លោកសេរីនេះហើយ ទើបកម្ពុជរដ្ឋយើង

បានទៅជាកោះសន្តិភាពមួយក្នុងពិភពលោក ។

លុះចប់ព្រះសង្ឃកថាដ៏មានខ្លឹមសារនេះហើយ សម្តេចព្រះបិតាជាតិ

ទ្រង់ក៏ក្រាបថ្វាយបង្គំលាព្រះសង្ឃ ដែលមានសម្តេចព្រះសង្ឃរាជទាំង

ពីរគណៈជាប្រធាន ហើយដោយមានព្រះរាជបរិពារផ្សែងតាមដង់បាន

ស្តេចយាងនិវត្តចូលព្រះបរមរាជវាំងវិញ ដោយព្រះសុភក្ដិភាព ។

ពិធីនេះ បានចប់សព្វគ្រប់នៅវេលាម៉ោង ១១ និង ៣០ នាទី ក្នុង

បរិយាកាសដ៏ជាទីសប្បាយរីករាយ ។

ចាប់តាំងពីថ្ងៃទី ១៤ រហូតដល់ថ្ងៃទី ១៣ មករា ១៩៦៤ ព្រះ

សង្ឃទាំងពីរគណៈប្រជុំនៅវត្តឧណ្ណាលោម និងវត្តបទុមវតី ក្រោមព្រះ

រាជាធិបតីភាពនៃសម្ដេចព្រះសង្ឃរាជទាំងពីរគណៈ ដែលព្រះអង្គទ្រង់ចាត់

ចែងធ្វើ ។

សេចក្ដីរាយការណ៍ស្ដីពីពិធីអនុស្សាវរីយមហាសន្និបាតលើកទី ២០ នៃ

មន្ត្រីសង្ឃ ក្នុងព្រះរាជាណាចក្រកម្ពុជាឯករាជ្យ ចប់តែប៉ុណ្ណេះ ។

# សុន្ទរកថា

សហជីវិន ម៉ែង-ឈុំ អនុរដ្ឋលេខាធិការក្រសួងធម្មការ

---

សូមព្រះតេជៈដ៏គល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូលសម្ដេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាបក្រោមលំអងធូលីព្រះបាទ ។

ក្នុងនាមក្រសួងធម្មការនិងសាសនកិច្ចធិការ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះបរមរាជវរោកាស ថ្វាយនូវអំណរព្រះមហាករុណាធិគុណដ៏លើសលុប ដោយកតញ្ញូធម៌យ៉ាងស្មោះជាទីបំផុត ចំពោះសម្ដេចសហជីវិនព្រះប្រមុខរដ្ឋ ដ៏ជាទីគោរព ជាទីស្នេហានៃពលរដ្ឋទូទៅ ដែលទ្រង់សព្វព្រះរាជហឫទ័យ ស្ដេចយាងមកជាព្រះរាជាធិបតីដ៏ឧត្ដុង្គឧត្ដមបំផុត ក្នុងឱកាសបើកពិធីអនុសំវច្ឆរមហាសន្និបាតទី ២០ នៃមន្ត្រីសង្ឃ សម្រាប់ឆ្នាំថោះបញ្ចស័ក ព. ស. ២៥០៦ ។ ព្រះរាជកាយវិការដ៏វិសេសនេះ ទូលព្រះបង្គំជាខ្ញុំទាំងឡាយសូមលើកតំកើងតំកល់ទុកលើសិរសា ព្រោះក្នុងបច្ចុប្បន្នកាលនេះ ព្រះអង្គកំពុងមានព្រះរាជករណីយកិច្ចដ៏មមាញឹក ចំពោះការស្ថាបនាជាតិជាច្រើនយ៉ាង មានទ្រង់កែទម្រង់នយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាដើម ។

សូមព្រះតេជៈគឹគល់លើត្បូង សូមព្រះរាជទានព្រះបរមរាជវរោកាស ថ្វាយ ក្រាបបង្គំទូលសម្ដេចព្រះសង្ឃរាជ-ព្រះសង្ឃរាជាគណៈឋានានុក្រម-



សម្តេចព្រះប្រមុខរដ្ឋ និងសម្តេចព្រះមហាសង្ឃរាជទី ១ ទ្រង់កំពុងសន្ទនា នៅឱកាសពិធីអនុសំវច្ឆរមន្ត្រីសង្ឃ លើកទី ២០ នៅយ៉ពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រិត ថ្ងៃទី ១០ – ១ – ៦៤

មេគណ អនុគណ និងចៅអធិការគ្រប់ព្រះអង្គ ដែលនិមន្តមកពីក្នុងក្រុង និងខេត្តក្រៅនានា ទូទាំងព្រះរាជាណាចក្រ ។

សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃរាជ ៖

សូមពិតត្ថុដិកា ព្រះករុណាគ្រប់ព្រះអង្គ ៖

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា សូមថ្លែងនូវអំណរព្រះគុណយ៉ាងក្រៃលែងចំពោះសម្តេចព្រះសង្ឃរាជ និងព្រះករុណាគ្រប់ព្រះអង្គ ដែលបានស្តេចយាង និមន្តមកកាន់វិប្រជុំសន្និបាតនេះជាកិត្តិយស ដើម្បីញ៉ាំងពិធីនេះ ឲ្យរឹងរឹតតែបានរុងរឿងឡើងជាកិយ្យាភាព ។

សូមព្រះតេជៈតំកល់លើត្បូង ៖

នៅក្នុងឆ្នាំដែលកន្លងទៅនេះ ក្រសួងធម្មការនិងសាសនសិក្សាធិការ បានចាត់ការខាងផ្នែកព្រះពុទ្ធសាសនា តាមគម្រោយព្រះមាគ៌ានយោបាយនៃសម្តេចជាអម្ចាស់ ដែលព្រះអង្គតែងទ្រង់លើកជារឿយ ៗ ថា៖ ការស្ថាបនាជាតិនឹងចម្រើនរុងរឿងបានដោយអាស្រ័យការចំរើនស្មើ ៗ គ្នាគ្រប់វិស័យ មានវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ជាដើម ។

ដូច្នេះ ក្រសួងធម្មការដែលជាផ្នែកមួយខាងវប្បធម៌ ក៏បានខំបំពេញការកិច្ចនេះ មានការសិក្សាខាងផ្លូវព្រះពុទ្ធសាសនានិងផ្លូវលោក ការបោះពុម្ពផ្សាយសៀវភៅក្បួនច្បាប់ផ្សេង ៗ ការរៀបចំនូវតម្រាប់តម្រា បូរបូកណរបស់ជាតិ ការតាំងជាបណ្ណាល័យសាធារណៈ និងការប្រ

មូលដ្ឋានឯកសារទំនៀមទម្លាប់របស់ប្រទេស ដែលអាស្រ័យតាមរបបរស់នៅរបស់ជាតិតាំងពីព្រេងនាយ រហូតមកដល់បច្ចុប្បន្នកាលនេះ ។ កាលបើស្រាវជ្រាវកេរកបានគ្រាស់ក្រែលហើយ ក្រសួងធម្មការបានចាត់ការបោះពុម្ពផ្សាយឲ្យប្រជាពលរដ្ឋទូទៅ បានជ្រាបច្បាស់នូវរឿងរ៉ាវស្រុកទេសរបស់ខ្លួន ដែលជាហេតុដឹកនាំឲ្យមាននិស្ស័យស្រឡាញ់ជាតិកាន់តែច្បាស់ឡើង និងឲ្យជុះស្មារតីថ្មី ៗ សម្រាប់ជួយជ្រោមជ្រែងក្នុងការកសាងប្រទេសជាតិ តាមផែនការផ្ដើមនៃសម្ដេចសហជីវិនជាអម្ចាស់គ្រប់កាលៈ ទេសៈ ។ មិនតែប៉ុណ្ណោះ អាស្រ័យដោយព្រះមាគ៌ានយោបាយអព្យាក្រឹត ដែលសម្ដេចទ្រង់បានស្ថាបនាឡើង ការបោះពុម្ពនេះក៏បានផ្សាយទៅ ជាការផ្លាស់ប្ដូរវប្បធម៌ជាមួយប្រទេសជាមិត្តនានាក្នុងលោក ៗ

រីឯការរៀនសូត្រ នៅក្នុងពុទ្ធិកឧត្ដមសិក្សា មធ្យមសិក្សា និងបឋមសិក្សា កម្មវិធីបានតម្រូវឲ្យមានរៀនវិជ្ជាផ្លូវធម៌ និងផ្លូវលោក ដើម្បីអប់រំបណ្ដុះនិស្ស័យសមណនិស្សិត ដែលជាអនាគតពលរដ្ឋខ្មែរនោះ ឲ្យគ្រប់ជញ្ជាក់នូវសេឯកជ្បជាតិបានជាក់ច្បាស់ និងឲ្យរៀបចំចរិយាស្របទៅនឹងព្រះរាជនយោបាយរបស់សម្ដេចឪក្នុងការកសាងជាតិ ។ ព្រោះជាស្ថាប័ននានាក្នុងព្រះពុទ្ធសាសនា ទំនុកបម្រុងទៅបានក៏អាស្រ័យដោយស្រុកទេសបានចំរើនផលិតផល ប្រជាពលរដ្ឋមានជីវភាពខ្ពង់ខ្ពស់ ។

ការដែលសម្តេចឪទ្រង់កែទម្រង់សេដ្ឋកិច្ច ដែលបានប្រកបដោយជោគជ័យ គឺពិតជាធ្វើឲ្យព្រះពុទ្ធសាសនាមានជំហររឹងប៉ឹងស្ថិតស្ថេរជាកិយ្យាភាពតទៅ ។

អាស្រ័យដោយព្រះមាគ៌ានយោបាយរបស់សម្តេចឪដ៏ស័ក្តិសិទ្ធិនេះ បានជាព្រះសង្ឃជាទីគោរពនៃយើង ព្រះអង្គបានយកព្រះទ័យទុកដាក់ជួយគប់រំពុទ្ធបរិស័ទឲ្យជ្រះថ្លាក្នុងការកសាងជាតិ មានការកសាងមន្ទីរពេទ្យ កសាងសាលារៀន ការលើកទំនប់លើកថ្នល់សាធារណៈ និងការដាំកូនឈើក្នុងទីវត្ត និងទីស្រែចំការជាដើម ។

កាយវិការនិងសមិទ្ធិសំខាន់ ៗ ទាំងនេះ គឺពិតជាកើតឡើងដោយសារតម្រាយយ៉ាងពិសិដ្ឋរបស់សម្តេចព្រះអគ្គមគ្គុទ្ទេសក៍ និងព្រះអគ្គពុទ្ធសាសនូបត្ថម្ភកដ៏ធ្ងើមរបស់ខ្មែរ ព្រោះគ្រប់ពេលដែលព្រះអង្គទ្រង់យាងទៅធ្វើព្រះរាជទស្សនកិច្ចនៅទីនានា ព្រះអង្គតែងថ្លែងដាស់តឿនកូនចៅក្នុងវិស័យកសាងជាតិនិងវិស័យកសាងព្រះពុទ្ធសាសនា ហើយទ្រង់បានកសាងផ្ទាល់ព្រះអង្គផង ឧទាហរណ៍ៈ ដូចព្រះអង្គទ្រង់ចំណាយព្រះរាជទ្រព្យច្រើនលើសលុប កសាងព្រះវិហារវត្តអាកម មានវត្តនៅខេត្តរតនគិរី នៅក្រុងព្រះសីហនុ និងគ្រឹះស្ថានថ្មី នៅពុទ្ធិកវិទ្យាល័យនេះជាដើម ។ ព្រះកាយវិការដ៏ប្រពៃទាំងនេះ បញ្ជាក់ឲ្យទូលព្រះបង្គំជាខ្ញុំគ្រប់គ្នាយល់ច្បាស់ថាៈ ព្រះរាជបល្ល័ង្កដែលមានសម្តេចព្រះមហាក្សត្រិយានី និង

សម្តេចសហជីវិន ទ្រង់ជាទំមិត្តរួបក្នុងវេលានេះ ទ្រង់កសាងជាតិ សាងសាសនាជាគង់ពុទ្ធចក្រនិងអាណាចក្រ ឲ្យវិលលឿនទៅស្របគ្នាជាដរាប-ជាកស្កុតានដូចជាពីអតីតកាល ព្រះមហាក្សត្រសម័យអង្គរ ទ្រង់បានស្ថាបនាទំនប់ទឹកនៅបារាយណ៍ ស្ថាបនាមន្ទីរព្យាលពេទ្យជាច្រើនអនេកក្នុងផ្ទៃអាណាចក្រ និងស្ថាបនាផ្លូវថ្នល់ពីអង្គរមកខុត្តង្គ លុះមកដល់រជ្ជកាលព្រះករុណាព្រះបាទសម្តេចព្រះអង្គឌួង ព្រះបរមកោដ្ឋ ព្រះអង្គទ្រង់ស្ថាបនាផ្លូវពីខុត្តង្គទៅកម កសាងវត្តអារាមយ៉ាងច្រើន និងរៀបរៀងក្បួនច្បាប់តម្រាប់តម្រាជាភាសាជាតិ ហើយតមកព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ទ្រង់បានសាងព្រះវិហារព្រះកែវមរកត ព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ព្រះអង្គទ្រង់បានបង្កើតព្រះរាជបណ្ណាល័យ សាលាបាលី មន្ទីរពុទ្ធសាសនបណ្ឌិត្យ ព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ព្រះអង្គទ្រង់ចាត់ឲ្យប្រែព្រះត្រៃបិដក ។ លុះមកដល់បច្ចុប្បន្នសម្តេចសហជីវិនជាអម្ចាស់ ព្រះអង្គទ្រង់បន្តព្រះរាជបេសកកម្មដ៏ថ្លៃថ្លានេះ ហើយទ្រង់បានពង្រីកព្រះសកម្មភាព ឲ្យរឹងរិតតែធំទូលំទូលាយឡើងទៀត ។ ការឧបត្ថម្ភព្រះពុទ្ធសាសនានៃសម្តេចសហជីវិនជាអម្ចាស់ពុំត្រឹមតែក្នុងប្រទេសប៉ុណ្ណោះទេ ទោះបីនៅក្រៅប្រទេសក៏ដោយ ឲ្យតែមានអ្វីជាឧបស័គ្គដល់ព្រះពុទ្ធសាសនា ព្រះអង្គតែងទ្រង់ព្រះតម្រិះដល់ជានិច្ច ដូចជាជួយគាំទ្រព្រះពុទ្ធសាសនា នៅវៀតណាមខាងត្បូងនៅពេល

មានគេយាយីជិះជាន់ក្នុងគ្រាមុននេះជាដើម ។ ទាំងនេះជាព្រះគុណូបការៈធ្ងន់អនេកនៃព្រះរាជបល្ល័ង្ក ។

ក្នុងពេលដែលព្រះអង្គទ្រង់យាងមកជាព្រះរាជាធិបតីភាព នាវេលានេះក៏រឹងរឹតតែបញ្ជាក់នូវព្រះគុណូបការៈ នឹងទឹកព្រះទ័យជ្រះថ្លារបស់ព្រះអង្គក្នុងការជ្រោមជ្រែងដល់កន់ពុទ្ធចក្រ នឹងអាណាចក្រឲ្យជឿនលឿនទៅមុខជានិរន្តរ៍ ។

ជាអវសាន ទូលព្រះបង្គំជាខ្ញុំ សូមលំឱតលំឱនកាយឧទ្ទិសដល់គុណព្រះរតនត្រ័យ នឹងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក មានបារមីព្រះអតីតមហាក្សត្រខ្មែរទាំងឡាយនឹងទេវតាទាំងម៉ឺនលោកធាតុ មានទេវតាស្វេតច្ឆត្រនៃប្រទេសកម្ពុជានេះជាដើម សូមលោកជួយពិទ័រក្សាអង្គសម្តេចព្រះមហាក្សត្រីយានី នឹងសម្តេចព្រះឧបយុវរាជជាម្ចាស់ សូមព្រះអង្គប្រកបដោយព្រះបរមសុខសួស្តី មានព្រះជន្មាយុយឺនយូរ ដើម្បីបានជាម្លប់ដំមហាត្រជាក់នៃពលរដ្ឋខ្មែរទូទៅ ហើយសូមព្រះអង្គបានឈ្នះអស់មារសត្រូវ ទាំងក្នុងប្រទេស ទាំងក្រៅប្រទេស គ្រប់ទិសទី កុំបីបៀតបៀនព្រះអង្គតទៅ :

សូមព្រះតេជៈតំកល់លើត្បូង :

# រឿងតាំងចៅអធិការសម្រាប់វត្តនានា

តារាងរាយនាមព្រះតេជព្រះគុណដែលបានទទួលសញ្ញាប័ត្រ
បានតាំងជាចៅអធិការនិងគ្រូសូត្រនៃវត្តនានា ក្នុងព្រះរាជា
ណាចក្រ ចាប់ពីឆ្នាំ ១៩៦២

១– ព្រះតេជព្រះគុណ ព្រាប-អ៊ុំ នាមឆាយាធម្មសារ កើតឆ្នាំជូត អាយុ ៣៩ ឆ្នាំ វស្សា ១៥ បានទទួលការតែងតាំងជាគ្រូសូត្រក្នុងវត្តចេតិយ ឃុំសំបួរ ស្រុកសៀមរាប ខេត្តសៀមរាប លេខសញ្ញាប័ត្រ ៣.៣៩៦ ចុះថ្ងៃទី ១៩.៩.៦២ ។

២– ព្រះតេជព្រះគុណ លី-សុខ នាមឆាយា ឥន្ទសី កើតពី ព.ស. ២៤៧៩ អាយុ ២៦ ឆ្នាំ វស្សាបាន ៦ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្តចេតិយ ឃុំសំបួរ ស្រុកសៀមរាប ខេត្តសៀមរាប លេខសញ្ញាប័ត្រ ៣.៣៩៧ ចុះថ្ងៃទី ១៩.៩.៦២ ។

៣– ព្រះតេជព្រះគុណ ចេង-ឡុង នាមឆាយាឥន្ទសី កើតឆ្នាំច អាយុ ២៨ ឆ្នាំ វស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្តកំក្រោម ឃុំ ស្រុក ខេត្តសៀមរាប លេខសញ្ញាប័ត្រ ៣.៣៩៨ ចុះថ្ងៃទី ៩-៩-៦២ ។

៤– ព្រះតេជព្រះគុណ ពៅ-ពេជ នាមឆាយាធម្មជោត កើតពី គ.ស. ១៩៣៣ អាយុ ២៩ ឆ្នាំ វស្សាបាន ១០ បានទទួលតែងតាំងជា

ចៅអធិការ គណវត្ត ព្រែកពក ឃុំថ្នាធ្នង់ ស្រុកដំបូល ខេត្តស្វាយរៀង លេខសញ្ញាប័ត្រ ៣.៣៩៩ ចុះថ្ងៃទី ១៩-៩-៦២ ។

៤– ព្រះតេជព្រះគុណ ស៊ូរ-នន្ទ នាមឆាយានារតោ កើតឆ្នាំរកា អាយុ ២៩ ឆ្នាំ វស្សាបាន ១០ បានទទួលតែងតាំងជាចៅអធិការគណវត្តតេន-ទីបាកម ឃុំគគីធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៤០០ ចុះថ្ងៃទី ១៩-៩-៦២ ។

៦– ព្រះតេជព្រះគុណ ចេក-សំ នាមឆាយាឥន្ទសរ កើតឆ្នាំមមែ អាយុ ៣២ ឆ្នាំ វស្សា ១២ បានទទួលតែងតាំងជាគ្រូសូត្រស្ដាំ គណវត្តត្រពែក ឃុំសំរោង ស្រុកសូត្រនិគម ខេត្តសៀមរាប លេខសញ្ញាប័ត្រ ៣៤០១ ចុះថ្ងៃទី ១៩-៩-៦២ ។

៦– ព្រះតេជព្រះគុណ តាប-ផន នាមឆាយាឥន្ទសុវណ្ណ កើតឆ្នាំឆ្លូវ អាយុ ២៥ ឆ្នាំ វស្សា ៥ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង គណវត្តត្រពែក ឃុំសំរោង ស្រុកសូត្រនិគមខេត្តសៀមរាប លេខសញ្ញាប័ត្រ ៣៤០២ ចុះថ្ងៃទី ១៩-៩-៦២ ។

៨– ព្រះតេជព្រះគុណ សាត់-សែម នាមឆាយាឥន្ទសរ កើតឆ្នាំរកា អាយុ ៤២ ឆ្នាំ វស្សា ១៤ បានទទួលតែងតាំងជាគ្រូសូត្រស្ដាំវត្តបន្ទាយស្រី ឃុំដំដែក ស្រុកសូត្រនិគមខេត្តសៀមរាប លេខសញ្ញាប័ត្រ ៣៤០៣ ចុះថ្ងៃទី ១៩–៩–៦២ ។

៩– ព្រះតេជព្រះគុណ អ៊ិន-អ៊ុន នាមឋាយាសុវណ្ណត្ថេរ កើតឆ្នាំរោង អាយុ ៣៤ ឆ្នាំ វស្សា ១៤ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង កុដិវត្តបន្ទាយស្រី ឃុំដំដែក ស្រុកសូត្រនិគម ខេត្តសៀមរាប លេខសញ្ញាប័ត្រ ៣៤០៤ ចុះថ្ងៃទី ១៩.៩.៦២ ។

១០– ព្រះតេជព្រះគុណ ជួង.ទឹម នាមឋាយាធម្មសុវណ្ណ កើតឆ្នាំវក អាយុ ៥៥ ឆ្នាំ វស្សា ៣២ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ កុដិវត្តរលួស ឃុំ ស្រុកសូត្រនិគម ខេត្តសៀមរាប លេខសញ្ញាប័ត្រ ៣៤០៥ ចុះថ្ងៃទី ១៩.៩.៦២ ។

១១– ព្រះតេជព្រះគុណ សាន់.សយ នាមឋាយាសុវណ្ណសរ កើតពី គ.ស. ១៩០៩ អាយុ ៥៣ ឆ្នាំ វស្សា ៣៣ បានទទួលតែងតាំងជាចៅអធិការកុដិវត្តពោធិរាមា ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤០៦ ចុះថ្ងៃទី ១៩.៩.៦២ ។

(នៅមានត)

## បំណោទគំនិត

មានសត្វមួយ បើគេកាត់ក្បាលចេញ ក្លាយទៅជាវត្ថុមានតម្លៃ ។ តើសត្វនោះឈ្មោះដូចម្តេច ?

បើអ្នកអានណា អាចរកឃើញ ហើយបានផ្ញើចម្លើយព្រមទាំងអាសយដ្ឋាន ទៅពុទ្ធសាសនបណ្ឌិត្យមុនគេ យើងនឹងចុះផ្សាយការសរសើរជូនក្នុងទំព័រទស្សនាវដ្តីយើង ក្នុងលេខបន្ទាប់ ។